# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# ការធ្វើអស្សាមិករណ៍នៅកម្ពុជា ឆ្នាំ២០១៣ ដល់ឆ្នាំ២០២៣

ស្រាវជ្រាវចាប់ពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. ភាព សុម៉ាលីន**

**ក. លី ហ៊ុយឡៀង**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ បណ្ឌិត **អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការធ្វើអស្សាមិករណ៍នៅកម្ពុជា ឆ្នាំ២០១៣ ដល់ឆ្នាំ២០២៣

ស្រាវជ្រាវចាប់ពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. តាព សុម៉ាលីន**

**ក. លី ហ៊ុយឡៀង**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ បណ្ឌិត **អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំកញ្ញា **គាព សុម៉ាលីន** និងកញ្ញា **លី ហ៊ុយទៀង** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានសិក្សាចាប់ពីឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២៣។

ជាបឋម នាងខ្ញុំទាំងពីររូប មានកិត្តិយសសូមសេចក្តីអនុញ្ញាត ដើម្បីបានសម្តែងនូវគារវកិច្ចគោរពដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះជីដូន ជីតា លោកឪពុក ព្រមទាំងអ្នកម្តាយដែលលោកបានខិតខំប្រឹងប្រែងសព្វគ្រប់បែបយ៉ាងដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូន/ចៅ រហូតដល់ធំពេញវ័យ។ ជាពិសេសទៅទៀតនោះ**លោកអ្នកមានគុណទាំងទ្វេ**មិនត្រឹមតែផ្តល់កំណើតដល់កូនប៉ុណ្ណោះទេ លោកថែមទាំងបានទូន្មានប្រៀនប្រដៅផ្តល់នូវដំបូន្មានល្អៗប្រកបដោយគុណធម៌ ព្រហ្មវិហារធម៌ ភាពមេត្តាប្រោសប្រណីដល់កូនជានិច្ច។ លោកទាំងពីរបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយនឹងកម្លាំងចិត្តដើម្បីផ្តល់ធនធានដល់កូនបានសិក្សារៀនសូត្រក្លាយទៅជាបញ្ញាវ័ន្តមួយរូបដែលអាចជាសសរទ្រូងយ៉ាងរឹងមាំដល់ប្រទេសជាតិមាតុភូមិទាំងមូល។ ចំពោះទឹកចិត្តលោកអ្នកមានគុណទាំងពីរពិតជាធំធេងខ្លាំងណាស់ធំជាងភ្នំ ជ្រៅជាងមហាសមុទ្រ គ្មានអ្វីអាចនឹងប្រៀបផ្ទឹម បានឡើយ។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តម បណ្ឌិត សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាធិការរង គណៈគ្រប់គ្រង ព្រមទាំងសាស្ត្រាចារ្យទាំងអស់** ដែលបានខិតខំប្រឹងប្រែងជួយអប់រំ ណែនាំ បណ្តុះបណ្តាលផ្តល់នូវចំណេះដឹងផ្នែកបញ្ញាស្មារតី ព្រមទាំងបទពិសោធន៍ និងសមត្ថភាព ដែលជាស្ពានចម្លងដល់រូបនាងខ្ញុំទាំងពីរឱ្យក្លាយជាចំណែកមួយក្នុងការជួយអភិវឌ្ឍន៍ប្រទេសជាតិឱ្យកាន់តែមានភាពរីកចម្រើន។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ**លោកសាស្ត្រាចារ្យជំនួយ បណ្ឌិត អ៊ុន សកក្កដា** ដោយលោកប្រៀបបានដូចជា លោកឪពុកទីពីរ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចង្អុលបង្ហាញតម្រង់ទិសពន្យល់កែលម្អ ផ្តល់នូវយោបល់ និងវិធីសាស្ត្រល្អៗ ដោយយកចិត្តទុកដាក់ ព្រមទាំងបទពិសោធន៍មួយចំនួនក្នុងការណែនាំអំពីនីតិវិធីនៃការសិក្សាស្រាវជ្រាវប្រធានបទសារណាមួយនេះតាំងដើមរហូតដល់ទីបញ្ចប់។

ជាចុងក្រោយ នាងខ្ញុំសូមគោរពជូនពរដល់ ជីដូន ជីតា លោកឪពុក អ្នកម្តាយ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ ទាំងអស់ឱ្យជួបប្រទះតែសេចក្តីសុខ និងពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈសុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងនាមនាងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោយពីបានសិក្សាអស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ហើយឆ្នាំនេះគឺជាឆ្នាំទី៤ និងជាឆ្នាំបញ្ចប់នៃការសិក្សា។ នាងខ្ញុំទទួលបាននូវចំណេះដឹងជាច្រើនតាមរយៈលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យដែលបានណែនាំ អប់រំ ផ្តល់ដំបូន្មានល្អៗកន្លងមក បន្ទាប់ពីបានធ្វើការសិក្សា ក្រេបជញ្ជក់យកចំណេះដឹងពីលោក លោកស្រីសាស្ត្រាចារ្យ ព្រមទាំងបានស្រាវជ្រាវនូវឯកសារដ៏មានសារៈប្រយោជន៍ជាច្រើនរួចមក នាងខ្ញុំបានសង្កេតឃើញមាននូវចំណុចមួយចំនួនដែលទាក់ទាញចំណាប់អារម្មណ៍ ហេតុដូច្នេះហើយនាងខ្ញុំទាំងពីររូបពិតជាមានសេចក្តីសោមនស្សរីករាយជាក្រៃលែង ដែលមានឱកាសនូវក្នុងការបង្ហាញសមត្ថភាពសរសេរចងក្រងសារណាបញ្ចប់ការសិក្សាមួយក្បាលនេះឡើង ក្រោមប្រធានបទ "ការធ្វើអស្សាមិករណ៍នៅកម្ពុជា" មកធ្វើជាកម្មវត្ថុក្នុងការស្រាវជ្រាវដើម្បីបញ្ចប់ឆ្នាំសិក្សា។ ក្នុងគោលបំណងសំខាន់ដែលនាងខ្ញុំជ្រើសរើសយកនូវប្រធានបទនេះឡើងយកមកសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ គឺដោយសារនាងខ្ញុំសង្កេតឃើញថាពុំសូវមាននិស្សិតលើកឡើងពីបញ្ហានេះច្រើនឡើយ ហើយក៏ចង់ឱ្យប្រជាពលរដ្ឋមួយចំនួនគាត់មានការយល់ដឹងឱ្យកាន់តែមានភាពស៊ីជម្រៅបន្ថែមទៀតផងដែរទាក់ទងទៅនឹងបញ្ហាទាំងអស់នេះ។

យ៉ាងណាមិញសារណាបញ្ចប់ការសិក្សាមួយក្បាលនេះគ្រាន់តែជាសមិទ្ធផលតូចមួយដែលនាងខ្ញុំចងក្រងដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្ររបស់នាងខ្ញុំតែប៉ុណ្ណោះ ហើយនាងខ្ញុំក៏ដឹងថានៅតែបន្សល់ទុកនូវចំណុចខ្វះខាតជាច្រើនទៀតជាក់ជាពុំខាន នៅក្នុងសារណាមួយច្បាប់នេះនាងខ្ញុំទាំងពីរនាក់បានសិក្សា ស្រាវជ្រាវ និងដកស្រង់ចេញពីឯកសារពាក់ព័ន្ធមួយចំនួនទាំងនៅក្នុងបណ្ណាល័យ ក៏ដូចជាឯកសារផ្សេងៗដែលអាចជួយជាគំនិតទាក់ទងទៅនឹងសារណា។ ការសិក្សាស្រាវជ្រាវអំពីប្រធានបទនេះក៏បានជួបនូវការលំបាកមួយចំនួនផងដែរ ប៉ុន្តែមិនមែនជាឧបសគ្គបង្អាក់នូវការសម្រេចចេញនូវសារណាមួយនេះឡើយ។

ជាចុងក្រោយនាងខ្ញុំទាំងពីរនាក់សូមសង្ឃឹមយ៉ាងមុតមាំថា សារណាមួយក្បាលនេះនឹងបានផ្តល់នូវសារៈប្រយោជន៍ទៅដល់មិត្តនិស្សិតអ្នកអានទាំងអស់គ្នា ក៏ដូចជាបន្ថែមនូវជំនួយផ្នែកស្មារតីដល់សិស្សានុសិស្សដែលមានបំណងចង់សិក្សាស្រាវជ្រាវ និងស្វែងយល់បន្ថែមទាក់ទងនឹងប្រធានបទស្តីពីការធ្វើអស្សាមិករណ៍នៅកម្ពុជា។ នាងខ្ញុំដឹងថាការស្រាវជ្រាវនេះពុំទាន់ពេញលេញ និងគ្រប់ជ្រុងជ្រោយនៅឡើយទេ ដូច្នេះហើយនាងខ្ញុំរង់ចាំនូវមតិរិះគន់ដើម្បីស្ថាបនាពីអស់លោក លោកស្រី មិត្តនិស្សិតអ្នកអានទាំងអស់ ក្នុងការយកមតិទាំងអស់នោះមកកែតម្រូវបន្ថែមទៀតលើចំណុចដែលខ្វះខាត។ ជាទីបញ្ចប់នាងខ្ញុំសូមខន្តីអភ័យទោសនូវរាល់កំហុសខុសឆ្គងទាំងឡាយដែលកើតមានឡើងដោយអចេតនាក្នុងការសរសេរសារណាមួយនេះ។ ព្រមទាំងប្រសិទ្ធិពរជ័យឱ្យមិត្តនិស្សិតអ្នកអានជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ**អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១

## ទិដ្ឋភាពទូទៅនៃការធ្វើអស្សាមិករណ៍

**១.១. ការធ្វើអស្សាមិករណ៍នៅកម្ពុជា** ........ ៦

**១.១.១. សញ្ញាណទូទៅ** ........ ៧

១.១.១.១. ប្រវត្តិនៃការធ្វើអស្សាមិករណ៍ ........ ៩

១.១.១.២. យន្តការអនុវត្តអស្សាមិករណ៍ ........ ១០

**១.១.២. គោលបំណង និងសារៈប្រយោជន៍នៃការធ្វើអស្សាមិករណ៍** ........ ១១

១.១.២.១. គោលបំណង ........ ១២

១.១.២.២. សារៈប្រយោជន៍ ........ ១២

**១.២. លក្ខខណ្ឌនៃការធ្វើអស្សាមិករណ៍** ........ ១៤

**១.២.១. បុគ្គលដែលធ្វើអស្សាមិករណ៍** ........ ១៤

១.២.១.១. បុគ្គលសាធារណៈ ........ ១៤

១.២.១.២. បុគ្គលឯកជន ........ ១៦

**១.២.២. ទ្រព្យដែលអាចធ្វើអស្សាមិករណ៍** ........ ១៦

១.២.២.១. អចលនវត្ថុនៃបុគ្គលសាធារណៈ ........ ១៧

១.២.២.២. អចលនវត្ថុនៃបុគ្គលឯកជន ........ ១៩

## ជំពូកទី២

## នីតិវិធីនៃការធ្វើអស្សាមិករណ៍

**២.១. ការរៀបចំ និងការប្រព្រឹត្តិទៅនៃការធ្វើអស្សាមិករណ៍** ........ ២១

**២.១.១. នីតិវិធីមុនធ្វើគម្រោងអស្សាមិករណ៍** ........ ២១

២.១.១.១. សំណើស្តីពីគម្រោងអស្សាមិករណ៍ ........ ២២

២.១.១.២. ការផ្តល់ព័ត៌មានស្តីពីគម្រោងនៃការធ្វើអស្សាមិករណ៍ ........ ២៤

**២.១.២. កិច្ចដំណើរការនៃការធ្វើអស្សាមិករណ៍** ........ ២៥

២.១.២.១. នីតិវិធីនៃការដកហូតអចលនវត្ថុ ........ ២៥

២.១.២.២. ការអនុវត្តគម្រោងអស្សាមិករណ៍ជាក់ស្តែង ....................................................................២៩
**២.២. ការទូទាត់សំណង និងបញ្ហាប្រឈមនៃការធ្វើអស្សាមិករណ៍** ................................... ៣១
**២.២.១. គោលការណ៍នៃការទូទាត់សំណង** ........................................................................ ៣១
២.២.១.១. រូបមន្តនៃការទូទាត់សំណង ................................................................................... ៣១
២.២.១.២. ការគណនាសំណង ................................................................................................ ៣៤
**២.២.២. បញ្ហាប្រឈម និងដំណោះស្រាយ** ......................................................................... ៣៥
២.២.២.១. បញ្ហាប្រឈម ......................................................................................................... ៣៦
២.២.២.២. ការដោះស្រាយវិវាទអស្សាមិករណ៍ ........................................................................ ៣៩
**សេចក្តីសន្និដ្ឋាន** ..................................................................................................................៤៣
**អនុសាសន៍** ......................................................................................................................... ៤៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ក្រោយពីប្រទេសកម្ពុជាបានឆ្លងកាត់នូវភ្លើងសង្គ្រាមដ៏ក្តៅគគុកអស់រយៈពេលជាច្រើនទស្សវត្សរ៍រួចមក ធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធកម្ពុជាត្រូវបានបំផ្លិចបំផ្លាញខ្ទិចខ្ទីអស់គ្មានសល់ ជាពិសេសតំបន់ដែលធ្លាប់បានរៀបចំមានរបៀបរៀបរយ ល្អប្រណិត ជាតំបន់ដែលធ្លាប់ទាក់ទាញ និងមានការកោតសសើរមិនដាច់ពីមាត់តាមរយៈសំណាក់ ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិបែរជាត្រូវបានខូចខាតបាត់បង់សោភ័ណ្ឌភាពស្ទើរតែទាំងស្រុង តែយ៉ាងណាក្តីក្រោយពីការរំដោះពីរបបប្រល័យពូជសាសន៍នាឆ្នាំ១៩៧៩ និងនយោបាយឈ្នះឈ្នះ នាងខ្ញុំបានសង្កេតឃើញថាប្រទេសកម្ពុជាមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការ កសាងខ្លួនឡើងវិញដើម្បីផ្លាស់ប្តូរមុខមាត់ជាតិសារជាថ្មី ឆ្ពោះទៅរកសុខសន្តិភាព ស្ថេរភាព សុខមាលភាព និងកំពុងឈានទៅរកការអភិវឌ្ឍមួយយ៉ាងគួរជាទីកត់សម្គាល់ ដោយសព្វថ្ងៃនេះគឺមានការរីកចម្រើនយ៉ាងខ្លាំងស្ទើរតែគ្រប់វិស័យទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ អាគារខ្ពស់ៗ សាលារៀន មន្ទីរពេទ្យ ស្ពានអាកាស ព្រលានយន្តហោះ ផ្ទះសម្បែង ដីធ្លី។ល។ យ៉ាងណាមិញពីសម័យកាលមួយទៅសម័យកាលមួយ តែងតែមានការវិវត្តប្រែប្រួលខុសៗពីគ្នាទៅតាមរចនាបទនៃការដឹកនាំរបស់រាជរដ្ឋាភិបាល ប៉ុន្តែបញ្ហាប្រឈមនៅតែកើតមានឡើងឥតឈប់ឈរ រវាងប្រជាពលរដ្ឋជាមួយរដ្ឋ រវាងប្រជាពលរដ្ឋជាមួយក្រុមហ៊ុនឯកជន និងរវាងរដ្ឋជាមួយប្រជាពលរដ្ឋ។ បញ្ហាទាំងអស់នេះវាកើតចេញពីកង្វះនូវការអប់រំ ការយល់ដឹង កង្វះប្រព័ន្ធផ្សព្វផ្សាយច្បាប់ និងកត្តាជាច្រើនទៀត ដោយមូលហេតុប្រទេសកម្ពុជាស្ថិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នៅឡើយ ហើយការយល់ដឹងពីច្បាប់ដីធ្លីរបស់ប្រជាជននូវមានកម្រិតទាបនិងភាពអាណាធិបតេយ្យផងដែរ។ ទើបជំរុញឱ្យមានការបង្កើតបទដ្ឋានគតិយុត្តនិងគោលការណ៍នីតិវិធីជាច្រើនបន្តបន្ទាប់ និងវិសោធនកម្មជាហូរហែពាក់ព័ន្ធជុំវិញទំនាក់ទំនងវិវាទដីធ្លីនេះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ទោះបីជាយ៉ាងណាក៏ដោយរាល់ការអភិវឌ្ឍតែងតែកើតមានឡើងនូវគុណសម្បត្តិ និងគុណវិបត្តិដូចជាការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធនៅព្រះរាជាណាចក្រកម្ពុជាទៀតសោត ឃើញថាមានការរីកលូតលាស់ជោគជ័យជាហូរហែ ពីមួយគម្រោងទៅមួយគម្រោង ទាំងគម្រោងតូច និងគម្រោងធំៗ ហើយបានចាក់គ្រឹះលិចចេញជារូបរាងឡើងក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ដែលសម្រេចបាននូវលទ្ធផលយ៉ាងត្រចះត្រចង់ ព្រមទាំងបានបម្រើដល់ផ្នែកសេដ្ឋកិច្ចជាតិ និងបម្រើផលប្រយោជន៍សាធារណៈដល់ប្រជាពលរដ្ឋមួយផ្នែកធំ ដោយយើងបានសង្កេតឃើញថាមានសំណង់ ការសាងសង់ផ្លូវថ្នល់ ស្ពាន សម្រាប់បម្រើដល់វិស័យដឹកជញ្ជូន ព្រមទាំងវិស័យទេសចរណ៍ជាដើម។ល។ ប៉ុន្តែរាល់ការអភិវឌ្ឍគម្រោងទាំងអស់នោះក៏បានជួបប្រទះនូវផលលំបាកដល់ប្រជាពលរដ្ឋជាច្រើនទាក់ទិនទៅនឹងបញ្ហាដីធ្លី ផ្ទះសម្បែង ដោយតម្រូវឱ្យមានការរុះរើរើបអូស

ដែលជាកម្មសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋ ដើម្បីសម្រេចតាមផែនការនៃការអនុវត្តគម្រោង។ មួយវិញទៀត វាបានបង្កឱ្យមាន ការធ្វើកូដកម្ម បាតុកម្ម ការចម្រូងចម្រាសគ្នាទៅវិញទៅមក ដែលបានធ្វើអោយគម្រោងខ្លះមានការអាក់ខានរអាក់រអួល និងបង្កើតទៅជា អស្ថេរភាព អសន្តិសុខជាតិនៅក្នុងសង្គម។ គុណវិបត្តិទាំងអស់នេះហើយបានក្លាយទៅ ជាបញ្ហាដ៏ស្មុគស្មាញដល់មន្ត្រីមូលដ្ឋាន ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ដែលពាក់ព័ន្ធ។ អាស្រ័យហេតុនេះហើយ ទើបបានជារាជរដ្ឋាភិបាលបង្កើតនូវបទដ្ឋានគតិយុត្តនានាយ៉ាងច្រើនរួមមានច្បាប់ភូមិបាលតែច្បាប់នេះគ្រាន់តែជា មូលដ្ឋានពាក់ព័ន្ធទៅនឹងការគ្រប់គ្រងដីធ្លីបន្តិចបន្តួចប៉ុណ្ណោះនៅមិនទាន់មានលក្ខណៈស៊ីជម្រៅនៅឡើយទេ។ ហេតុដូច្នេះ ហើយទើបរាជរដ្ឋាភិបាលខិតខំរិះរកនូវប្រព័ន្ធបទដ្ឋានគតិយុត្តថ្មីមួយផ្សេងទៀតគឺ ច្បាប់ស្ដីពីអស្សាមិករណ៍នៅកម្ពុជាដែលត្រូវបានរដ្ឋសភាអនុម័ត កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងព្រឹទ្ធសភាបានយល់ព្រមស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ និងប្រកាសឱ្យប្រើកាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០ ដែលប្រព័ន្ធច្បាប់ស្ដីពីអស្សាមិករណ៍នេះបង្កើតឡើងសម្រាប់ធ្វើការដោះស្រាយនូវរាល់បញ្ហាវិវាទទាំងការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុរបស់ប្រជាពលរដ្ឋសម្រាប់ការសាងសង់ សំណង់ ការបម្រើដល់ស្ថាបនា ការស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដែលបម្រើទៅដល់ផលប្រយោជន៍សាធារណៈ និងប្រយោជន៍ជាតិរាល់ការអភិវឌ្ឍរបស់ព្រះរាជាណាចក្រកម្ពុជានោះ រាជរដ្ឋាភិបាលមានគោលការណ៍ និងយន្តការសម្រាប់ធ្វើការគណនា ក៏ដូចជាការទូទាត់សំណងជូនទៅប្រជាពលរដ្ឋជាមុនយ៉ាងសមរម្យ និងយុត្តិធម៌ទៅតាមស្ថានភាពជាក់ស្តែង។ ក៏ប៉ុន្តែនូវតែកើតមានមន្ទិលសង្ស័យជុំវិញអត្ថន័យ និងបញ្ហាមួយចំនួនពាក់ព័ន្ធទៅនឹងការអនុវត្តជាក់ស្តែងហេតុដូច្នេះ ហើយទើបមានការចោទសួរជារើយៗពាក់ព័ន្ធទៅនឹងបញ្ហាមួយចំនួនដូចខាងក្រោម៖

១. តើយន្តការនៃការធ្វើអស្សាមិករណ៍ប្រព្រឹត្តទៅយ៉ាងដូចម្តេច?

២. តើច្បាប់ស្តីពីអស្សាមិករណ៍មានគោលបំណង និងសារៈប្រយោជន៍អ្វីខ្លះ?

៣. ដើម្បីអាចធ្វើអស្សាមិករណ៍បាន តើត្រូវបំពេញនូវលក្ខខណ្ឌអ្វីខ្លះ?

៤. ក្នុងកិច្ចដំណើរការនៃការធ្វើអស្សាមិករណ៍ តើត្រូវប្រព្រឹត្តទៅយ៉ាងដូចម្តេច?

៥. តើការធ្វើអស្សាមិករណ៍ជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះ? ហើយ តើរាជរដ្ឋាភិបាលមានដំណោះស្រាយយ៉ាងដូចម្តេច ចំពោះបញ្ហាប្រឈមទាំងអស់នេះ?

៦. តើច្បាប់អស្សាមិករណ៍ផ្តល់នូវភាពយុត្តិធម៌ជូនប្រជាពលរដ្ឋដែរឬទេ?

## ៣. គោលបំណងនៃកិច្ចការស្រាវជ្រាវ

គោលបំណងនៃកិច្ចការស្រាវជ្រាវនេះ ក្រុមរបស់នាងខ្ញុំបានសង្កេតឃើញថាមានចំណុចជាច្រើនគួរជាទីកត់សម្គាល់ដូចតទៅះ

**ទី១** ដោយសារឃើញកើតមាននូវបញ្ហារឹបអូសដីធ្លីរបស់ប្រជាពលរដ្ឋក្រោមរូបភាព និងស្ថានភាពជាក់ស្តែងជាច្រើនគួរជាទីកត់សម្គាល់ តាមរយៈការសាងសង់សំណង់នានាជាអាទិ៍។

**ទី២** ផ្សព្វផ្សាយច្បាប់អស្សាមិករណ៍ឱ្យកាន់តែមានភាពទូលំទូលាយជាងមុន ក៏ដូចជាចែករំលែកនូវចំណេះដឹងដែលពាក់ព័ន្ធអំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋជាពិសេសដើម្បីផ្តល់នូវព័ត៌មានមួយចំនួនឱ្យគាត់មានការយល់ដឹងឱ្យស៊ីជម្រៅបន្ថែមទៀតអំពីនីតិវិធីនៃការអនុវត្តច្បាប់នេះ ព្រមទាំងការទូទាត់សំណងឱ្យបានត្រឹមត្រូវជៀសវាងមានការគាបសង្កត់ ជិះជាន់ពីសំណាក់អ្នកមានអំណាចផ្សេងៗក្នុងរូបភាពណាមួយជាអាទិ៍។

**ទី៣** សិក្សាស្វែងយល់ឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតទៅលើបទដ្ឋានគតិយុត្តនេះថា តើរាជរដ្ឋាភិបាលពិតជាធានាបាននូវការដកហូតសិទ្ធិស្របច្បាប់លើកម្មសិទ្ធិឯកជនដោយសងសំណងយ៉ាងសមរម្យ និងយុត្តិធម៌រួមទាំងបម្រើដល់ផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិជូនទៅដល់ប្រជាពលរដ្ឋតាមរូបភាពបែបណាក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា។

**ទី៤** ធ្វើឡើងដើម្បីពង្រឹង និងបង្កើនប្រសិទ្ធិភាពខ្ពស់លើវិស័យនៃការអនុវត្តច្បាប់អស្សាមិករណ៍ឱ្យកាន់តែមានភាពងាយស្រួល និងមានលក្ខណៈល្អប្រសើរ ហើយថែមទាំងមានភាពត្រឹមត្រូវស្របទៅតាមបទបញ្ញត្តិនៃច្បាប់ព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះទៅទៀត ដើម្បីកាត់បន្ថយទំនាស់រវាងប្រជាពលរដ្ឋជាមួយប្រជាពលរដ្ឋព្រមទាំងរវាងប្រជាពលរដ្ឋជាមួយក្រុមហ៊ុនឯកជន និងរវាងរដ្ឋជាមួយរដ្ឋ ដែលជាហេតុបង្កឱ្យមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសេចក្តីថ្លៃថ្នូររបស់សង្គមជាតិទាំងមូលផងដែរ។

**ទី៥** ដោយហេតុថាពុំសូវឃើញមាននូវកិច្ចការស្រាវជ្រាវទាក់ទងទៅនឹងប្រធានបទ ការធ្វើអស្សាមិករណ៍នៅព្រះរាជាណាចក្រកម្ពុជាណាមួយមានលក្ខណៈលំអិត និងស៊ីជម្រៅច្រើននៅឡើយទេ ទើបក្រុមរបស់នាងខ្ញុំសម្រេចលើកយកប្រធានបទនេះមកបង្ហាញដើម្បីជាជំនួយដល់បញ្ញាស្មារតី ក៏ដូចជាគុណប្រយោជន៍ទៅដល់បងប្អូន មិត្តនិស្សិតគ្រប់ជំនាន់ដែលចង់សិក្សាស្វែងយល់បន្ថែមពាក់ព័ន្ធនឹងបញ្ហានេះ។

## ៤. ទំហំ និងដែនកំណត់នៃកិច្ចការស្រាវជ្រាវ

ចំពោះកិច្ចការស្រាវជ្រាវប្រធានបទខាងលើត្រូវបានកំណត់យកតាមប្រព័ន្ធច្បាប់អស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នាងខ្ញុំផ្តោតសំខាន់តែចំពោះបុគ្គលដែលអាចធ្វើអស្សាមិករណ៍ ទ្រព្យដែលអាចយកទៅធ្វើអស្សាមិករណ៍បានក៏ដូចជានីតិវិធីមួយចំនួនមុនឈានទៅដល់ការអនុវត្តច្បាប់អស្សាមិករណ៍នេះឡើង។ ដែលត្រូវឆ្លងកាត់នូវការរៀបចំជាច្រើនដំណាក់កាលគិតចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២៣ តែប៉ុណ្ណោះ។ ពោលគឺ

មិនបានស្រាវជ្រាវទូលំទូលាយនោះទេ។ ចំពោះវិសាលភាពនៃកិច្ចការស្រាវជ្រាវដែលពាក់ព័ន្ធទៅនឹងប្រធានបទនេះរួមមានលិខិតបទដ្ឋានគតិយុត្តនានា និងច្បាប់ដែលទាក់ទិនជាគោលក្នុងប្រធានបទខាងលើនេះ។

## ៥. សារៈសំខាន់នៃកិច្ចការស្រាវជ្រាវ

នាងខ្ញុំសង្កេតឃើញថាការសិក្សាស្រាវជ្រាវប្រធានបទមួយនេះបានផ្ដល់នូវសារៈសំខាន់ជាច្រើនរូបភាពផងដែរ ដែលរូបភាពទាំងអស់នោះមានទាំងសារៈសំខាន់ចំពោះប្រទេសជាតិទាំងមូល ពោលគឺបានផ្សព្វផ្សាយនឹងចែករំលែកអំពីនីតិវិធីនៃការអនុវត្តស្របតាមមាត្រដ្ឋាននៃច្បាប់ ប្រទេសជាតិបានជួយកាត់បន្ថយវិវាទមួយផ្នែកធំដែលកើតមានស្របពេលដែលកំពុងអភិវឌ្ឍន៍ក្នុងការបម្រើផលប្រយោជន៍សាធារណៈ និងប្រយោជន៍ជាតិទាំងអស់នេះហើយជាគ្រឹះយ៉ាងសំខាន់ដែលអាចជួយជំរុញឱ្យប្រទេសជាតិមានភាពសម្បូរបែប រីកចម្រើនស្ទើរតែគ្រប់វិស័យ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធកាន់តែមានភាពជឿនលឿនទៀតផង។ មិនតែប៉ុណ្ណោះចំពោះជនរងគ្រោះអាចដឹងនឹងស្វែងយល់អំពីដែនកំណត់នៃសិទ្ធិរបស់ខ្លួនក្នុងនាមជាម្ចាស់អចលនវត្ថុក្នុងការព្យាយាមរិះរកគ្រប់ដំណោះស្រាយដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់សម្រាប់ខ្លួនឯងដោយផ្ទាល់ ព្រមទាំងអាចតតាំងនូវបញ្ហាដែលកើតមានទាន់ពេលវេលា លើសពីនេះជនរងគ្រោះក៏អាចថ្លឹងថ្លែងបានចំពោះសំណងដែលខ្លួនត្រូវទទួលបាន ជៀសវាងការកើតមាននូវទំនាស់ណាមួយជាយថាហេតុនាកិច្ចចាប់ផ្ដើមគម្រោងអស្សាមិករណ៍នេះឡើង។ ដោយឡែករាល់ផលប្រយោជន៍ដែលកើតមានចំពោះប្រជាពលរដ្ឋទូទៅក៏ដូចគ្នា ប្រសិនបើគាត់មានការយល់ដឹងកាន់តែច្រើន នោះគាត់អាចបង្ការទុកជាមុននូវរាល់បញ្ហាប្រឈមតាមរយៈការធ្វើអស្សាមិករណ៍បានទាន់ពេលវេលា ព្រមទាំងមិនធ្វើឱ្យខាតបង់នូវផលប្រយោជន៍ហើយអាចជាការរួមចំណែកមួយសម្រាប់សម្រួលដល់ការអភិវឌ្ឍជាតិផងដែរ។ មិនតែប៉ុណ្ណោះ ប្រជាពលរដ្ឋដែលអាចយល់ដឹងអំពីនីតិវិធីច្បាប់អស្សាមិករណ៍កាន់តែមានភាពងាយស្រួលក្នុងការអនុវត្តកាន់តែឆាប់រហ័ស។

## ៦. វិធីសាស្ត្រនៃកិច្ចការស្រាវជ្រាវ

តាមរយៈការសរសេរស្រាវជ្រាវលើប្រធានបទ "ការធ្វើអស្សាមិករណ៍នៅកម្ពុជា" នាងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវដោយប្រកាន់នូវគោលជំហរផ្អែកលើទិន្នន័យចំនួន២ ពោលគឺទីមួយទិន្នន័យចម្បង និងទីពីរទិន្នន័យបន្ទាប់បន្សំ។ ចំពោះទិន្នន័យទាំងពីរមានមូលដ្ឋានដូចតទៅ៖

- **ទិន្នន័យចម្បង** ផ្អែកទៅលើកម្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធច្បាប់អស្សាមិករណ៍រួមមានច្បាប់ផ្សេងៗទៀតដូចជាព្រះរាជក្រម អនុក្រឹត្យ ច្បាប់ សេចក្ដីជូនដំណឹងចេញដោយរាជរដ្ឋាភិបាលព្រមទាំងក្រសួងដែលពាក់ព័ន្ធនានា។
- **ទិន្នន័យបន្ទាប់បន្សំ** ផ្អែកទៅលើការសិក្សាស្រាវជ្រាវនៅតាមគេហៈទំព័រមួយចំនួន ទាំងគេហៈទំព័ររបស់រាជរដ្ឋាភិបាល និងគេហៈទំព័ររបស់អង្គការមិនមែនរាជរដ្ឋាភិបាលព្រមទាំងគេហៈទំព័រព័ត៌មានក្នុងស្រុក។

## ៧. រចនាសម្ព័ន្ធនៃកិច្ចការស្រាវជ្រាវ

ចំពោះសារណាបញ្ចប់ការសិក្សានេះ នាងខ្ញុំបានបែងចែកជា ២ជំពូកគឺ៖

- **ជំពូកទី១ " ទិដ្ឋភាពទូទៅនៃការធ្វើអស្សាមិករណ៍ "** ៖ ដែលក្នុងនោះផងដែរមាន ២ ចំណុច ដែលនាងខ្ញុំនឹងលើកយកមកបង្ហាញ ដោយចំណុចទី១ និយាយអំពីការធ្វើអស្សាមិករណ៍នៅកម្ពុជា និងចំណុចទី២ បង្ហាញអំពីលក្ខខណ្ឌនៃការធ្វើអស្សាមិករណ៍។
- **ជំពូកទី២ " នីតិវិធីនៃការធ្វើអស្សាមិករណ៍ "** ៖ ដែលក្នុងនោះផងដែរមាន ២ ចំណុចដែល នាងខ្ញុំលើកយកមកបង្ហាញ ដោយចំណុចទី១ និយាយអំពីការរៀបចំ និងការប្រព្រឹត្តិទៅនៃការធ្វើ អស្សាមិករណ៍ និងចំណុចទី២ បង្ហាញអំពីការទូទាត់សំណង និងបញ្ហាប្រឈមនៃការធ្វើអស្សាមិករណ៍។

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃការ
# ធ្វើអស្សាមិករណ៍នៅកម្ពុជា

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃការធ្វើអស្សាមិករណ៍

## ១.១. ការធ្វើអស្សាមិករណ៍នៅកម្ពុជា

ដី គឺជាប្រធានបទដ៏សំខាន់នៅក្នុងការជជែកពិភាក្សាអំពីការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៃប្រទេសកម្ពុជា។ ហេតុដូច្នេះហើយយើងខ្ញុំសង្កេតឃើញថាការកកើតនូវវិវាទដីធ្លី គឺជាបញ្ហាដ៏សំខាន់មួយក្នុងចំណោមបញ្ហាផ្សេងៗទៀតរបស់កម្ពុជា។ វិវាទដីធ្លីបណ្តាលមកពីកត្តាមួយចំនួនដូចជា គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងទីក្រុង និងនៅតាមទីជនបទដូចជា ការសម្បទានដីសេដ្ឋកិច្ច និងសម្បទានផ្សេងៗទៀត។[១] ស្របតាមក្របខ័ណ្ឌគតិយុត្តស្តីពីអស្សាមិករណ៍មានការចងកាតព្វកិច្ចក្នុងច្បាប់អន្តរជាតិ។ យោងតាមច្បាប់អន្តរជាតិការតាំងលំនៅថ្មីដោយបង្ខំ និងដោយមិនមានការស្ម័គ្រចិត្ត ត្រូវបានចាត់ទុកថាជាការដើរថយក្រោយនៃការទទួលបានសិទ្ធិមនុស្ស។ ប្រទេសកម្ពុជា គឺជាភាគីហត្ថលេខីសន្ធិសញ្ញាអន្តរជាតិជាច្រើន ហេតុដូច្នេះត្រូវមានកាតព្វកិច្ចក្នុងការការពារប្រជាពលរដ្ឋរបស់ខ្លួនប្រឆាំងនូវរាល់វិធានការធ្វើឱ្យសិទ្ធិមនុស្សមានការធ្លាក់ចុះ ដែលជាក់ចេញមកដោយអង្គភាពរដ្ឋាភិបាល និងតតិយជន។[២] យើងក្រឡេកមកមើលច្បាប់អស្សាមិករណ៍សំដៅដល់ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុរបស់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈរួមមាន ដី សំណង់ និងដំណាំដាំដុះសម្រាប់បម្រើការស្ថាបនា ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដែលបម្រើប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ ព្រមទាំងផ្តល់នូវសំណងជាមុនដោយសមរម្យ និងមានភាពយុត្តិធម៌។[៣] ពោលគឺដើម្បីធានាថារាល់ការរឹបអូសកម្មសិទ្ធិត្រូវបានធ្វើឡើងដោយសមស្រប និងយុត្តិធម៌ជាមុនសិន សំដៅដល់ការបម្រើផលប្រយោជន៍ជាតិ និងផលប្រយោជន៍សាធារណៈ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។ ការដកហូតអនុវត្តន៍តែចំពោះកិច្ចការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈរួមមានការសាងសង់ ឬពង្រីកហេដ្ឋារចនាសម្ព័នដូចជា (ផ្លូវអយស្ម័យយាន ផ្លូវថ្នល់ ស្ពាន អាកាសយានដ្ឋាន កំពង់ផែសម្រាប់ដឹកជញ្ជូន ដោយរួមទាំងរចនាសម្ព័ន្ធ និងឧបករណ៍។ ការផ្គត់ផ្គង់អគ្គីសនី (ស្ថានីយ៍ថាមពលអគ្គីសនីខ្សែបណ្តាញបញ្ជូន)ជាអាទិ៍។ ប្រព័ន្ធគមនាគមន៍រួមមានដូចជា (ប្រៃសណីយ៍ ទូរគមនាគមន៍ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ល។ គោលបំណងខាងអប់រំផ្នែកវិទ្យាសាស្ត្រ និងវប្បធម៌រួមមានដូចជា (សាលារៀនបណ្តុះបណ្តាលសារមន្ទីរ)។ល។ ផ្នែកសេវាថែទាំសុខភាព (មណ្ឌលសុខភាពមន្ទីរពេទ្យ)។ល។ ការរុករកផូស៊ីល (រោងចក្រហ្គាសបណ្តាញបំពង់ប្រេងឥន្ទនៈ រោងចក្រចម្រាញ់ប្រេង)។ល។ អគារដែលរងនូវការបំផ្លិចបំផ្លាញធ្ងន់ធ្ងរដោយសារ

[១] ការវិភាគទិន្នន័យស្ថិតិស្តីពីវិវាទដីធ្លីនៅកម្ពុជាក្នុងឆ្នាំ២០១០។

[២] គេហទំព័រ https://opendevelopmentcambodia.net/km/tipics/expropriation/ ដកស្រង់នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣។

[៣] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា៤ វាក្យខណ្ឌទី១។

គ្រោះធម្មជាតិ ក៏អាចជាកម្មវត្ថុនៃការដកហូតដូចគ្នាទៅនឹងតំបន់វប្បធម៌ និងតំបន់វិទ្យាសាស្ត្រពិសេសដោយផ្តល់នូវផលប្រយោជន៍ខាងបរិស្ថាន និងប្រវត្តិសាស្ត្រព្រមទាំងដីដែលត្រូវការចាំបាច់សម្រាប់ការតាំងទីលំនៅថ្មី ការការពារ និងគាំទ្រសិទ្ធិប្រជាពលរដ្ឋកន្លែងកាត់ព្រំដែន ការពារជាតិ និងសន្តិសុខជាតិ។[៤]

យ៉ាងណាមិញ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានធ្វើការលើកឡើងថា យើងអាចប្រើប្រាស់ច្បាប់អស្សាមិករណ៍នេះបាននៅពេលណាដែលផលប្រយោជន៍រដ្ឋតម្រូវ ពោលគឺត្រូវតែយកមកប្រើប៉ុន្តែអាជ្ញាធរក៏ដូចជាក្រសួងដែលពាក់ព័ន្ធទាំងអស់ត្រូវសុំការអនុញ្ញាត ឬយោបល់ជាមុនសិន មុននឹងសម្រេចឈានទៅដល់ការអនុវត្តច្បាប់អស្សាមិករណ៍ សម្រាប់ការដកហូតដីឯកជនមកស្ថាបនាគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។ ជាទូទៅច្បាប់អស្សាមិករណ៍ត្រូវបានធ្វើឡើងនៅក្នុងករណីដែលប្រជាពលរដ្ឋរឹងរូសមិនព្រមទទួលសំណងចំពោះផលប៉ះពាល់ពីគម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធនានា ដោយរដ្ឋមានសិទ្ធិក្នុងការដកហូតដីនោះ។ ប៉ុន្តែមន្ត្រីត្រូវប្រើប្រាស់ច្បាប់នេះឱ្យមានតម្លាភាព និងយុត្តិធម៌ ត្រឹមត្រូវ និងប្រើនៅពេលចាំបាច់ប៉ុណ្ណោះ។[៥]

### **១.១.១. សញ្ញាណទូទៅ**

យើងអាចកំណត់សម្គាល់បានថាការកសាង គឺជាថ្នាលមួយយ៉ាងចម្បងសម្រាប់ការអភិវឌ្ឍប្រទេសជាតិឱ្យឈានទៅរកភាពរីកចម្រើនមិនថា ការកសាងស្ពានអាកាស ផ្លូវ ថ្នល់ សាលារៀន មន្ទីរពេទ្យ ព្រមទាំងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជាច្រើនផ្សេងៗទៀតជាអាទិ៍។ ដែលទាំងអស់នេះសុទ្ធសឹងតែជារូបភាពនៃការបន្សល់ទុកជាសមិទ្ធផលសម្រាប់សង្គមជាតិទាំងមូល ព្រមទាំងជាតម្រូវការចាំបាច់សម្រាប់ប្រជាពលរដ្ឋផងដែរ។ ដើម្បីធ្វើឱ្យការកសាងកាន់តែមានភាពរីកលូតលាស់ ហើយមានប្រសិទ្ធិភាពខ្ពស់នោះ លុះត្រាតែមានកត្តាទីតាំងភូមិសាស្ត្រល្អជាចម្បងផងដែរ ព្រមទាំងកត្តាដីធ្លីដែលមានលក្ខណៈសមាមាត្រទៅនឹងការអភិវឌ្ឍទៀតនោះ ទើបជាហេតុជំរុញឱ្យរាជរដ្ឋាភិបាលបានធ្វើការដកហូតនូវសិទ្ធិកម្មសិទ្ធិស្របច្បាប់លើអចលនវត្ថុពីម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ។ មានតែរដ្ឋទេដែលជាអ្នកធ្វើអស្សាមិករណ៍ដើម្បីប្រើប្រាស់ក្នុងគោលដៅជាផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ[៦] ពោលគឺរដ្ឋមិនអាចយកការធ្វើអស្សាមិករណ៍នេះទៅប្រើប្រាស់ក្នុងគោលដៅបម្រើផលប្រយោជន៍របស់បុគ្គលឯកជនដោយយកអចលនវត្ថុដែលរឹបអូសបានពីប្រជាពលរដ្ឋរួចផ្ទេរអចលនវត្ថុនោះទៅឱ្យតតិយជនផ្សេងទៀត ហើយមកធ្វើការក្លែងបន្លំថាជាការធ្វើឡើងដើម្បីបម្រើដល់ផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិបានឡើយ។ អស្សាមិករណ៍នេះអនុវត្តន៍ទៅបានលុះត្រាតែយកទៅអនុវត្តន៍គម្រោងក្នុងគោលដៅស្ថាបនា ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ បម្រើទៅដល់ផលប្រយោជន៍សាធារណៈ

---

[៤] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា៥។

[៥] គេហទំព័រ https://construction-property.com/km/pm-orders- ដកស្រង់នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣។

[៦] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា៧។

ផលប្រយោជន៍ជាតិ និងការអភិវឌ្ឍរបស់ព្រះរាជាណាចក្រកម្ពុជា។[៧] ដោយឡែកការដកហូតនូវសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុនេះត្រូវផ្តល់នូវសំណងលើការខូចខាតអចលនវត្ថុជាក់ស្តែង ក្នុងការទូទាត់ជាមុនដោយសមរម្យ និងយុត្តិធម៌ មិនតែប៉ុណ្ណោះសំណងត្រូវបានវាយតម្លៃទៅតាមតម្លៃមធ្យមទៅលើទីផ្សារអចលនវត្ថុ ដោយមិនគិតពីការប្រែប្រួលតម្លៃអ្វីឡើយ បន្ទាប់ពីសេចក្តីប្រកាស និងផលប៉ះពាល់នៃគម្រោងនេះ។ ជាក់ស្តែងការអនុវត្តអស្សាមិករណ៍ គួរគប្បីត្រួតពិនិត្យទៅលើអចលនវត្ថុឱ្យបានជាក់លាក់អំពីប្រភេទនៃអចលនវត្ថុដែលត្រូវយកមកធ្វើអស្សាមិករណ៍ ដោយរដ្ឋត្រូវគិតអំពីទំហំនៃការធ្វើ ក៏ដូចជាវាស់ចំណែកដែលនៅសេសសល់ពីការធ្វើនោះ ដោយមិនត្រូវទុកអចលនវត្ថុនោះចោលដោយមិនអើពើ ឬគ្មានហេតុផលសមស្របណាមួយបានឡើយ ចំពោះអចលវត្ថុដែលនៅសល់ត្រូវធ្វើការលក់ជូនទៅម្ចាស់អចលនវត្ថុនោះវិញ ក្នុងករណីប្រសិនបើម្ចាស់អចលនវត្ថុនោះមិនព្រមទទួលយកទេនោះត្រូវចាត់ទុកជាទ្រព្យសម្បត្តិរបស់រដ្ឋ។[៨] ដូច្នេះមុននឹងឈានទៅដល់ការអនុវត្តគម្រោងអស្សាមិករណ៍ រាជរដ្ឋាភិបាលចាំបាច់ត្រូវរៀបចំគណៈកម្មាធិការក្នុងការរៀបចំចាត់ចែង អង្កេតនិងត្រួតពិនិត្យទៅលើដំណាក់កាលនីមួយៗឱ្យសមស្របទៅតាមនីតិវិធីនៃច្បាប់។ គោលការណ៍នៃការធ្វើអស្សាមិករណ៍ មុននឹងដំណើរការនៃការធ្វើអស្សាមិករណ៍រាជរដ្ឋាភិបាលត្រូវគ្រោងថវិកាប្រចាំឆ្នាំឱ្យបានគ្រប់គ្រាន់ និងប្រាក់តណទានឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលាជូនទៅគណៈកម្មាធិការអស្សាមិករណ៍តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់យកទៅធ្វើការទូទាត់សំណងជូនម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិដែលរងនូវផលប៉ះពាល់ដោយសារការធ្វើអស្សាមិករណ៍។[៩]

មិនតែប៉ុណ្ណោះក៏មានករណីជាក់ស្តែងមួយចំនួនដែលគួរឱ្យកត់សម្គាល់ បានន័យថាមិនមែនរាល់ការធ្វើអស្សាមិករណ៍ទាំងអស់សុទ្ធសឹងតែជូនដំណឹងទៅម្ចាស់សិទ្ធិនៃអចលនវត្ថុនោះទេ ដោយឡែកអស្សាមិករណ៍ពិសេសក្នុងករណីដែលមានភាពបន្ទាន់ ទៅលើសុវត្ថិភាពតម្រូវដូចជាពាក់ព័ន្ធទៅនឹង (គ្រោះធម្មជាតិ ទឹកជំនន់ អគ្គីភ័យ ភ្លើងឆេះព្រៃ សង្គ្រាមដែលបម្រុងនឹងកើតឡើង ឬភេរវកម្ម និងស្ថានភាពផ្សេងៗជាអាទិ៍)។ ដែលអនុញ្ញាតឱ្យរដ្ឋធ្វើការដកហូតនូវអចលនវត្ថុនោះទាំងស្រុង ឬមួយផ្នែក ឬលើសិទ្ធិប្រត្យក្សនៃអចលនវត្ថុជាបណ្តោះអាសន្នដោយមិនចាំបាច់ធ្វើការពិគ្រោះយោបល់អ្វីឡើយ។ រាជរដ្ឋាភិបាលមិនមានការត្រៀមរៀបចំគម្រោង ការចាត់ចែង ការអង្កេត ឬបាយការណ៍ដែលពាក់ព័ន្ធទៅតាមដំណាក់កាលនោះទេ ហើយរាជរដ្ឋាភិបាលត្រូវប្រគល់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិវិញនៅពេលបញ្ចប់ការដកហូត ក្នុងករណីបន្ទាន់នឹងចាំបាច់បែបនេះត្រូវគិតភ្លាម ហើយរាជរដ្ឋាភិបាលធ្វើការអនុវត្តភ្លាមៗតែម្តង ដែលជាផលប្រយោជន៍ដល់សាធារណៈ និងប្រយោជន៍

[៧] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា១។

[៨] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា៩។

[៩] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា១១។

របស់ជាតិទាំងមូល ក្នុងរូបភាពដូចបានកំណត់ជាក់លាក់ខាងលើ គឺរាជរដ្ឋាភិបាលមានសិទ្ធិអំណាចសម្រេចក្នុងការធ្វើអស្សាមិករណ៍ជាករណីដាច់ដោយឡែកមិនចាំបាច់អនុវត្តន៍ស្របតាមនីតិវិធីនៃច្បាប់នោះទេ។[១០]

### ១.១.១.១. ប្រវត្តិនៃការធ្វើអស្សាមិករណ៍

ការធ្វើអស្សាមិករណ៍ គឺជាការដកហូតនូវរាល់កម្មសិទ្ធិលើអចលនវត្ថុ ឬសិទ្ធិប្រត្យក្សរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដើម្បីបម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍សង្គមជាតិ ព្រមទាំងផ្តល់នូវតម្លៃសមរម្យ និងយុត្តិធម៌ជូនទៅដល់ម្ចាស់កម្មសិទ្ធិ ហេតុដូច្នេះហើយទើបបង្កើតឱ្យមានការដកហូតនូវកម្មសិទ្ធិលើអចលនវត្ថុរបស់ប្រជាពលរដ្ឋជាបន្តបន្ទាប់។

- **មុនឆ្នាំ២០១០**

មានការប៉ាន់ប្រមាណថាការធ្វើអស្សាមិករណ៍គឺ មានការកកើតតាំងពីមុនច្បាប់ស្តីពីអស្សាមិករណ៍ក្នុងឆ្នាំ២០១០ មកម្ល៉េះ។ ហើយពុំមានឯកសារផ្លូវការណាមួយបានកំណត់សម្គាល់ជាក់លាក់អំពីដំណើរការនៃការធ្វើអស្សាមិករណ៍ ឬការគណនាសំណងច្បាស់លាស់ជូនម្ចាស់អចលនវត្ថុនៅឡើយទេ។ ដោយមិនទាន់ឃើញមានច្បាប់ ឬបទដ្ឋានគតិយុត្តណាមួយបានធ្វើការកំណត់ឱ្យមានភាពលំអិត និងគ្មានភាពស៊ីជម្រៅទេនាពេលនោះ។ យ៉ាងណាមិញ ច្បាប់ភូមិបាលបានកំណត់ត្រឹមតែជាសញ្ញាណចំពោះការធ្វើអស្សាមិករណ៍ប៉ុណ្ណោះ មិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយ ដូច្នេះហើយការអនុវត្តក៏មិនទាន់មានគោលការណ៍ ឬវិធានត្រឹមត្រូវនឹងយន្តការច្បាស់លាស់នៅឡើយដែរ។ ដោយឡែកចំពោះការអភិវឌ្ឍក៏នៅមិនទាន់មានភាពល្អប្រសើរ ពោលគឺទាមទារឱ្យមានការសាងសង់ច្រើន ដូចនេះហើយចាំបាច់ត្រូវការនូវនីតិវិធីច្បាប់ច្បាស់លាស់សម្រាប់ការអនុវត្តដើម្បីបង្ការនូវជម្លោះរវាងប្រជាពលរដ្ឋ និងម្ចាស់គម្រោងកាន់តែមានភាពរលូនបន្ថែមទៀត។

នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៧ សាលាក្រុងភ្នំពេញបានប្រកាសថាខ្លួនបានព្រមជួលតំបន់បឹងកក់ឱ្យទៅក្រុមហ៊ុនអភិវឌ្ឍន៍ឯកជន (Sharaku Inc.) សម្រាប់ការអភិវឌ្ឍលើផ្ទៃដីទំហំ១៣៣ហិចតា ដោយក្នុងនោះរួមមានផ្ទៃបឹង៩០ហិចតាផងដែរ។ ប្រជាពលរដ្ឋមានផលប៉ះពាល់ប្រមាណ៤២៥២គ្រួសាររស់នៅក្នុងសង្កាត់ស្រះចកនៃខណ្ឌដូនពេញ។ សាលាក្រុងរាជធានីភ្នំពេញបានផ្តល់សំណងជាទឹកប្រាក់ចំនួន៨៥០០ដុល្លារ បូកនឹងប្រាក់២លានរៀល បន្ថែមទៀតដល់គ្រួសារដែលបានស្ម័គ្រចិត្តចាកចេញពីតំបន់បឹងកក់នេះ។ ប៉ុន្តែការទូទាត់សំណងនៃផលប៉ះពាល់នាពេលនោះពុំមានការបញ្ជាក់ពីរដ្ឋាភិបាលថាយកមូលដ្ឋានណា និងលិខិតបទដ្ឋានគតិយុត្តណាសម្រាប់មកគណនាជូនប្រជាពលរដ្ឋនោះទេ។ ហើយការផ្តល់នូវសំណងជាទឹកប្រាក់នាពេលនោះហាក់បីដូចជាមិនទាន់គ្រប់គ្រាន់សម្រាប់សំណងដែលល្អប្រសើរនោះឡើយ បានន័យថាប្រជាពលរដ្ឋទទួល

[១០] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា១០។

បានសំណងដែលមានលក្ខណៈមិនសមរម្យ ពីព្រោះទឹកប្រាក់ដែលបានផ្ដល់មកនោះមានចំនួនតិចតួចពេក ចំពោះគ្រួសារដែលទទួលរងនូវផលប៉ះពាល់ (ការគណនាតម្លៃនៃសំណងទាបជាងតម្លៃទីផ្សារ)។

- **ឆ្នាំ២០១០ ដល់ ២០២៣**

ក្រោយពីមានការបង្កើតច្បាប់អស្សាមិករណ៍រួចមក យើងសង្កេតឃើញថាប្រទេសកម្ពុជាកាន់តែមានភាពរីកចម្រើនខ្លាំងលើគ្រប់វិស័យគមនាគមន៍ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធសាធារណៈប្រទេសកម្ពុជាមានសន្ទុះលើការអភិវឌ្ឍគួរជាទីកត់សម្គាល់។ ហើយអាចដោះស្រាយនូវរាល់បញ្ហាទំនាស់ដែលកើតមានឡើងនៅពេលដែលប្រជាពលរដ្ឋរឹងរូសមិនព្រមសហការណ៍ ឬផ្ទេរនូវអចលនវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន ស្របពេលដែលជាតម្រូវការយ៉ាងចាំបាច់ចំពោះគម្រោងសម្រាប់ការរុះរើដើម្បីសាងសង់នានា។ ស្របតាមនីតិវិធីនៃច្បាប់ស្ដីពីអស្សាមិករណ៍បានកំណត់មានភាពច្បាស់លាស់ទៅលើគម្រោងដែលត្រូវអភិវឌ្ឍន៍ ដូច្នេះទាំងម្ចាស់កម្មសិទ្ធិករនៃអចលនវត្ថុទាំងម្ចាស់គម្រោងមានភាពងាយស្រួលនៅក្នុងកិច្ចដំណើរការអស្សាមិករណ៍ ហើយប្រជាពលរដ្ឋក៏អាចទទួលបាននូវសំណងយ៉ាងសមរម្យ និងយុត្តិធម៌ផងដែរ។

រាជរដ្ឋាភិបាលមានការយកចិត្តទុកដាក់យ៉ាងខ្លាំងដោយបានដកយកស្ថានីយប្រេងឥន្ធនៈសូគីម៉ិចនៅចំណុចច្រមុះជ្រូកក្បាលថ្នល់ចេញ ដើម្បីឱ្យមានភាពល្អប្រសើរលើបញ្ហាចរាចរណ៍នៅចំណុចផ្លូវនេះខណៈដែលផ្លូវមានការកកស្ទះជារៀងរាល់ថ្ងៃ។ ដើម្បីដោះស្រាយនូវបញ្ហាចរាចរណ៍នៅច្រមុះជ្រូកក្បាលថ្នល់ ក្នុងគោលដៅកែលំអនៅប្រព័ន្ធចរាចរណ៍ និងសម្រួលដល់ការកកស្ទះចរាចរណ៍នៅតំបន់នេះ។ ក្រោយពីការដកហូតស្ថានីយប្រេងឥន្ធនៈចេញពីចំណុចនេះរួចមកឃើញថាការកាត់បន្ថយការកកស្ទះដោះស្រាយបាន៥០%ប៉ុណ្ណោះ។ ដោយឃើញថាការកកស្ទះចរាចរណ៍នៅតែជាបញ្ហាប្រឈមដែលពុំទាន់មានការដោះស្រាយឱ្យមានលក្ខណៈល្អប្រសើរនូវឡើយនោះ។ រដ្ឋបាលរាជធានីភ្នំពេញក៏បានបង្កើតជាគម្រោងថ្មីមួយទៀត គឺការស្ថាបនាស្ពានអាកាសថ្មីមួយនៅផ្លូវបំបែកក្បាលថ្នល់ (ផ្លូវច្រមុះជ្រូកក្បាលថ្នល់) នេះតែម្ដង។ ហើយការដកហូត និងការរុះរើនៅតំបន់នេះរាជរដ្ឋាភិបាលបានផ្ដល់សំណងជូនដល់ម្ចាស់អចលនវត្ថុយ៉ាងសមរម្យ និងយុត្តិធម៌។

### ១.១.១.២. យន្តការអនុវត្តអស្សាមិករណ៍

ជាទូទៅរាល់ការអភិវឌ្ឍនូវគម្រោងណាមួយនៃព្រះរាជាណាចក្រកម្ពុជា គឺសុទ្ធសឹងតែមានការគ្រោងទុកជាមុនសិន ទើបអាចឈានទៅដល់ការអនុវត្តបន្តបន្ទាប់ដើម្បីទទួលបាននូវប្រសិទ្ធភាពខ្ពស់រាល់គម្រោងនៃការអភិវឌ្ឍនីមួយៗចាំបាច់ត្រូវការអ្នកគ្រប់គ្រងទៅតាមស្ថានការនៃគម្រោងទាំងអស់នោះ ដើម្បីបញ្ចៀសនូវបញ្ហាប្រឈមដែលនឹងអាចកើតមានឡើងដោយប្រការណាមួយក្នុងអំឡុងពេលអនុវត្តន៍។ ហេតុដូច្នេះហើយទើបយើងឃើញមាននូវគណៈកម្មាធិការមួយរូបយ៉ាងតិចនៅក្នុងការអនុវត្តគម្រោង ដើម្បីឱ្យគណៈកម្មាធិការមានការទទួលខុសត្រូវចំពោះគម្រោងដែលខ្លួនបានត្រួតពិនិត្យ។ ដោយឡែកការធ្វើអស្សាមិករណ៍ក៏ដូច្នេះដែរ

ដាច់ខាតគឺត្រូវមានអ្នកគ្រប់គ្រង និងចាត់ចែងច្បាស់លាស់មុននឹងឆ្ពោះទៅរកការអនុវត្តនៃអស្សាមិករណ៍ ចំពោះអ្នកដែលដឹកនាំត្រួតពិនិត្យនៅក្នុងគម្រោង និងការដកហូតអចលនវត្ថុនានានោះគឺរួមមានដូចជា គណៈកម្មាធិការអស្សាមិករណ៍ដែលត្រូវបានកំណត់ដោយអនុក្រឹត្យ ហើយបង្កើតឡើង និងដឹកនាំដោយតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានតំណាងក្រសួងស្ថាប័នពាក់ព័ន្ធចូលរួម [១១] អនុកម្មាធិការអស្សាមិករណ៍ដែលជាសេនាធិការនៃគណៈកម្មាធិការអស្សាមិករណ៍ត្រូវបានបង្កើតឡើង និងដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងមានតំណាងមន្ទីរជំនាញ អាជ្ញាធរពាក់ព័ន្ធចូលរួមហើយត្រូវបានកំណត់ដោយអនុក្រឹត្យ [១២] គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាត្រូវបានបង្កើតនឹងដឹកនាំដោយតំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងមានតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួម ហើយត្រូវបានកំណត់ដោយអនុក្រឹត្យដាច់ដោយឡែក[១៣] ការចាត់តាំងបែបនេះក្នុងគោលបំណងដើម្បីគ្រប់គ្រង និងស្វែករកដំណោះស្រាយនានា ដែលកើតឡើងចំពោះវិវាទដែលទាក់ទងទៅនឹងការធ្វើអស្សាមិករណ៍ដែលបង្កើតឡើងនោះ។ តួយ៉ាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើរតួយ៉ាងសំខាន់ក្នុងការទូទាត់សំណងដោយសមរម្យ និងយុត្តិធម៌ជូនដល់ប្រជាពលរដ្ឋដែលជាម្ចាស់សិទ្ធិលើអចលនវត្ថុដែលទទួលរងនូវផលប៉ះពាល់ពីការធ្វើអស្សាមិករណ៍។

### ១.១.២. គោលបំណង និងសារៈប្រយោជន៍នៃការធ្វើអស្សាមិករណ៍

ច្បាប់ស្តីពីអស្សាមិករណ៍នៅក្នុងឆ្នាំ២០១០បានចែងអំពីគោលការណ៍ យន្តការ នីតិវិធី និងការដកហូតកម្មសិទ្ធិ ព្រមទាំងឱ្យនិយមន័យអំពីការផ្តល់សំណងត្រឹមត្រូវ និងយុត្តិធម៌សម្រាប់ម្ចាស់សិទ្ធិលើអចលនវត្ថុរាល់គម្រោង សាងសង់ ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈសម្រាប់ជាផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ និងការអភិវឌ្ឍកម្ពុជា។ ផ្ទុយទៅវិញច្បាប់ស្តីពីអស្សាមិករណ៍ពុំមានចែងយ៉ាងពិស្តារអំពីកិច្ចដំណើរការ និងនីតិវិធីនៃការតាំងទីលំនៅថ្មីឡើងវិញ ដែលបង្កដោយគម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈព្រមទាំងការធ្វើលទ្ធកម្មដីធ្លី ការផ្តល់ដីធ្លីនិងទ្រព្យសម្បត្តិជាអំណោយ និងការគាំទ្រនៅក្រោយការផ្លាស់ប្តូរទីលំនៅឡើយ។[១៤] ច្បាប់អស្សាមិករណ៍នេះផ្តោតលើការយកចិត្តទុកដាក់ទាំងស្រុងលើតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ ក៏ដូចជាប្រទេសជាតិទាំងមូលជាពិសេសពាក់ព័ន្ធជាមួយនឹងការដកហូតអចលនវត្ថុពីម្ចាស់សិទ្ធិក្នុងការយកទៅ អនុវត្តន៍គម្រោងដែលបានគ្រោងទុកជាប្រយោជន៍សាធារណៈនិងប្រយោជន៍របស់ជាតិ។ មិនតែប៉ុណ្ណោះច្បាប់នេះដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនលទ្ធភាពរបស់គម្រោងឱ្យកាន់តែមានប្រសិទ្ធិភាពខ្ពស់ក្នុង

[១១] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/00៣, ២៦ កុម្ភៈ ២០១០, មាត្រា១២។

[១២] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/00៣, ២៦ កុម្ភៈ ២០១០, មាត្រា១៣។

[១៣] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/00៣, ២៦ កុម្ភៈ ២០១០, មាត្រា១៤។

[១៤] គេហទំព័រ https://documents1.worldbank.org/curated/es/ ចូលមើលថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣។

ការសម្រេចនូវគោលដៅពាក់ព័ន្ធទៅនឹងការអនុវត្ត ហើយច្បាប់នេះបានបន្ថែមនូវភាពច្បាស់លាស់ ការផ្តល់នូវបច្ចេកទេសបន្ថែម ព្រមទាំងមានការផ្តល់ជាអនុសាសន៍អនុវត្តន៍ល្អៗលើការអនុវត្តសម្រាប់ឱ្យប្រជាពលរដ្ឋមានការយល់ដឹងនូវសិទ្ធិរបស់ខ្លួននៅពេលដែលខ្លួនទទួលរងនូវផលប៉ះពាល់ចំពោះគម្រោងនានា។ ហេតុដូចនេះ ច្បាប់ស្តីពីអស្សាមិករណ៍មានគោលបំណង និងសារៈប្រយោជន៍ដូចតទៅ៖

**១.១.២.១. គោលបំណង**

ច្បាប់នេះមានគោលបំណងធានាទៅដល់ការដកហូតនូវសិទ្ធិកម្មសិទ្ធិស្របច្បាប់របស់បុគ្គលដែលជាម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ អ្នកអនុវត្តន៍ត្រូវប្រកាន់ខ្ជាប់នូវតម្លាភាព សុចរិតភាព យុត្តិធម៌ ភាពត្រឹមត្រូវប្រកបដោយសុក្រឹតភាព ដោយមិនត្រូវមានបំណងទុច្ចរិតដោយប្រការណាមួយឡើយ។ មុនពេលយកដីរបស់ម្ចាស់អចលនវត្ថុទៅអនុវត្តន៍គម្រោងណាមួយនោះ រាជរដ្ឋាភិបាលត្រូវផ្តល់នូវសំណងហើយធានាឱ្យបាននូវការទូទាត់សំណងដល់ម្ចាស់ទ្រព្យ និង/ឬ ម្ចាស់សិទ្ធិនានា រួមទាំងប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់អវិជ្ជមានដោយសារគម្រោងអភិវឌ្ឍន៍នោះជាមុនឱ្យគ្រប់ចំនួនស្របតាមនីតិវិធីតាមរយៈការព្រមព្រៀង ដែលបានគណនាទៅតាមតម្លៃទីផ្សារសំណងត្រូវទូទាត់ជាសាច់ប្រាក់ ជាទ្រព្យ ឬជាសិទ្ធិជំនួសទៅតាមស្ថានភាពជាក់ស្តែង ហើយសំណងទាំងនោះត្រូវតែថ្លឹងថ្លែងឱ្យមានលក្ខណៈសមរម្យ ឥតលំអៀង មានសមភាពរវាងប្រជាពលរដ្ឋ និងអ្នកអនុវត្តន៍គម្រោង។ តែទោះបីជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍធ្វើឡើងតាមរយៈការធ្វើអស្សាមិករណ៍នូវទ្រព្យសម្បត្តិឯកជនមួយផ្នែក និងផ្នែកខ្លះទៀតធ្វើឡើងតាមរយៈអចលនវត្ថុសាធារណៈរបស់រដ្ឋផងដែរ ប៉ុន្តែការដែលយកអចលនវត្ថុរបស់ប្រជាពលរដ្ឋមកធ្វើជាទ្រព្យសម្បត្តិឯកជន និងទ្រព្យសម្បត្តិរបស់រដ្ឋផ្ទាល់គឺក្នុងគោលបំណងចម្បងដើម្បីបម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍របស់ជាតិជាធំ រដ្ឋត្រូវអនុវត្តន៍នូវសិទ្ធិអំណាចរបស់ខ្លួននៃការធ្វើអស្សាមិករណ៍ដោយបានដកហូតដី និងទ្រព្យសម្បត្តិនានាដែលជាតម្រូវការសម្រាប់គម្រោងឆ្ពោះទៅរកការអភិវឌ្ឍដោយផ្អែកតាមច្បាប់អស្សាមិករណ៍។ ច្បាប់នេះទៀតសោត បានចូលរួមចំណែកនូវក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈសម្រាប់ជាប្រយោជន៍រួមរបស់ជនរួមជាតិទាំងមូល។

**១.១.២.២. សារៈប្រយោជន៍**

**ក. សារៈប្រយោជន៍ខាងនីតិវិធី**

សព្វថ្ងៃនេះយើងតែងតែសង្កេតឃើញថាមានការដកហូតដីធ្លីរបស់ប្រជាពលរដ្ឋពីសំណាក់រដ្ឋកើតមានជាហូរហែ។ បើទោះបីជាមានការបង្កើតច្បាប់ទប់ស្កាត់បញ្ហាដីធ្លីយ៉ាងណាក៏ដោយ ក៏នៅតែកើតមានបញ្ហាដីធ្លីយ៉ាងផុសផុលក្នុងសង្គមឥតឈប់ឈរ។ យ៉ាងណាមិញរាល់ការដកហូតទាំងអស់នេះគឺធ្វើឡើងដើម្បីស្តារ និងពង្រីកការអភិវឌ្ឍគ្រប់ទីកន្លែងក៏ដូចជាបណ្តុះផ្នែកហេដ្ឋារចនាសម្ព័ន្ធឱ្យកាន់តែមានសន្ទុះខ្លាំងបន្ថែមទៀតផងដែរ។ ហេតុដូច្នេះហើយដើម្បីឱ្យការដកហូតអចលនវត្ថុរបស់ប្រជាពលរដ្ឋឱ្យកាន់តែមានសមភាព តម្លាភាពសុក្រឹត

និងយុត្តិធម៌ទៅបានយ៉ាងរលូន គណៈកម្មាធិការអស្សាមិករណ៍ត្រូវគោរពនូវគោលការណ៍នៃនីតិវិធីអស្សាមិករណ៍ជាកំហិត ដែលមានបញ្ញត្តិនៅក្នុងច្បាប់ស្តីពីអស្សាមិករណ៍ជៀសវាងមានការរាំងស្ទះដោយប្រការណាមួយ ដែលអាចបង្កប់នូវភាពអយុត្តិធម៌ និងអាចទប់ស្កាត់ការបង្កជាចលាចលក្នុងកិច្ចដំណើរការនៃការអនុវត្តគម្រោងទាំងនោះ។ ច្បាប់ស្តីពីអស្សាមិករណ៍ក៏បានចែងយ៉ាងលំអិតនូវនីតិវិធី និងដំណាក់កាលដ៏សំខាន់ៗជាច្រើនសម្រាប់ការសាងសង់គម្រោងនានាផងដែរ។

**ខ. សារៈប្រយោជន៍ខាងសំណង**

ជាជំហានបន្ទាប់ក្រោយពីបានឆ្លងកាត់នូវដំណាក់កាលនីតិវិធីជាច្រើនហូរហែរួចមក នោះនឹងឈានដល់ដំណាក់កាល នៃការផ្តល់នូវសំណងជូនដល់ម្ចាស់អចលនវត្ថុដែលទទួលរងនូវផលប៉ះពាល់ដោយសារគម្រោងសាងសង់របស់រដ្ឋ។ ដំណាក់កាលនេះ គឺជាដំណាក់កាលយ៉ាងសំខាន់មួយក្នុងចំណោមដំណាក់កាលផ្សេងៗទៀតមិនត្រឹមតែមានភាពយុត្តិធម៌ប៉ុណ្ណោះទេ តែថែមទាំងជាផ្នែកមួយយ៉ាងសំខាន់សម្រាប់បង្ការកុំឱ្យមានជម្លោះរវាងប្រជាពលរដ្ឋ ជាមួយនឹងរដ្ឋទៀតផងដែរ។ ជាទូទៅមុនឈានទៅរកការអនុវត្តគម្រោងនោះបាន លុះត្រាតែម្ចាស់កម្មសិទ្ធិលើអចលនវត្ថុធ្វើការរុះរើចាកចេញពីទីតាំងជាមុនសិន ដើម្បីធ្វើការប្រគល់អចលនវត្ថុនោះជូនទៅគណៈកម្មាធិការអស្សាមិករណ៍អនុវត្តន៍។ ប៉ុន្តែដើម្បីឱ្យការរុះរើមានប្រសិទ្ធិភាពខ្ពស់នោះ រាជរដ្ឋាភិបាលត្រូវផ្តល់នូវសំណងលើការខូចខាតអចលនវត្ថុជាក់ស្តែងដោយសមរម្យ និងយុត្តិធម៌ ជូនដល់ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិដែលទទួលរងដោយការធ្វើអស្សាមិករណ៍នោះជាមុន ទើបការអនុវត្តប្រកបដោយចីរភាព។[១៥] សំណងនេះទៀតសោតត្រូវបានកំណត់ និងវាយតម្លៃដោយអាជ្ញាធរមានសមត្ថកិច្ច ហើយការកំណត់បែបនេះមាននៅក្នុងច្បាប់អស្សាមិករណ៍ រួចជាស្រេច ក្នុងការផ្តល់សំណងដែលច្បាប់បានថ្លឹងថ្លែងថាមានភាពសមរម្យហើយនោះសម្រាប់ការផ្គត់ផ្គង់ដល់បុគ្គលដែលទទួលរងផលប៉ះពាល់នានា។[១៦]

**គ. សារៈប្រយោជន៍ខាងដោះស្រាយទំនាស់**

ក្រោយពីរាជរដ្ឋាភិបាលបានគណនាសំណងរួចសព្វគ្រប់អស់ហើយ ប្រជាពលរដ្ឋនៅតែមិនពេញចិត្តនូវសំណងដែលរដ្ឋបានផ្តល់ឱ្យ ហើយម្ចាស់អចលនវត្ថុយល់ឃើញថាការទូទាត់របស់រដ្ឋមិនគ្រប់ចំនួនតាមស្ថានភាពជាក់ស្តែងដែលបានធ្វើការគណនា ឬការប្រព្រឹត្តទៅរបស់រាជរដ្ឋាភិបាលមិនមានភាពត្រឹមត្រូវស្របតាមនីតិវិធីនៃច្បាប់អស្សាមិករណ៍ ដោយរាល់ការដកហូតអចលនវត្ថុនៅតំបន់នោះមិនយកទៅបម្រើប្រយោជន៍រួមរបស់ជាតិម្ចាស់កម្មសិទ្ធិលើអចនលវត្ថុមានសិទ្ធិប្រើប្រាស់នូវសិទ្ធិ និងករណីកិច្ចរបស់ខ្លួនតាំងនាមជាម្ចាស់សិទ្ធិ។ ពោលគឺប្រសិនបើម្ចាស់សិទ្ធិមិនយល់ស្របទៅនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការអស្សាមិករណ៍ទេនោះអាចដាក់

[១៥] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា២៣។

[១៦] ច្បាប់ស្តីពីអស្សាមិករណ៍ឆ្នាំ២០១០, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា២២ វាក្យខណ្ឌទី២។

ពាក្យបណ្តឹងទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាបាន ប៉ុន្តែបើនៅតែមិនទទួលបាននូវលទ្ធផលដែលជាតម្រូវការរបស់ខ្លួនទៀតនោះម្ចាស់កម្មសិទ្ធិអាចប្តឹងទៅតុលាការមានសមត្ថកិច្ចបន្តទៀតបាន។

## **១.២. លក្ខខណ្ឌនៃការធ្វើអស្សាមិករណ៍**

ជាទូទៅការធ្វើអស្សាមិករណ៍ គឺជាការដកហូតនូវទ្រព្យសម្បត្តិឯកជនរបស់បុគ្គលឯកជនយកមកបម្រើជាផលប្រយោជន៍សាធារណៈរបស់រាជរដ្ឋាភិបាល ដែលជាហេតុបណ្តាលឱ្យប៉ះពាល់ដល់ការកាន់កាប់កម្មសិទ្ធិលើអចលនវត្ថុរបស់បុគ្គលដែលជាម្ចាស់ទ្រព្យទាំងអស់នោះ។ ដើម្បីឱ្យការអភិវឌ្ឍប្រព្រឹត្តទៅដោយរលូនក៏ដូចជាជៀសវាងនូវរាល់បញ្ហា និងជម្លោះរវាងបុគ្គលឯកជនជាមួយនឹងអាជ្ញាធរសាធារណៈនោះ ត្រូវពិនិត្យឱ្យល់អិតទៅលើដែនសមត្ថកិច្ចនៃការធ្វើអស្សាមិករណ៍ឱ្យមានលក្ខណៈច្បាស់លាស់ ចំពោះបុគ្គលដែលគួរធ្វើអស្សាមិករណ៍ និងទ្រព្យដែលអាចធ្វើអស្សាមិករណ៍បាន។

### **១.២.១. បុគ្គលដែលធ្វើអស្សាមិករណ៍**

ស្របតាមការវិវត្តនៃស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយបានប្រែក្លាយច្បាប់អស្សាមិករណ៍ក្នុងការប្រើប្រាស់ដើម្បីដកហូតកម្មសិទ្ធិស្របច្បាប់របស់បុគ្គលឯកជន យកមកបម្រើជាប្រយោជន៍សាធារណៈដោយត្រូវផ្ទេរនូវកម្មសិទ្ធិនោះពីបុគ្គលឯកជនមកជាការស្ថាបនា ស្តារ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធវិញហើយយកទស្សទាននៃការបម្រើផលប្រយោជន៍សាធារណៈមកធ្វើជាគោលការណ៍ក្នុងកិច្ចដំណើរការអស្សាមិករណ៍។ ក្នុងនោះផងដែរ ចំពោះបុគ្គលដែលអាចធ្វើអស្សាមិករណ៍បានលុះត្រាតែបុគ្គលនោះបានទទួលនូវសិទ្ធិអំណាចក្នុងការអនុវត្តអស្សាមិករណ៍ដើម្បីបញ្ចៀសនូវការបំពានជាដើម។ ដោយឡែក ចំពោះបុគ្គលដែលមានសមត្ថកិច្ចក្នុងការធ្វើអស្សាមិករណ៍នោះរួមមាន នីតិបុគ្គលសាធារណៈ និងនីតិបុគ្គលឯកជន។

#### **១.២.១.១. បុគ្គលសាធារណៈ**

ការធ្វើអស្សាមិករណ៍ គឺជាបុព្វសិទ្ធិនៃអំណាចសាធារណៈហេតុនេះបុគ្គលដែលពាក់ព័ន្ធក្នុងការធ្វើអស្សាមិករណ៍ត្រូវបានប្រគល់ទៅឱ្យបុគ្គលសាធារណៈ។ ម្យ៉ាងវិញទៀតនៅក្នុងច្បាប់ស្តីពីអស្សាមិករណ៍បានកំណត់ថាមានតែរដ្ឋទេដែលជាអ្នកធ្វើអស្សាមិករណ៍ ដើម្បីប្រើប្រាស់ក្នុងគោលដៅជាផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ។[១៧] ដោយឡែកមាត្រា៤ នៃច្បាប់ស្តីពីអស្សាមិករណ៍ក៏បានកំណត់ដែរថាអ្នកអនុវត្តន៍គម្រោងសំដៅដល់រដ្ឋ សហគ្រាស និងគ្រឹះស្ថានសាធារណៈ អ្នកម៉ៅការ ឬវិនិយោគិន ក៏មានសិទ្ធិចូលរួមក្នុងការអនុវត្តអស្សាមិករណ៍ដែរ។

- **សហគ្រាសសាធារណៈ** គឺជាយន្តការផ្តល់នូវសេវាសាធារណៈរបស់រដ្ឋដែលស្ថិតនៅក្រោមការគ្រប់គ្រង

[១៧] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា៧ វាក្យខណ្ឌទី១។

នៃនីតិឯកជន និងនីតិសាធារណៈ ព្រមទាំងជានីតិបុគ្គលដែលមានស្វ័យភាពហិរញ្ញវត្ថុ ហើយដែលមានដើមទុនទាំងអស់ ឬភាគច្រើនជារបស់រដ្ឋហេតុនេះសហគ្រាសអាចដឹកនាំដោយផ្ទាល់ ឬដោយប្រយោលពីសំណាក់រដ្ឋ។ សហគ្រាសសាធារណៈមានបេសកកម្មបង្កលក្ខណៈដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាអាទិ៍។ សហគ្រាសសាធារណៈត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងស្ថាប័ន ឬអាជ្ញាធរសាធារណៈណាមួយអាស្រ័យលើប្រភេទនៃសកម្មភាពរបស់សហគ្រាសនោះ។ សហគ្រាសសាធារណៈក៏មានលទ្ធភាពអាចធ្វើអស្សាមិករណ៍បានផងដែរ។

**<u>ឧទាហរណ៍</u>** ដូចជាសហគ្រាសសាធារណៈដែលផ្តល់សេវាខាងផ្នែកទូរគមនាគមន៍ក៏មានសិទ្ធិក្នុងការធ្វើអស្សាមិករណ៍បានដែរ។

❖ **គ្រឹះស្ថានសាធារណៈ** គឺជាយន្តការនៃការផ្តល់នូវសេវាសាធារណៈដែលមានស្វ័យភាពខាងហិរញ្ញវត្ថុ ឬរដ្ឋបាលដែលជានីតិបុគ្គលនៃនីតិសាធារណៈដែលទទួលបន្ទុកខាងផ្នែកសេវាសាធារណៈ។ គ្រឹះស្ថានសាធារណៈបង្កើតឡើងមានស្វ័យភាពរបស់ខ្លួនឯង តែមិនបានន័យថាមានឯករាជ្យនោះទេ ផ្ទុយទៅវិញគ្រឹះស្ថានសាធារណៈត្រូវតែភ្ជាប់ខ្លួនទៅនឹងរដ្ឋសមូហភាពដែនដីជានិច្ច។ គ្រឹះស្ថានសាធារណៈ ក៏ដើរតួនាទីយ៉ាងសំខាន់ដោយមានសមត្ថកិច្ចធ្វើអស្សាមិករណ៍សម្រាប់ផលប្រយោជន៍សាធារណៈផងដែរ ពីព្រោះតែរដ្ឋពុំមានលទ្ធភាពក្នុងការធ្វើអស្សាមិករណ៍បានគ្រប់គ្រាន់ ហេតុនេះទើបគ្រឹះស្ថានសាធារណៈមានលទ្ធភាពក្នុងការធ្វើអស្សាមិករណ៍ ព្រមទាំងអនុវត្តន៍បានយ៉ាងល្អចំពោះអស្សាមិករណ៍ពីព្រោះយើងមានគណៈកម្មាធិការអស្សាមិករណ៍គ្រប់គ្រងដោយច្បាប់ និងបទបញ្ញត្តិផ្សេងៗទៀត។ ក៏ប៉ុន្តែជាគោលការណ៍ គ្រឹះស្ថានសាធារណៈអាចធ្វើអស្សាមិករណ៍បានតែក្នុងគោលដៅទាក់ទងទៅនឹងជំនាញឯកទេសរបស់ខ្លួនតែប៉ុណ្ណោះ។

**<u>ឧទាហរណ៍</u>** អាជ្ញាធរជាតិអប្សរាដែលជាគ្រឹះស្ថានសាធារណៈមានលក្ខណៈវប្បធម៌ និងមានបេសកកម្មគិតគូរដឹកនាំការងាររៀបចំ និងអភិវឌ្ឍន៍ទេសចរណ៍នៃតំបន់សៀមរាបអង្គរដែលបានស្នើសុំធ្វើផ្លូវមួយនៅក្នុងខេត្តសៀមរាបឆ្ពោះទៅកាន់ប្រាសាទអង្គរវត្ត។

ដោយឡែកមិនមែនរាល់គ្រឹះស្ថានសាធារណៈទាំងអស់សុទ្ធសឹងតែមានលទ្ធភាពអាចធ្វើអស្សាមិករណ៍បាននោះទេ ពោលគឺត្រូវដឹកនាំដោយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតំណាងក្រសួងស្ថាប័នពាក់ព័ន្ធចូលរួម[១៨] ចំណែកឯ អនុគណៈកម្មាធិការជាសេនាធិការនៃគណៈកម្មាធិការអស្សាមិករណ៍ត្រូវបានបង្កើតឡើង និងដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងមានតំណាងដោយមន្ទីរជំនាញ អាជ្ញាធរពាក់ព័ន្ធ

[១៨] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា១២។

ចូលរួម។[១៩] មិនតែប៉ុណ្ណោះគណៈអភិបាលរាជធានី ខេត្តក៏មានសិទ្ធិសម្រេចធ្វើគម្រោងអស្សាមិករណ៍បានផងដែរ ប្រសិនបើគម្រោងដែលបានធ្វើឡើងមកនោះវាស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ជាមួយគ្នានេះផងដែរ គណៈអភិបាល រាជធានី ខេត្តបានសម្រេចធ្វើការកំណត់នូវសមាសភាពនៃបុគ្គលសាធារណៈដែលអាចអនុវត្តន៍សមត្ថកិច្ចនេះបាន ហើយចំពោះការប្រគល់ឱ្យនេះសម្រាប់តែគម្រោងណាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួននឹងពុំមានលក្ខណៈសំខាន់ ហើយមិនចាំបាច់ប្រើប្រាស់នូវថវិកាច្រើននោះទេ ទាំងនេះបណ្តាលមកពីប្រទេសកម្ពុជាប្រកាន់ភ្ជាប់នូវប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ។

### ១.២.១.២. បុគ្គលឯកជន

នៅក្នុងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តណាមួយពុំបានចែងយ៉ាងលំអិតអំពីសមត្ថកិច្ចនៃការចូលរួមធ្វើអស្សាមិករណ៍នោះឡើយ ដោយឡែកច្បាប់ស្តីពីអស្សាមិករណ៍គ្រាន់តែបង្ហាញថាបុគ្គលឯកជនក៏មានសិទ្ធិអំណាចនៅក្នុងការធ្វើអស្សាមិករណ៍ក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈផងដែរ ក៏ប៉ុន្តែមិនបានកំណត់អំពីសមត្ថកិច្ចនៃការធ្វើអស្សាមិករណ៍ឱ្យបានច្បាស់លាស់នោះទេ។ ជាក់ស្តែងសព្វថ្ងៃយើងសង្កេតឃើញថាបុគ្គលឯកជនក៏មានលទ្ធភាពនៅក្នុងការចូលរួមចំណែកធ្វើអស្សាមិករណ៍បានដែរ ពីព្រោះរដ្ឋបានផ្តល់សិទ្ធិទៅឱ្យបុគ្គលឯកជន ដែលបុគ្គលឯកជនមានទំនាក់ទំនងជាមួយសេវាសាធារណៈ ហើយបុគ្គលឯកជនត្រូវបានចាត់ទុកថាធ្វើដើម្បីផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍របស់ជាតិ។

**ឧទាហរណ៍** អ្នកវិនិយោគិនបានធ្វើការវិនិយោគទុនជាមួយប្រទេសកម្ពុជា ទៅលើការបង្កើតនូវទំនប់វារីអគ្គីសនី ដើម្បីបម្រើដល់ផលប្រយោជន៍សាធារណៈ នៅក្នុងករណីនេះបុគ្គលឯកជនបានសម្រេចផ្តើមដំណើរការកិច្ចអស្សាមិករណ៍ដើម្បីអាចសម្រួលដល់ការវិនិយោគ។

ជារួមមកទាំងបុគ្គលសាធារណៈ និងបុគ្គលឯកជនសុទ្ធតែមានសមត្ថកិច្ចនៅក្នុងការធ្វើអស្សាមិករណ៍ ប៉ុន្តែ លុះត្រាតែមានការផ្តល់នូវសិទ្ធិអំណាចក្នុងការអនុវត្តសមត្ថកិច្ចទាំងនោះជាមុនសិន ហើយការអនុវត្តច្បាប់អស្សាមិករណ៍នេះក៏ត្រូវតែស្របទៅនឹងផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍របស់ជាតិតម្រូវ។

## ១.២.២. ទ្រព្យដែលអាចធ្វើអស្សាមិករណ៍

ជាគោលការណ៍អស្សាមិករណ៍ គឺជាការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុរបស់រូបវន្តបុគ្គល និងនីតិបុគ្គលសាធារណៈ ដែលការដកហូតនេះធ្វើទៅលើអចលនវត្ថុមួយផ្នែក ឬទាំងស្រុង ឬលើសិទ្ធិប្រត្យក្សនៃអចលនវត្ថុ។[២០] ទ្រព្យដែលអាចធ្វើអស្សាមិករណ៍សំដៅលើអចលនវត្ថុមានដូចជា ដីសំណង់ អគារ ផ្ទះ។ល។ ដោយឡែកអចលនវត្ថុមួយចំនួនក៏អាចធ្វើអស្សាមិករណ៍បានដែរ។ ប្រសិនបើអចលនវត្ថុនោះ

[១៩] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា១៣។

[២០] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០,មាត្រា៦។

ស្ថិតនៅកន្លែងដែលរដ្ឋត្រូវការអភិវឌ្ឍដើម្បីប្រយោជន៍សាធារណៈរដ្ឋអាចធ្វើការដោះដូរអចលនវត្ថុដោយសងជាសំណងយ៉ាងសមរម្យ ព្រមទាំងផ្តល់នូវភាពយុត្តិធម៌។ អចលនវត្ថុទាំងនោះរួមមានដូចជា អចលនវត្ថុនៃបុគ្គលសាធារណៈ និងអចលនវត្ថុនៃបុគ្គលឯកជន។

**១.២.២.១. អចលនវត្ថុនៃបុគ្គលសាធារណៈ**

អចលនវត្ថុនៃបុគ្គលសាធារណៈ សំដៅទៅលើដីទាំងអស់ដែលជារបស់រដ្ឋ ហើយដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ឬស្ថាប័នថ្នាក់ជាតិ និងដីដែលត្រូវបានប្រគល់ឱ្យនីតិបុគ្គលសាធារណៈដែលបានទទួលស្គាល់ដោយច្បាប់ថា ជានីតិបុគ្គលដើម្បីកាន់កាប់។[២១] ដីរបស់រដ្ឋរួមមានដូចជា ដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ។

❖ ដីសាធារណៈរបស់រដ្ឋ សំដៅលើដីដែលមានជាប់ផលប្រយោជន៍សាធារណៈ និងឋិតនៅក្នុងប្រភេទជាក់លាក់នៃទ្រព្យដែលមានផលប្រយោជន៍សាធារណៈដូចខាងក្រោម៖

**ក. ទ្រព្យទាំងឡាយដែលបង្ហាញការកើតឡើងពីធម្មជាតិ**

ចំពោះ ទ្រព្យទាំងឡាយដែលបង្ហាញការកើតឡើងពីធម្មជាតិដូចជា៖

១. ព្រៃឈើ

២. ផ្លូវទឹកដែលនាវា ឬក្បូនអាចចូលបាន បណ្តែតបាន

៣. បឹងធម្មជាតិ

៤. ច្រាំងទន្លេដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន

៥. ត្រើយសមុទ្រ

**ខ. ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅ**

ចំពោះ ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅដូចជា៖

១. តំបន់

២. កំពង់ផែ

៣. ផ្លូវដែក

៤. ស្ថានីយរថភ្លើង

៥. ព្រលានយន្តហោះ

[២១] អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ, លេខ១១៨ អនក្រ បក, ០៥ តុលា ២០០៥, មាត្រា២។

**គ. ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈតាមស្ថានភាពពីកំណើត ឬក្រោយពីការរៀបចំ**

ចំពោះ ទ្រព្យទាំងឡាយណាដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈទៅតាមស្ថានភាពពីកំណើត ឬក្រោយពីការរៀបចំដូចជា៖

១. ផ្លូវថ្នល់

២. ផ្លូវលំ

៣. ផ្លូវរទេះ

៤. ផ្លូវដើរ

៥. សួនច្បារ ឧទ្យានសាធារណៈ

៦. ដីចំណី។

**ឃ. ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យដំណើរការសម្រាប់សេវាសាធារណៈ**

ចំពោះ ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យដំណើរការសម្រាប់សេវាសាធារណៈដូចជា៖

១. សាលារៀន ឬ អគារសិក្សាសាធារណៈ

២. អគាររដ្ឋបាល

៣. មន្ទីរពេទ្យសាធារណៈ

**ង. ដែនបម្រុងធម្មជាតិការពារដោយច្បាប់**

**ច. បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ**

**ឆ. អចលនវត្ថុជាព្រះរាជទ្រព្យ ដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស**

**ជ. ដីផ្សេងៗទៀតដែលមានចរិតបំរើផលប្រយោជន៍សាធារណៈ និងដីដែលមានមូលដ្ឋានគតិយុត្តកំណត់រួចហើយ។**[២២]

មិនតែប៉ុណ្ណោះ រាល់ការគ្រប់គ្រងដីសាធារណៈរបស់រដ្ឋអាចប្រឈមនឹងការដាក់ទណ្ឌកម្ម អាចជាការដាកពិន័យ ឬផ្តន្ទាទោសដាក់ពន្ធនាគារ។

❖ ដីឯកជនរបស់រដ្ឋរួមមាន ដីទាំងអស់ដែលមិនមែនជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងមិនមែនជាដីដែល

[២២] អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ, លេខ១១៨ អនក្រ បក, ០៨ តុលា ២០០៥, មាត្រា៤។

កាន់កាប់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬដោយសមូហភាព ស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១។ ដីឯកជនរបស់រដ្ឋមានរួមបញ្ចូលដូចជា ទ្រព្យនិទាយាទភាពទាំងអស់ ឬទ្រព្យដែលម្ចាស់កម្មសិទ្ធិប្រគល់ឱ្យរដ្ឋដោយស្ម័គ្រចិត្ត ឬទ្រព្យដែលមិនអាចកំណត់បាននូវអត្តសញ្ញាណភោគី ឬកម្មសិទ្ធិករស្របច្បាប់។[២៣]

ដូចនេះ ចំពោះដីឯកជនរបស់រដ្ឋគឺរាល់អចលនវត្ថុទាំងឡាយដែលជាកម្មសិទ្ធិរបស់រដ្ឋ ប៉ុន្តែមិនបម្រើឱ្យផលប្រយោជន៍សាធារណៈនោះទេ។ ដីឯកជនរបស់រដ្ឋអាចជាកម្មវត្ថុនៃការលក់ ការដូរ ការផ្ទេរ និងការជួលរាប់បញ្ចូលទាំងការជួលរយៈពេលវែង និងសម្បទានដី ប៉ុន្តែរាល់ការផ្ទេរសិទ្ធិត្រូវគោរពតាមនីតិវិធីច្បាប់។ ចំណែកឯដីសាធារណៈរបស់រដ្ឋមិនអាចលក់ ឬផ្ទេរ និងមិនអាចផ្តល់ឱ្យជាសម្បទានដីសេដ្ឋកិច្ច ឬសង្គមកិច្ចឡើយ។ យ៉ាងណាក្តីដីសាធារណៈរបស់រដ្ឋអាចត្រូវបានជួល ប៉ុន្តែការជួលនោះត្រូវប្រឈមនឹងការរឹតត្បឹតតឹងតែងជាងការជួលដីឯកជនរបស់រដ្ឋ។ តែទោះបីជាយ៉ាងណាក៏ដោយ ដីនេះអាចជួលបានក្នុងរយៈពេលមិនលើសពី ១៥ឆ្នាំឡើយដរាបណារាល់សកម្មភាពលើដីសាធារណៈរបស់រដ្ឋមិនធ្វើឱ្យផ្លាស់ប្តូរលក្ខណៈនៃដី ឬធ្វើឱ្យដីនោះស្ថិតក្នុងលក្ខខណ្ឌដែលតម្លៃប្រយោជន៍សាធារណៈត្រូវបានបាត់បង់។ ប្រសិនបើដីសាធារណៈរបស់រដ្ឋបាត់បង់តម្លៃខាងបម្រើបម្រាស់ដល់ផលប្រយោជន៍សាធារណៈ វាអាចនឹងត្រូវបានចាត់ថ្នាក់ឡើងវិញជាដីឯកជនរបស់រដ្ឋ ដូចនេះអាចយកដីនោះមកជួល ធ្វើសម្បទាន ដោះដូរ ឬលក់បាន។

**១.២.២.២. អចលនវត្ថុនៃបុគ្គលឯកជន**

អចលនវត្ថុនៃបុគ្គលឯកជន គឺសំដៅទៅលើទ្រព្យសម្បត្តិជាដីទាំងឡាយណាដែលបានក្លាយទៅជាកម្មសិទ្ធិឯកជន ដោយមិនមែនជាដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋនោះទេ។ មិនតែប៉ុណ្ណោះដីឯកជននៃអចលនវត្ថុមានសិទ្ធិកម្មសិទ្ធិ ឬមានសិទ្ធិកាន់កាប់ដោយស្របច្បាប់ជាលក្ខណៈបុគ្គល ឬរួមគ្នាដោយបុគ្គលឬក្រុមហ៊ុន។ ចំពោះ ទ្រព្យឯកជនអាចជាកម្មវត្ថុនៃការលក់ដូរបានពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត ដែលមានលក្ខណៈស្រដៀងទៅនឹងទ្រព្យឯកជនរបស់រដ្ឋដែរ ប៉ុន្តែវាមិនអាចក្លាយទៅជាកម្មវត្ថុនៃសម្បទាន និងភោគៈទេ ចំណែកឯដីឯកជនរបស់រដ្ឋអាចក្លាយទៅជាកម្មវត្ថុនៃសម្បទាន និងភោគៈ។ សិទ្ធិជាម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុគឺជាសិទ្ធិដែលទទួលស្គាល់ក្នុងបទបញ្ញត្តិនៃមាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលជាច្បាប់កំពូលរបស់ប្រទេស ដែលបានកំណត់យ៉ាងជាក់លាក់ថា ជនណាក៏ដោយមិនថាជាបុគ្គលក្តី ជាសមូហភាពក្តីគឺមានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ យ៉ាងណាមិញមានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរទេទើបអាចមានសិទ្ធិលើដីធ្លី។ កម្មសិទ្ធិឯកជនស្របច្បាប់ស្ថិតក្រោមការគាំពារនៃច្បាប់ ដែលនឹងដកហូតកម្មសិទ្ធិពីជនណាមួយបាននោះលុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញតិទុក ហើយត្រូវផ្តល់

[២៣] អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ, លេខ១១៨ អនក្រ បក,០៨ តុលា ២០០៥, មាត្រា៥។

សំណងទុកជាមុនដោយសមរម្យ និងយុត្តិធម៌។[២៤]មិនតែប៉ុណ្ណោះច្បាប់ភូមិបាលឆ្នាំ២០០១ ក៏បានការពារសិទ្ធិពីការទន្ទ្រាននេះផងដែរ ហើយការដកហូតសិទ្ធិនេះអាចប្រព្រឹត្តទៅបានលុះត្រាតែត្រូវបានធ្វើឡើងដើម្បីបម្រើឱ្យប្រយោជន៍សាធារណៈ និងទទួលបានការបង់ថ្លៃផ្តល់ជាសំណងដោយសមរម្យ និងយុត្តិធម៌រួចរាល់។[២៥]

ប្រជាពលរដ្ឋគ្រប់រូបដែលមានប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុ គឺជាម្ចាស់កម្មសិទ្ធិពេញលេញតាមផ្លូវច្បាប់ (ឬហៅថាកម្មសិទ្ធិករ)។ កម្មសិទ្ធិករមានសិទ្ធិប្រើប្រាស់អាស្រ័យផល និងចាត់ចែងទ្រព្យរបស់ខ្លួនបានដោយផ្តាច់មុខ និងទូលំទូលាយ។[២៦] លើកលែងតែកម្មសិទ្ធិករប្រើប្រាស់ទ្រព្យនោះដើម្បីព្យាបាទ ឬរំខានដល់តតិយជន និងអ្នកជិតខាងរបស់ខ្លួនបានឡើយ ប៉ុន្តែការប្រើប្រាស់ទ្រព្យមានចរិតជាធម្មានុរូបមិនចាត់ទុកជាការរំខានទេ។[២៧]

បន្ថែមពីនេះទៅទៀត កម្មសិទ្ធិករអាចដាំដុះ សាងសង់ រៀបចំ ឬកែប្រែ គាស់កកាយ កាប់ព្រៃ ជីករូងចាក់បំពេញដីឈូសឆាយរៀបចំដីកសិកម្ម ឧស្សាហកម្ម និងរោងចក្រ។

អចលនវត្ថុមាន ០៣ ប្រភេទដូចជា៖

- អចលនវត្ថុពីកំណើត មានជាអាទិ៍៖ ដីព្រៃឈើ ដីកាប់រាន ដីដាំដុះ ដីទុកទំនេរ ដីមិនអាចដាំដុះ ដីលិចទឹក ដីសំណង់ ដីរៀបចំផ្សេងទៀត
- អចលនវត្ថុពីភ័ព្វវាសនា មានជាអាទិ៍៖ វត្ថុដែលយកទៅដាំជាប់នឹងដី ឬដាំជាប់ជាមួយសំណង់ និងមិនអាចបំបែកចេញបាន
- អចលនវត្ថុតាមការកំណត់របស់ច្បាប់ មានជាអាទិ៍៖ សិទ្ធិភណ្ឌិកលើអចលនទ្រព្យ និងចលនវត្ថុដែលច្បាប់កំណត់ថាជាអចលនវត្ថុ។

[២៤] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា៤៥។

[២៥] ច្បាប់ភូមិបាល ឆ្នាំ២០០១, មាត្រា៥។

[២៦] ច្បាប់ភូមិបាល ឆ្នាំ២០០១, មាត្រា៨៥។

[២៧] ច្បាប់ភូមិបាល ឆ្នាំ២០០១, មាត្រា៨៦។

# ជំពូកទី២
# នីតិវិធីនៃការធ្វើអស្សាមិករណ៍

# ជំពូកទី២
# នីតិវិធីនៃការធ្វើអស្សាមិករណ៍

## ២.១. ការរៀបចំ និងការប្រព្រឹត្តិទៅនៃការធ្វើអស្សាមិករណ៍

រាល់ការដកហូតដីធ្លីរបស់ប្រជាពលរដ្ឋ ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ វាបានបង្កនូវផលប៉ះពាល់យ៉ាងខ្លាំងទៅដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋមួយចំនួន ព្រមទាំងធ្វើឱ្យមានការប៉ះទង្គិចទៅដល់ទ្រព្យសម្បត្តិរដ្ឋដូចគ្នាផងដែរ។ ដូច្នេះហើយ ដើម្បីបង្ការកុំឱ្យមានផលប៉ះពាល់ទៅដល់សង្គមជាតិកាន់តែច្រើន រាជរដ្ឋាភិបាលបានបង្កើតនូវច្បាប់ស្តីពីអស្សាមិករណ៍ឡើង ក្នុងគោលបំណងធានារាល់ការដកហូតសិទ្ធិស្របច្បាប់លើកម្មសិទ្ធិឯកជនដោយសមរម្យ និងយុត្តិធម៌ ផ្តល់ជូនប្រជាពលរដ្ឋក្នុងការទូទាត់សំណងជាមុនប្រកបទៅដោយតម្លាភាព និងមានភាពសុក្រឹត ព្រមទាំងធ្វើឡើងដើម្បីបម្រើទៅដល់ផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិនៅក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។[២៨] ម្យ៉ាងវិញទៀត រាល់ការធ្វើអស្សាមិករណ៍មិនមែនធ្វើឡើងទៅតាមតែចិត្តនឹកឃើញ និងការចង់បានរបស់ស្ថាប័នរដ្ឋ ឬស្ថាប័នផ្សេងៗដែលជាប់ពាក់ព័ន្ធនោះទេ។ ផ្ទុយទៅវិញ ចំពោះការធ្វើអស្សាមិករណ៍នីមួយៗ ពោលគឺចាំបាច់ទាមទារឱ្យមានការរៀបចំគម្រោងការច្បាស់លាស់ និងមានថវិកាគ្រប់គ្រាន់ជាមុនសិនទើបអាចប្រព្រឹត្តទៅបាន។ មូលហេតុដែលធ្វើបែបនេះក៏ព្រោះតែដើម្បីការពារកុំឱ្យមានការខាតបង់ផលប្រយោជន៍ប្រជាពលរដ្ឋ ព្រមទាំងគោរពសិទ្ធិបុគ្គលរងគ្រោះដែលត្រូវបានដកហូតអចលនវត្ថុផងដែរ។

### ២.១.១. នីតិវិធីមុនធ្វើគម្រោងអស្សាមិករណ៍

ជាការពិតណាស់ ចំពោះការធ្វើអស្សាមិករណ៍ គឺត្រូវធ្វើឡើងដោយផ្អែកទៅលើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ដែលមានការអនុញ្ញាតពីរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួង ស្ថាប័នសាមី ព្រមទាំងត្រូវមានការប្រកាសសេចក្តីជូនដំណឹងពីរដ្ឋទៅកាន់ម្ចាស់អចលនវត្ថុជាមុនសិន ទើបអាចសម្រេចទៅបានដោយមិនមែនធ្វើឡើងតាមតែចិត្តនឹកឃើញរបស់បុគ្គលណាម្នាក់ ហើយមិនមានគម្រោងផែនការច្បាស់លាស់នោះទេ។ បានសេចក្តីថា ជាគោលការណ៍គណៈកម្មាធិការអស្សាមិករណ៍ត្រូវតែរៀបចំសំណើស្តីពីគម្រោងអស្សាមិករណ៍នេះទៅកាន់រាជរដ្ឋាភិបាលដើម្បីពិនិត្យ និងសម្រេចជាមុនសិន។[២៩] បន្ទាប់ពីរាជរដ្ឋាភិបាលបានពិនិត្យ និងធ្វើការសម្រេចទទួលយកសំណើរបស់គណៈកម្មាធិការអស្សាមិករណ៍រួចហើយ គណៈកម្មាធិការអស្សាមិករណ៍ត្រូវ

[២៨] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា២។

[២៩] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា១៥។

ផ្តល់ព័ត៌មានជូនទៅដល់ប្រជាពលរដ្ឋឱ្យបានដឹងអំពីការធ្វើអស្សាមិករណ៍នេះ ដើម្បីឱ្យប្រជាពលរដ្ឋធ្វើការត្រៀមខ្លួនទុកជាមុន។

ដូច្នេះ ដើម្បីធ្វើការបកស្រាយឱ្យកាន់តែច្បាស់ នាងខ្ញុំសូមធ្វើការលើកឡើងអំពី សំណើស្តីពីគម្រោងអស្សាមិករណ៍ និងការផ្តល់ព័ត៌មានស្តីពីគម្រោងនៃការធ្វើអស្សាមិករណ៍នេះដូចតទៅ។

**២.១.១.១. សំណើស្តីពីគម្រោងអស្សាមិករណ៍**

សំណើស្តីពីគម្រោងអស្សាមិករណ៍ ពិតជាមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងនីតិវិធីដំណើរការនៃការធ្វើអស្សាមិករណ៍ ពីព្រោះវាគឺជាជំហានដំបូង ឬជាជំហានគ្រឹះសម្រាប់ជួយឱ្យគម្រោងអស្សាមិករណ៍ដំណើរការទៅមុខបានយ៉ាងរលូន។ម្យ៉ាងវិញទៀត សំណើស្តីពីគម្រោងនេះអាចប្រព្រឹត្តទៅបានលុះត្រាតែបានឆ្លងកាត់នូវដំណាក់កាលជាច្រើនដូចជា គោលការណ៍ពីរាជរដ្ឋាភិបាល ការអង្កេតជាសាធារណៈ និងការធ្វើរបាយការណ៍សុំសេចក្តីសម្រេចពីរាជរដ្ឋាភិបាលជាដើម។

**ក. គោលការណ៍ពីរាជរដ្ឋាភិបាល**

គោលការណ៍ពីរាជរដ្ឋាភិបាល គឺជាសេចក្តីសម្រេចស្នើឡើងដោយក្រសួង ឬស្ថាប័នសាមីដែលពាក់ព័ន្ធស្នើសុំទៅរាជរដ្ឋាភិបាលដើម្បីធ្វើគម្រោងអស្សាមិករណ៍ ក្នុងមូលហេតុមានផលប៉ះពាល់ដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។ ដូច្នេះហើយ ទើបគេតម្រូវឱ្យក្រសួង ឬស្ថាប័នសាមីដែលជាប់ពាក់ព័ន្ធត្រូវធ្វើសំណើទៅកាន់រាជរដ្ឋាភិបាលពិនិត្យទៅលើគម្រោង ដើម្បីធ្វើការសម្រេចដាក់ឱ្យដំណើរការនីតិវិធីដកហូត។ ក្នុងនោះផងដែរ គោលការណ៍ពីរាជរដ្ឋាភិបាលពិតជាមានសារៈសំខាន់ណាស់នៅក្នុងដំណើរការនៃការធ្វើអស្សាមិករណ៍ពីព្រោះនីតិវិធីតម្រូវឱ្យមានការសម្រេចយល់ព្រមពីនាយករដ្ឋមន្ត្រី ទើបអាចធ្វើការប្រព្រឹត្តទៅបាន។ បន្ទាប់ពីទទួលបានគោលការណ៍ពីរាជរដ្ឋាភិបាល គណៈកម្មាធិការអស្សាមិករណ៍នឹងធ្វើការសិក្សាទៅលើគម្រោង ដោយគិតអំពីចំនួនថវិកាជាតិដែលត្រូវចំណាយក្នុងរយៈពេលនៃការធ្វើអស្សាមិករណ៍ ព្រមទាំងស្វែងរកដំណោះស្រាយនៅពេលដែលមានវិវាទកើតឡើង។ ក្រោយពីបានសិក្សាទៅលើគម្រោងចប់សព្វគ្រប់អស់ហើយ គណៈកម្មាធិការអស្សាមិករណ៍ត្រូវរៀបចំធ្វើរបាយការណ៍ស្តីពីដំណើរការនៃគម្រោងអស្សាមិរកណ៍ ដែលទាក់ទងទៅនឹងផលប៉ះពាល់ដាក់ជូនទៅរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងសម្រេច។

**ខ. ការអង្កេតជាសាធារណៈ**

ការធ្វើអស្សាមិករណ៍ វាបានជះនូវឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងទៅដល់ការរស់នៅរបស់ប្រជាពលរដ្ឋដែលរងគ្រោះក៏ដូចជាសន្តិសុខសង្គមជាតិផងដែរ។ ដូច្នេះហើយ ដើម្បីកាត់បន្ថយកុំឱ្យមានបញ្ហាទាំងអស់នេះកើតមានឡើងច្បាប់ស្តីពីអស្សាមិករណ៍បានចែងយ៉ាងច្បាស់អំពីការអង្កេតជាសាធារណៈ ក្នុងគោលបំណងកត់ត្រានូវទិន្នន័យទីកន្លែងដែលត្រូវអនុវត្តន៍គម្រោង។ ដោយក្នុងការអង្កេតនេះ គណៈកម្មាធិការអស្សាមិករណ៍ត្រូវតែធ្វើ

ការរៀបចំចាត់ចែងពិគ្រោះយោបល់ជាសាធារណៈនៅក្នុងកម្រិតអាជ្ញាធរ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ព្រមទាំងជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកតំណាងភូមិ ឬសហគមន៍ដែលរងនូវអស្សាមិករណ៍ដើម្បីផ្តល់ព័ត៌មានជាក់លាក់ច្បាស់លាស់ និងទទួលបាននូវមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធអំពីសំណើនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។[៣០] កាលដែលធ្វើដូច្នេះ គឺដើម្បីឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់បានចូលរួមយ៉ាងសកម្មនឹងដឹងឮជាសាធារណៈអំពីការដកហូតអចលនវត្ថុយកទៅធ្វើអស្សាមិករណ៍ ព្រមទាំងកុំឱ្យមានការព្រួយបារម្ភថាការធ្វើអស្សាមិករណ៍នេះ គឺធ្វើឡើងដោយឈរលើគោលការណ៍ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ និន្នាការនយោបាយ ឬមានការគាបសង្កត់ពីសំណាក់ជនទុច្ចរិតណាមួយឡើយ។ លើសពីនេះទៅទៀត ការអង្កេតជាសាធារណៈក៏បានផ្តល់នូវសិទ្ធិអត្ថិភាពទៅដល់ប្រជាពលរដ្ឋដែលជាប់ពាក់ព័ន្ធបានចូលរួមនឹងដឹងឮអំពីនីតិវិធីនៃការដកហូតដោយឱ្យពួកគាត់បានសិក្សាស្វែងយល់អំពីគោលបំណង ព្រមទាំងគុណប្រយោជន៍នៃការធ្វើអស្សាមិករណ៍។ ទន្ទឹមនឹងនេះ ការអង្កេតជាសាធារណៈក៏បានធ្វើឱ្យរាជរដ្ឋាភិបាលបានដឹងអំពីទុក្ខលំបាកដែលកើតមានឡើងចំពោះប្រជាពលរដ្ឋរងគ្រោះក្នុងការធ្វើគម្រោងអស្សាមិករណ៍នេះផងដែរ។ ដើម្បីជួយស្វែងរកដំណោះស្រាយជូនប្រជាពលរដ្ឋដូចជា ការផ្តល់នូវសំណងមួយយ៉ាងសមរម្យស្របតាមតម្លៃទីផ្សារ ឬរកទីកន្លែងថ្មីដែលមានសន្តិសុខសណ្តាប់ធ្នាប់ល្អជូនទៅកាន់ពួកគាត់សម្រាប់រស់នៅ។

**គ. ការធ្វើរបាយការណ៍**

បន្ទាប់ពីបានគោលការណ៍ពីរាជរដ្ឋាភិបាល និងធ្វើការអង្កេតជាសាធារណៈចប់ក្នុងអំឡុងពេល៣០ថ្ងៃរួចហើយ គណៈកម្មាធិការអស្សាមិករណ៍ត្រូវធ្វើរបាយការណ៍ដែលក្នុងនោះត្រូវលើកឡើងនូវអនុសាសន៍នានាដាក់ជូន និងសុំការសម្រេចពីរាជរដ្ឋាភិបាល។[៣១] ការធ្វើរបាយការណ៍នេះ គឺត្រូវធ្វើឡើងដោយមានការចូលរួមពីអាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ចូលរួមធ្វើរបាយការណ៍។ ហើយការចូលរួមធ្វើរបាយការណ៍នេះទៀតសោត ក៏ត្រូវមានការពិភាក្សា និងបូកសរុបថវិកាដែលត្រូវទូទាត់សំណងជាមុនជូនទៅកាន់ប្រជាពលរដ្ឋ។ បន្ទាប់មក គណៈកម្មាធិការអស្សាមិករណ៍នឹងដាក់ជូនរបាយការណ៍នេះទៅកាន់រាជរដ្ឋាភិបាលដើម្បីពិនិត្យសុំសេចក្តីសម្រេច។ នៅពេលដែលទទួលបានរបាយការណ៍ពីគណៈកម្មាធិការអស្សាមិករណ៍រួចហើយរាជរដ្ឋាភិបាលអាចយករបាយការណ៍នេះមកធ្វើការកែសម្រួល មុននឹងចេញសេចក្តីសម្រេចដាក់ចេញនូវគម្រោងស្តីពីការធ្វើអស្សាមិករណ៍។ បានសេចក្តីថា ប្រសិនបើនៅក្នុងករណីដែលរាជរដ្ឋាភិបាលបានពិនិត្យឃើញថា គម្រោងដែលគណៈកម្មាធិការអស្សាមិករណ៍ដាក់មកនេះមិនមានភាពចាំបាច់ ឬមិនមានសារៈសំខាន់នៅក្នុងការជួយអភិវឌ្ឍន៍

[៣០] ច្បាប់ស្តីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា១៦។

[៣១] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា១៦។

ប្រទេសជាតិឱ្យមានភាពរីកចម្រើនទេ រាជរដ្ឋាភិបាលអាចធ្វើការមិនឯកភាពទៅលើគម្រោងនេះបានដោយអាចពន្យាពេលរកដំណោះស្រាយ ឬបង្វែរគម្រោងនេះទៅកាន់ទីកន្លែងណាមួយផ្សេងទៀត។

**២.១.១.២. ការផ្តល់ព័ត៌មានស្តីពីគម្រោងនៃការធ្វើអស្សាមិករណ៍**

ជាគោលការណ៍ ពេលដែលរាជរដ្ឋាភិបាលបានពិនិត្យរបាយការណ៍របស់គណៈកម្មាធិការអស្សាមិករណ៍រួចហើយ ដោយពិនិត្យឃើញថាគម្រោងអស្សាមិករណ៍ដែលស្នើបញ្ជូនមក ពិតជាបានជួយអភិវឌ្ឍន៍សង្គមជាតិឱ្យមានភាពរីកចម្រើនយ៉ាងពិតប្រាកដមែន។ ដូច្នេះហើយរាជរដ្ឋាភិបាលនឹងចេញសេចក្តីសម្រេចដាក់ឱ្យអនុវត្តន៍គម្រោងអស្សាមិករណ៍នោះជាផ្លូវការ។ ហើយបន្ទាប់ពីទទួលបានសេចក្តីសម្រេច គណៈកម្មាធិការអស្សាមិករណ៍ត្រូវចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដែលជាដំបូងគណៈកម្មាធិការអស្សាមិករណ៍ត្រូវជម្រាបដល់ម្ចាស់សិទ្ធិអចលនវត្ថុ ឬម្ចាស់សិទ្ធិឱ្យបានដឹងអំពីអចលនវត្ថុ ដែលជាកម្មវត្ថុនៃការដកហូត និងត្រូវថែងអំពីគោលបំណងនៃការដកហូតកម្មសិទ្ធិ និង/ឬ សិទ្ធិលើអចលនវត្ថុឱ្យបានច្បាស់លាស់។ ហើយគណៈកម្មាធិការនៃអស្សាមិករណ៍ត្រូវកំណត់អំពីកម្មវត្ថុនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ទីតាំងគម្រោង ព្រមទាំងរយៈពេលសម្រាប់អនុវត្តន៍គម្រោង និងអាជ្ញាធរមានសមត្ថកិច្ចដែលមានសិទ្ធិរៀបចំធ្វើការដកហូតទៅលើកម្មសិទ្ធិ និង/ឬ សិទ្ធិ ឬទ្រព្យសម្បត្តិឯកជន។ បន្ទាប់មក គណៈកម្មាធិការអស្សាមិករណ៍ត្រូវតែផ្ញើនូវសេចក្តីប្រកាសទៅដល់គ្រប់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិដោយត្រូវភ្ជាប់នូវលិខិតថតចម្លង ព្រមទាំងមានដាក់ស្លាកសម្គាល់ថាអចលនវត្ថុនេះជាកម្មវត្ថុត្រូវដកហូតសម្រាប់បម្រើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។ ព្រមទាំងត្រូវផ្សព្វផ្សាយសេចក្តីប្រកាសតាមប្រព័ន្ធផ្សព្វផ្សាយ និងត្រូវបិទផ្សាយសេចក្តីប្រកាសនៅសាលាឃុំ សង្កាត់ ពាក់ព័ន្ធនឹងទីតាំងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដោយសេចក្តីប្រកាសនេះត្រូវធ្វើការផ្សព្វផ្សាយជូនទៅដល់ប្រជាពលរដ្ឋដែលមានអចលនវត្ថុពាក់ព័ន្ធដោយមេភូមិ។ ចំពោះការបិទផ្សាយ ត្រូវបិទនៅកន្លែងដែលងាយនឹងមើលឃើញដើម្បីឱ្យភាគីពាក់ព័ន្ធទាំងអស់បានដឹងព័ត៌មានអំពីគម្រោងនៃការធ្វើអស្សាមិករណ៍បានគ្រប់ៗគ្នានឹងត្រូវកំណត់កាលបរិច្ឆេទនៅក្នុងសេចក្តីប្រកាសឱ្យបានត្រឹមត្រូវ ក្នុងគោលបំណងកំណត់អំពីអំឡុងពេលដែលត្រូវដកហូតឲ្យបានច្បាស់លាស់ ដើម្បីបង្កនូវលក្ខណៈងាយស្រួលជូនទៅដល់ប្រជាពលរដ្ឋត្រៀមខ្លួនក្នុងការស្វែងរកទីកន្លែងថ្មី ឬផ្តល់នូវសំណងមួយយ៉ាងសមរម្យមានភាពយុត្តិធម៌ជូនទៅដល់ប្រជាពលរដ្ឋរងគ្រោះ ព្រមទាំងកំណត់នូវរយៈពេលនៃការធ្វើបណ្តឹងតវ៉ា។[៣២]

[៣២] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/00៣, ២៦ កុម្ភៈ ២០១០, មាត្រា១៧។

### ២.១.២. កិច្ចដំណើរការនៃការធ្វើអស្សាមិករណ៍

ចំពោះការធ្វើអស្សាមិករណ៍ គឺវាបានផ្តល់នូវផលលំបាកយ៉ាងច្រើនទៅដល់រាជរដ្ឋាភិបាលនៅក្នុងការជួយស្វែងរកដំណោះស្រាយជូនប្រជាពលរដ្ឋ ពីព្រោះដោយសារតែកិច្ចដំណើរការនៃការធ្វើអស្សាមិករណ៍នេះវាបានកាត់ផ្តាច់នូវកម្មសិទ្ធិលើអចលនវត្ថុរបស់ម្ចាស់សិទ្ធិ ដោយមានការរុះរើទីកន្លែងសម្រាប់ធ្វើគម្រោង។ ក៏ប៉ុន្តែរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា រាល់ការដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុកហើយត្រូវផ្តល់សំណងជាមុន ដោយមានភាពសមរម្យ និងយុត្តិធម៌។[៣៣] រីឯ ច្បាប់ភូមិបាលក៏បានបញ្ញត្តិផងដែរថា គ្មានបុគ្គលណាមួយត្រូវបានដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ។ ហើយការដកហូតត្រូវធ្វើឡើងតាមទម្រង់ និងនីតិវិធីបញ្ញត្តិដោយច្បាប់ និងបទបញ្ជា បន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។[៣៤] តែទោះបីជាមានការផ្តល់នូវសំណងយ៉ាងណាក៏ដោយ ការធ្វើអស្សាមិករណ៍នេះ វាបានផ្តល់នូវគុណវិបត្តិមួយចំនួនដូចជា ប្រជាពលរដ្ឋមិនពេញចិត្តនឹងសំណងជាសាច់ប្រាក់ដែលរដ្ឋបានផ្តល់ឱ្យ ឬសំណងដែលរដ្ឋបានផ្តល់មកនោះវាមិនគ្រប់គ្រាន់សម្រាប់ពួកគាត់ស្វែងរកទីកន្លែងថ្មី ឬពួកគាត់មិនដឹងថាត្រូវទៅរស់នៅទីកន្លែងណាផ្សេងទៀតជាអាទិ៍។

គួសបញ្ជាក់ផងដែរថា កិច្ចដំណើរការអស្សាមិករណ៍ត្រូវបានដំណើរការជាស្ថាពរនៅពេលដែលរដ្ឋបានសម្រេចយល់ព្រមទៅលើគម្រោងរបស់គណៈកម្មាធិការអស្សាមិករណ៍បានស្នើ ហើយនឹងត្រូវមានការដកហូតអចលនវត្ថុពីប្រជាពលរដ្ឋស្របតាមនីតិវិធីនៃច្បាប់។

#### ២.១.២.១. នីតិវិធីនៃការដកហូតអចលនវត្ថុ

ដំណើរការនៃការដកហូត គឺជាដំណាក់កាលមួយដែលត្រូវបានកាត់ផ្តាច់នូវកម្មសិទ្ធិលើអចលនវត្ថុពីម្ចាស់សិទ្ធិទៅលើផ្ទះសំបែង ឬដីចម្ការច្បារដំណាំ ដើម្បីយកទៅធ្វើគម្រោងអស្សាមិករណ៍។ ការដកហូតនេះត្រូវធ្វើឡើងដោយគណៈកម្មាធិការអស្សាមិករណ៍ ជាមួយនឹងម្ចាស់អចលនវត្ថុដែលទាមទារឱ្យម្ចាស់អចលនវត្ថុធ្វើការចាកចេញ ព្រមទាំងធ្វើការរុះរើនូវអ្វីដែលខ្លួនចង់យកទៅដោយគ្មានការហាមឃាត់ពីអាជ្ញាធរចំពោះរបស់របរនោះឡើយ។ ដោយមុនពេលធ្វើការដកហូត គណៈកម្មាធិការអស្សាមិករណ៍ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចអស្សាមិករណ៍ និងត្រូវផ្តល់សំណងគ្រប់ចំនួនដល់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិមុននឹងធ្វើអស្សាមិករណ៍។[៣៥] ដូច្នេះ នៅពេលដែលរាជរដ្ឋាភិបាលបានចេញសេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចអស្សាមិករណ៍នៅទីកន្លែង

---

[៣៣] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, មាត្រា៤៤។

[៣៤] ច្បាប់ភូមិបាលឆ្នាំ២០០១, មាត្រា៥។

[៣៥] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា២១។

ណាមួយហើយម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិពុំអាចលក់ ឬផ្ទេរនូវអចលនវត្ថុនោះឱ្យអ្នកដទៃបានឡើយ។ ក្នុងករណីប្រសិនបើមានលិខិតឯកសារនានា និងនីតិវិធីទាំងអស់ដែលផ្ទុយនឹងខ្លឹមសារដែលបានរៀបរាប់ត្រូវចាត់ទុកជាមោឃៈ។[៣៦] ក៏ប៉ុន្តែអ្វីដែលជាផលវិបាកសម្រាប់រាជរដ្ឋាភិបាលនោះ គឺប្រជាពលរដ្ឋគាត់មិនព្រមធ្វើការចាកចេញពីទីកន្លែងដែលពួកគាត់ធ្លាប់រស់នៅឡើយ ដោយមានមូលហេតុមួយចំនួនដូចជា ពួកគាត់ទទួលបានសំណងនៅលើដីរបស់ពួកគាត់មិនសាកសម និងតម្លៃទីផ្សារ ឬទីកន្លែងដែលត្រូវផ្លាស់ប្តូរជាមួយ និងទីកន្លែងចាស់របស់ពួកគាត់នោះ វាពិបាកនៅក្នុងការប្រកបមុខរបរសម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ជាងទីកន្លែងដែលពួកគាត់ធ្លាប់រស់នៅពីមុន។ ហេតុដូច្នេះហើយ ទើបច្បាប់ស្តីពីអស្សាមិករណ៍បានកំណត់យ៉ាងច្បាស់លាស់ថា មុននឹងធ្វើការដកហូតកម្មសិទ្ធិលើអចនលវត្ថុ ព្រមទាំងសិទ្ធិប្រត្យក្សលើអចលនវត្ថុអាចធ្វើទៅបានលុះត្រាតែ គណៈកម្មាធិការអស្សាមិករណ៍បានផ្តល់នូវសំណងឱ្យម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិជាមុនដោយសមរម្យ និងយុត្តិធម៌តាមគោលការណ៍ និងនីតិវិធីនៃការទូទាត់សំណង។[៣៧] បន្ទាប់ពីគណៈកម្មាធិការអស្សាមិករណ៍បានទូទាត់សំណងគ្រប់ចំនួនស្របតាមនីតិវិធីនៃច្បាប់ស្តីពីអស្សាមិករណ៍រួចហើយ គណៈកម្មាធិការអស្សាមិករណ៍នឹងទុកសិទ្ធិឱ្យម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិអាចកាន់កាប់អចលនវត្ថុទាំងនោះបានត្រឹមរយៈពេល០១ខែ។ នៅក្នុងករណី ប្រសិនបើម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិមិនព្រមចាកចេញពីទីកន្លែងនោះ គណៈកម្មាធិការអស្សាមិករណ៍អាចស្នើសុំទៅស្ថាប័នមានសមត្ថកិច្ច ឬអាជ្ញាធរសាធារណៈ ដើម្បីចាត់វិធានការតម្រូវឱ្យជននោះចាកចេញពីទីតាំងដែលត្រូវបានដកហូត។[៣៨] ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយក៏ស្ថាប័នមានសមត្ថកិច្ច ឬអាជ្ញាធរសាធារណៈត្រូវស្វែងរកវិធីសាស្ត្រគ្រប់បែបយ៉ាងដើម្បីជៀសវាងនូវការប្រើប្រាស់កម្លាំងបាយទៅលើប្រជាពលរដ្ឋហើយជំនួសមកវិញក្នុងការចរចាតាមសន្តិវិធី ដោយប្រកាន់ភ្ជាប់នូវគោលការណ៍ច្បាប់សិទ្ធិលើលំនៅឋាន និងគោលការណ៍មនុស្សធម៌ ក្នុងការជួយលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជា។

ដោយឡែក យោងទៅតាមទិដ្ឋភាពជាក់ស្តែងនៅក្នុងការធ្វើគម្រោងអស្សាមិករណ៍នេះទៀតសោត យើងសង្កេតឃើញថាមានការដកហូតទៅលើអចលនវត្ថុចំនួន០៣ប្រភេទ ដោយក្នុងនោះរួមមានដូចជា ការដកហូតអចលនវត្ថុទាំងស្រុង ការដកហូតអចលនវត្ថុមួយផ្នែក និងការដកហូតអចលនវត្ថុបណ្តោះអាសន្ន ដោយរាល់ការដកហូតទាំងអស់នេះ គឺគេមានគោលបំណងយកទៅអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានភាពរីកចម្រើន។ ដូច្នេះ

[៣៦] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា៣០។

[៣៧] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា១៩។

[៣៨] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា៣១។

ដើម្បីស្វែងយល់ថា ការដកហូតទាំង០៣ប្រភេទនេះប្រព្រឹត្តទៅយ៉ាងដូចម្តេចនោះ យើងនិងធ្វើការសិក្សាទៅលើប្រភេទនៃការដកហូតទាំង០៣នេះដូចតទៅ។

**ក. ការដកហូតអចលនវត្ថុទាំងស្រុង**

ការដកហូតអចលនវត្ថុទាំងស្រុង គឺជាការដកហូតនូវអចលនវត្ថុទាំងមូល ដែលមាននៅលើដីទាំងអស់ដោយមិនអោយសេសសល់នៅត្រង់កន្លែងណាមួយឡើយ។ ពីព្រោះតែទំហំនៃដីសម្រាប់ស្ថាបនា ស្តារ គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈវាបានធ្វើឱ្យប៉ះពាល់ចំដីនេះទាំងអស់។ ដូច្នេះហើយ រដ្ឋនិងធ្វើការដកហូតទំហំនៃអចលនវត្ថុនេះទាំងស្រុងដោយផ្អែកទៅតាមគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈរបស់រដ្ឋ។ ក្នុងនោះផងដែរ យោងទៅតាមទិដ្ឋភាពជាក់ស្តែងកន្លងមកយើងបានសង្កេតឃើញថា នៅតំបន់ពយជំទាវម៉ៅ ដែលស្ថិតនៅក្នុងភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ត្រូវបានរាជរដ្ឋាភិបាលរៀបចំធ្វើគម្រោងអស្សាមិករណ៍ទាំងស្រុងទៅលើអចលនវត្ថុមួយចំនួនរបស់ប្រជាពលរដ្ឋ ក្នុងគោលដៅស្ថាបនា ស្តារគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈឱ្យមានលក្ខណៈល្អប្រសើរ ព្រមទាំងជួយលើកកម្ពស់ដល់វិស័យទេសចរណ៍នៅកម្ពុជាឱ្យមានភាពទាក់ទាញដែលអាចផ្តល់នូវប្រាក់ចំណូលជូនរដ្ឋបានយ៉ាងច្រើនលើសលប់។[៣៩]

មួយវិញទៀត ចំពោះការដកហូតអចលនវត្ថុទាំងស្រុងនេះ ប្រសិនបើនៅក្នុងករណីការដកហូតមិនបានធ្វើឱ្យមានផលប៉ះពាល់ទៅដល់អចលនវត្ថុទាំងស្រុងទេ រឺការដកហូតនេះវាបានប៉ះពាល់តែមួយផ្នែកនៃដី រដ្ឋមិនអាចធ្វើការដកហូតអចលនវត្ថុនៃដីនោះទាំងស្រុងបានឡើយ ទោះបីជាស្ថិតនៅក្នុងហេតុផលណាមួយក៏ដោយ។ មូលហេតុក៏ព្រោះតែមុននឹងធ្វើអស្សាមិករណ៍នៅកន្លែងណាមួយនោះ រដ្ឋត្រូវធ្វើការរៀបចំគម្រោងផែនការឱ្យបានច្បាស់លាស់ ដោយត្រូវគិតពិចារណាថាគួរដកហូតអចលនវត្ថុនោះនៅក្នុងទំហំដីប៉ុណ្ណា ដើម្បីជៀសវាងកុំឱ្យអចលនវត្ថុដែលបានធ្វើការដកហូតមកនោះទុកចោលទំនេរឥតប្រយោជន៍ហើយមិនដឹងយកទៅប្រើប្រាស់ក្នុងគោលបំណងអ្វី។ ជាងនេះទៅទៀត ប្រសិនបើនៅក្នុងករណីរាជរដ្ឋាភិបាលបានធ្វើខុសពីគម្រោងដែលបានព្រាងទុកហើយធ្វើឱ្យអចលនវត្ថុនៃការដកហូតនោះនៅសេសសល់ទំនេរចោល ប្រាកដណាស់វាហាក់បីដូចជារំលោភបំពានសិទ្ធិប្រជាពលរដ្ឋ ធ្វើឱ្យប្រជាពលរដ្ឋរងនូវភាពអយុត្តិធម៌ព្រមទាំងបាត់បង់ទំនុកចិត្តទៅលើរាជរដ្ឋាភិបាលផងដែរ។ ដូច្នេះហើយ រាល់កិច្ចដំណើរការនៃការធ្វើគម្រោងអស្សាមិករណ៍នីមួយៗរដ្ឋត្រូវមានការប្រុងប្រយ័ត្នខ្ពស់ជាទីបំផុត ចំពោះការដកហូតអចលវត្ថុរបស់ប្រជាពលរដ្ឋ ពីព្រោះប្រជាពលរដ្ឋគាត់បានលះបង់ខ្ពស់នៅក្នុងការផ្តល់ទីកន្លែងដែលពួកគាត់ធ្លាប់រស់នៅយ៉ាងកក់ក្តៅជាច្រើនជំនាន់ ជូនទៅរាជរដ្ឋាភិបាលដើម្បីធ្វើការកសាងប្រទេសជាតិឱ្យមានភាពរីកចម្រើន។

---

[៣៩] សូមមើលឧបសម្ព័ន្ធរូបភាពទី៣។

### ខ. ការដកហូតអចលនវត្ថុមួយផ្នែក

ចំពោះការដកហូតអចលនវត្ថុមួយផ្នែក គឺជាការដកហូតនូវអចលនវត្ថុត្រឹមតែមួយផ្នែកនៃដីក្នុងចំណោមអចលនវត្ថុទាំងអស់។ មូលហេតុនៃការដកហូតអចលនវត្ថុមួយផ្នែកនេះ គឺបណ្តាលមកពីគម្រោងសាងសង់ពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈរបស់រដ្ឋ ត្រូវបានប៉ះចំផ្នែកណាមួយនៃដីរបស់ប្រជាពលរដ្ឋរងគ្រោះតែប៉ុណ្ណោះ។ ក្នុងនោះផងដែរ ចំពោះនីតិវិធីនៃការដកហូតអចលវត្ថុនេះទៀតសោត រដ្ឋត្រូវធ្វើការសិក្សាឱ្យបានលំអិតអំពីការរៀបចំគម្រោងដោយមិនត្រូវមានភាពធ្វេសប្រហែសនោះឡើយ។ ពីព្រោះដោយសារតែការដកហូតអចលនវត្ថុមួយផ្នែកនេះ គឺវាមានលក្ខណៈស្មុគស្មាញខ្លាំង ដោយហេតុថានៅពេលដែលរដ្ឋធ្វើអស្សាមិករណ៍ទៅលើគម្រោងណាមួយនៅក្នុងគម្រោងនោះប្រាកដណាស់តែងតែមានអចលនវត្ថុខ្លះត្រូវធ្វើការដកហូតទាំងស្រុង រីឯអចលវត្ថុខ្លះទៀតត្រូវដកហូតមួយផ្នែក។ ដូច្នេះហើយ រដ្ឋត្រូវធ្វើការបែងចែកឱ្យបានច្បាស់លាស់រវាងការដកហូតទាំងពីរនេះ ដើម្បីជៀសវាងកុំឱ្យមានវិវាទដោយប្រការណាមួយកើតឡើងទៅលើប្រជាពលរដ្ឋ។ ជាទូទៅ យើងសង្កេតឃើញថាការដកហូតអចលនវត្ថុមួយផ្នែកនេះវាបានបង្កនូវផលលំបាកជាច្រើនក៏ពិតមែន ក៏ប៉ុន្តែផ្ទុយទៅវិញវាក៏បានផ្តល់នូវផលប្រយោជន៍មួយចំនួនជូនទៅដល់ប្រជាពលរដ្ឋរងគ្រោះផងដែរ។ **<u>ជាឧទាហរណ៍</u>** នៅក្នុងករណីប្រជាពលរដ្ឋដែលរស់នៅតំបន់ជនបទមិនទាន់មានការអភិវឌ្ឍ ដោយតំបន់ដែលពួកគាត់រស់នៅមានតែផ្លូវលំតូចចង្អៀតសម្រាប់ធ្វើដំណើរ ប៉ុន្តែក្រោយមកស្រាប់តែមានគម្រោងអស្សាមិករណ៍សាងសង់ផ្លូវដោយប្តូរពីផ្លូវលំទៅជាផ្លូវជាតិវិញហើយការផ្លាស់ប្តូរផ្លូវនេះវាមានទំហំធំដោយតម្រូវយកដីចំនួនមួយផ្នែករបស់ប្រជាពលរដ្ឋមកសាងសង់ទើបអាចដំណើរការទៅបាន។ ដូច្នេះ ប្រជាពលរដ្ឋត្រូវខាតបង់នូវដីចំនួនមួយផ្នែករបស់ពួកគាត់ជូនទៅរាជរដ្ឋាភិបាលដើម្បីធ្វើការកសាងផ្លូវ។ ផ្ទុយទៅវិញ រាល់ការខាតបង់ទាំងអស់វាមិនមែនសុទ្ធសឹងតែឥតប្រយោជន៍នោះទេ តែវាក៏អាចបានមកវិញនូវផលប្រយោជន៍មួយចំនួនផងដែរ។ ពិតមែនប្រជាពលរដ្ឋបានបាត់បង់នូវដីចំនួនមួយផ្នែក ប៉ុន្តែពួកគាត់អាចទទួលបាននូវផលប្រយោជន៍ពីការបាត់បង់ដីនោះមកវិញដូចជា មានផ្លូវសម្រាប់ធ្វើដំណើរងាយស្រួលជាងមុន ដីអាចមានតម្លៃថ្លៃ និងមានភាពអ៊ូអរងាយស្រួលក្នុងការប្រកបមុខរបរចិញ្ចឹមជីវិតជាដើម។

### គ. ការដកហូតអចលនវត្ថុបណ្តោះអាសន្ន

ការដកហូតអចលនវត្ថុបណ្តោះអាសន្ន គឺជាការដកហូតនៅក្នុងករណីពិសេស និងបន្ទាន់ ដែលសុវត្ថិភាពសាធារណៈតម្រូវដូចជា ប្រយុទ្ធប្រឆាំងគ្រោះអគ្គីភ័យ ទឹកជំនន់ ភ្លើងឆេះព្រៃ រញ្ជួយដី សង្គ្រាមដែលប្រុងនឹងកើតមានឡើង ឬការវាយប្រហារដោយភេរវកម្ម និងស្ថានភាពផ្សេងៗទៀតដែលកំណត់ដោយរាជរដ្ឋាភិបាលអាចធ្វើការដកហូតអចលនវត្ថុ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុជាបណ្តោះអាសន្នដោយមិនចាំបាច់ធ្វើការពីគ្រោះយោបល់

ឡើយ ហើយត្រូវប្រគល់ជូនម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិវិញនៅពេលចប់ការដកហូតនេះ។[៤០] ក្នុងករណីបន្ទាន់ និងចាំបាច់ដែលផលប្រយោជន៍ជាតិតម្រូវ រាជរដ្ឋាភិបាលមានអំណាចឆន្ទានុសិទ្ធិក្នុងការធ្វើអស្សាមិករណ៍ដោយមិនចាំបាច់រៀបចំធ្វើការពិគ្រោះយោបល់តាមនីតិវិធីនៃច្បាប់នោះទេ។[៤១] កាលដែលធ្វើបែបនេះ ពីព្រោះតែស្ថានការណ៍នៃការធ្វើអស្សាមិករណ៍នោះមានលក្ខណៈជាបន្ទាន់ ដែលទាមទារឱ្យមានការដកហូតទាំងប្រញាប់មិនអាចយឺតយ៉ាវបាន។ ក្នុងករណី ប្រសិនបើគណៈកម្មាធិការអស្សាមិករណ៍ធ្វើការរៀបចំទៅតាមនីតិវិធីនៃច្បាប់ពីមួយដំណាក់កាលទៅមួយដំណាក់កាលវាត្រូវចំណាយរយៈពេលយូរ ដែលអាចធ្វើឱ្យអាជ្ញាធរមិនអាចទប់ស្កាត់នូវបញ្ហានេះឱ្យទាន់ពេលវេលាបានឡើយ។ ដូច្នេះហើយប្រជាពលរដ្ឋដែលរងគ្រោះ ត្រូវធ្វើការសហការណ៍ជាមួយអាជ្ញាធរដោយមិនត្រូវបង្កនូវភាពរាំងស្ទះណាមួយកើតឡើងនោះទេ។ នៅពេលដែលភារៈកិច្ចត្រូវបានបញ្ចប់ជាស្ថាពរ អាជ្ញាធរនឹងធ្វើការប្រគល់ជូននូវអចលនវត្ថុដែលបានមកពីការដកហូតជាបណ្តោះអាសន្ននោះទៅកាន់ម្ចាស់អចលនវត្ថុដើមវិញ ដោយមិនត្រូវមានការកេងប្រវ័ញ្ចទៅលើម្ចាស់អចលនវត្ថុនោះឡើយ។ សូមបញ្ជាក់ផងដែរថា បានជាអាជ្ញាធរមានឆន្ទានុសិទ្ធិធ្វើការដកហូតជាបណ្តោះអាសន្ននេះឡើង ក៏ព្រោះតែវាគឺជាករណីបន្ទាន់ និងមានភាពចាំបាច់ជាទីបំផុតសម្រាប់ផលប្រយោជន៍ជាតិ និងផលប្រយោជន៍សាធារណៈតម្រូវ។ ប្រសិនបើពុំមានអំណាចឆន្ទានុសិទ្ធិសម្រាប់រាជរដ្ឋាភិបាលនោះទេផលប្រយោជន៍ជាតិនឹងត្រូវមានការខាតបង់ដោយសារតែការយឺតយ៉ាវនោះជាក់ជាពុំខាន។

### ២.១.២.២. ការអនុវត្តគម្រោងអស្សាមិករណ៍ជាក់ស្តែង

ការអនុវត្តគម្រោង គឺជាដំណាក់កាលមួយដ៏មានសារៈសំខាន់បំផុតនៅពេលដែលដំណាក់កាលអង្កេត ដំណាក់កាលស្នើសុំ និងចេញសេចក្តីសម្រេចពីរាជរដ្ឋាភិបាល ព្រមទាំងដំណាក់កាលដកហូតជាអាទិ៍ត្រូវបានបញ្ចប់។ យ៉ាងណាមិញ ចំពោះដំណាក់កាលនៃការអនុវត្តគម្រោងនេះ គេមិនអាចធ្វើការពន្យាពេល ឬក៏ប្រើប្រាស់អចលនវត្ថុដែលបានមកពីការដកហូតយកទៅប្រើប្រាស់ឱ្យខុសពីគោលបំណងដែលបានគ្រោងទុកនោះឡើយ។ ដោយអចលនវត្ថុដែលត្រូវបានដកហូតមកនេះ គឺត្រូវប្រើប្រាស់សម្រាប់តែក្នុងគោលដៅដែលបានគ្រោងទុកនៅក្នុងសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដើម្បីជាផលប្រយោជន៍សាធារណៈ ឬតម្រូវការនៃផលប្រយោជន៍ជាតិតែប៉ុណ្ណោះ នឹងមិនអាចទុកចោលឱ្យនៅទំនេរដោយគ្មានហេតុផលសមស្រប ឬផ្ទេរទៅឱ្យតតិយជនណាម្នាក់ក្នុងគោលដៅបម្រើផលប្រយោជន៍ឯកជននោះទេ។[៤២]

---

[៤០] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា១០ កថាខណ្ឌទី១។

[៤១] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា១០ កថាខណ្ឌទី២។

[៤២] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា៩។

**ក. ការអនុវត្តខុសពីគម្រោង**

ជាការពិតណាស់ រាល់អចលនវត្ថុដែលបានដកហូតដើម្បីយកទៅធ្វើគម្រោងអស្សាមិករណ៍ គឺត្រូវយកទៅប្រើប្រាស់ឱ្យចំគោលដៅដូចដែលបានគ្រោងទុក មានន័យថាការអនុវត្តទៅលើគម្រោងដែលយកទៅអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ គឺត្រូវប្រើប្រាស់ឱ្យទាន់ពេលវេលា និងមិនត្រូវយកទៅប្រើប្រាស់ឱ្យខុសពីគោលដៅដែលបានគ្រោងទុកនោះឡើយ។ **ឧទាហរណ៍** ដូចជារដ្ឋមានគម្រោងសាងសង់មន្ទីរពេទ្យនៅក្នុងតំបន់ជនបទដាច់ស្រយាលមួយ ពីព្រោះរដ្ឋបានសង្កេតឃើញថានៅក្នុងតំបន់នោះពុំមានមន្ទីរពេទ្យគ្រប់គ្រាន់សម្រាប់ឱ្យប្រជាពលរដ្ឋសម្រាកព្យាបាលជំងឺ។ ដោយឈ្វេងយល់ពីទុកលំបាករបស់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលក៏បានរៀបចំគម្រោងសាងសង់មន្ទីរពេទ្យនៅតំបន់នោះ ដើម្បីជួយសម្រាលទៅដល់ប្រជាពលរដ្ឋក្នុងការពិគ្រោះជំងឺផ្សេងៗ។ ដូច្នេះ ដើម្បីសាងសង់នូវមន្ទីរពេទ្យនេះរដ្ឋត្រូវធ្វើអស្សាមិករណ៍នៅកន្លែងណាមួយនៃដីរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះ ហើយរដ្ឋបានប្រគល់ដីមួយកន្លែងដែលបានធ្វើការដកហូតពីប្រជាពលរដ្ឋប្រគល់ទៅឱ្យក្រុមហ៊ុនឯកជនធ្វើការសាងសង់។ ប៉ុន្តែផ្ទុយទៅវិញ ចំពោះសមិទ្ធផលដែលកើតចេញមកនោះវាខុសពីគម្រោងអស្សាមិករណ៍ដែលរដ្ឋបានផ្សព្វផ្សាយ ពីព្រោះដោយសារតែគម្រោងនៃការសាងសង់មន្ទីរពេទ្យបែរទៅជាសាងសង់រោងចក្រឧស្សាហ៍កម្មទៅវិញ។ កាលដែលធ្វើបែបនេះ ហាក់បីដូចជាមានការរំលោភបំពានសិទ្ធិរបស់ប្រជាពលរដ្ឋ ហេតុនេះប្រជាពលរដ្ឋអាចមានសិទ្ធិប្តឹងជំទាស់ចំពោះដំណើរការគម្រោងនេះបាន។

**ខ. អចលនវត្ថុដែលនៅទំនេរ**

ជាទូទៅ មុននឹងចាប់ផ្តើមកិច្ចដំណើរការនៃការធ្វើគម្រោងអស្សាមិករណ៍រដ្ឋត្រូវតែរៀបចំផែនការឱ្យបានច្បាស់លាស់យ៉ាងប្រុងប្រយ័ត្នទុកជាមុនសិន។ ដើម្បីជៀសវាងកុំឱ្យអចលនវត្ថុដែលបានមកពីប្រជាពលរដ្ឋដោយការធ្វើអស្សាមិករណ៍យ៉ាងលំបាកនោះទុកចោលឱ្យនៅទំនេរឥតប្រយោជន៍។ ក្នុងនោះផងដែរ ចំពោះអចលនវត្ថុដែលនៅទំនេរនេះមានន័យថា មុននឹងដំណើរការគម្រោងអស្សាមិករណ៍នៅទីតាំងណាមួយរដ្ឋត្រូវធ្វើការដកហូតអចលនវត្ថុរបស់ប្រជាពលរដ្ឋដែលរស់នៅទីតាំងនោះយកមកអភិវឌ្ឍន៍គម្រោងជាមុនសិន។ ក៏ប៉ុន្តែក្រោយមកដោយមានភាពធ្វេសប្រហែសរដ្ឋបានយល់ឃើញថាការធ្វើគម្រោងនៅទីតាំងនោះវាពុំបានផ្តល់នូវគុណសម្បត្តិអ្វីមកដល់រដ្ឋឡើយ ហើយរដ្ឋក៏សម្រេចចិត្តថានឹងបង្វែរគម្រោងអស្សាមិករណ៍ទៅទីតាំងណាមួយផ្សេងទៀត។ ដូច្នេះហើយ ចំពោះអចលនវត្ថុដែលបានដកហូតមកពីប្រជាពលរដ្ឋមុននោះ គឺត្រូវទុកចោលឱ្យនៅទំនេរសិន។ កាលដែលធ្វើបែបនេះ វាបានបង្កនូវគុណវិបត្តិជាច្រើនមកដល់រដ្ឋក៏ដូចជាប្រជាពលរដ្ឋរងគ្រោះផងដែរ។ សម្រាប់រដ្ឋ គឺត្រូវខាតបង់នូវពេលវេលា និងថវិកាជាតិជាច្រើន ព្រមទាំងបានបាត់បង់ទំនុកចិត្តពីប្រជាពលរដ្ឋថែមទៀត។ ចំណែកឯ ប្រជាពលរដ្ឋរងគ្រោះវិញគឺទទួលរងនូវភាពអយុត្តិធម៌ជាខ្លាំង ពីព្រោះពួកគាត់បានខិតខំចាកចេញពីកន្លែងដែលពួកគាត់ធ្លាប់រស់នៅយ៉ាងលំបាកហើយយល់ព្រមលះបង់ទាំងកម្លាំងកាយ និងកម្លាំងចិត្តដើម្បីផ្តល់នូវ

អចលនវត្ថុជូនរដ្ឋក្នុងការកសាងសង្គមជាតិឱ្យមានភាពរីកចម្រើន។ ហេតុនេះហើយ ដើម្បីតបស្នងនូវទឹកចិត្តរបស់ប្រជាពលរដ្ឋរងគ្រោះ រដ្ឋត្រូវធ្វើយ៉ាងណាកុំទុកអចលនវត្ថុដែលបាន ដកហូតពីប្រជាពលរដ្ឋឱ្យនៅទំនេរដោយត្រូវមានភាពប្រុងប្រយ័ត្នខ្ពស់ក្នុងការរៀបចំគម្រោងនេះ។ ក៏ប៉ុន្តែ នៅក្នុងករណីដែលអចលនវត្ថុនៅសល់ពីតម្រូវការប្រើប្រាស់ ត្រូវផ្តល់សិទ្ធិអាទិភាពលក់ជូនទៅដល់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិតាមអត្រាតម្លៃនៃការទូទាត់សំណងវិញ។ តែបើម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិមិនព្រមទទួលយកអចលនវត្ថុដែលសេសសល់ពីតម្រូវការប្រើប្រាស់វិញទេនោះ រដ្ឋត្រូវរក្សាទុកអចលនវត្ថុនោះជាសម្បត្តិរបស់រដ្ឋ។[៤៣]

សូមបញ្ជាក់ផងដែរថា ចំពោះអចលនវត្ថុដែលសល់ពីការប្រើប្រាស់ វាផ្ទុយពីអចលនវត្ថុដែលនៅទំនេរ។ ដោយអចលនវត្ថុដែលនៅសល់ពីការប្រើប្រាស់ មានន័យថារដ្ឋបានធ្វើគម្រោងអស្សាមិករណ៍ទៅលើអចលនវត្ថុនោះហើយ ក៏ប៉ុន្តែនៅពេលដែលគម្រោងត្រូវបានបញ្ចប់អចលនវត្ថុនោះ គឺនៅសេសសល់ ដែលជាហេតុធ្វើឱ្យរដ្ឋចង់ប្រគល់ដីនោះទៅឱ្យប្រជាពលរដ្ឋដើមវិញ។ តែចំពោះការផ្តល់អចលនវត្ថុឱ្យវិញនេះ ប្រជាពលរដ្ឋត្រូវប្រគល់សំណងមួយចំនួនទៅកាន់រដ្ឋតាមតម្លៃនៃអចលនវត្ថុដែលនៅសេសសល់នោះផងដែរ។

## ២.២. ការទូទាត់សំណង និងបញ្ហាប្រឈមនៃការធ្វើអស្សាមិករណ៍

### ២.២.១. គោលការណ៍នៃការទូទាត់សំណង

ជាគោលការណ៍ មុននឹងធ្វើការអនុវត្តនីតិវិធីអស្សាមិករណ៍ជាក់ស្តែង រដ្ឋត្រូវផ្តល់នូវសំណងមួយយ៉ាងសមរម្យ និងប្រកបទៅដោយភាពយុត្តិធម៌ជូនទៅដល់ប្រជាពលរដ្ឋដែលរងនូវផលប៉ះពាល់នៃការដកហូតនេះជាមុនសិន។ គោលបំណងដែលរាជរដ្ឋាភិបាលចាត់វិធានការណ៍ផ្តល់នូវសំណងនេះជាមុន ក៏ព្រោះតែរាជរដ្ឋាភិបាលចង់ទុករយៈពេលឱ្យម្ចាស់សិទ្ធិមានលទ្ធភាពអាចស្វែងរកនូវទីកន្លែងថ្មីដើម្បីតាំងទីលំនៅបាន។ សូមបញ្ជាក់ផងដែរថា ចំពោះគោលការណ៍នៃការទូទាត់សំណងជូនទៅដល់ប្រជាពលរដ្ឋនេះ គឺគេរាប់បញ្ចូលទាំងអស់នូវរាល់ព្យសនៈកម្មដែលបានកើតមានឡើង។ ដូច្នេះ ដើម្បីធ្វើការសិក្សាស្វែងយល់ឱ្យបានលំអិតអំពីកម្មវត្ថុនៃការផ្តល់សំណងមានអ្វីខ្លះ យើងនឹងធ្វើការបកស្រាយអំពីរូបមន្តនៃការទូទាត់សំណង និងការគណនាសំណងជាអាទិ៍។

#### ២.២.១.១. រូបមន្តនៃការទូទាត់សំណង

ជាការពិតណាស់ ចំពោះរូបមន្តនៃការទូទាត់សំណង គឺជាផ្នែកមួយដ៏មានសារៈសំខាន់ជាទីបំផុតនៅក្នុងដំណាក់កាលនៃការទូទាត់សំណងជូនប្រជាពលរដ្ឋស្របទៅតាមនីតិវិធីនៃច្បាប់ស្តីពីអស្សាមិករណ៍។ ដោយការអនុវត្តនូវរូបមន្តនៃការទូទាត់សំណងនេះ វាបានផ្តល់នូវភាពងាយស្រួលជាច្រើនទៅដល់រាជរដ្ឋាភិបាលក្នុងការទូទាត់សំណងជូនប្រជាពលរដ្ឋប្រកបទៅដោយតម្លាភាព និងមានភាពយុត្តិធម៌។ ហើយរូបមន្តនៃការទូទាត់សំណងនេះទៀតសោត គឺត្រូវបានគេបែងចែកជា០២ប្រភេទ ដែលរួមមានដូចជា សំណងទូទាត់ជាសាច់ប្រាក់

---

[៤៣] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/00៣, ២៦ កុម្ភៈ ២០១០, មាត្រា៩ កថាខណ្ឌទី២។

និងសំណងទូទាត់ជាទ្រព្យ ឬជាសិទ្ធិជំនួស។[៤៤] ដោយការទូទាត់ទាំង០២ប្រភេទ នេះគឺត្រូវធ្វើឡើងទៅតាមភាពជាក់ស្តែងហើយតម្រូវឱ្យមានការយល់ព្រមពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ព្រមទាំងគណៈកម្មាធិការអស្សាមិករណ៍ផងដែរ។ សូមជម្រាបថា នៅក្នុងការទទួលបាននូវសំណងជាសាច់ប្រាក់ និងសំណងទូទាត់ជាទ្រព្យ ឬជាសិទ្ធិជំនួសនេះគឺមានតែម្ចាស់អចលនវត្ថុស្របច្បាប់តែប៉ុណ្ណោះ។ រីឯ ប្រជាពលរដ្ឋដែលគ្មានប័ណ្ណកម្មសិទ្ធិស្របច្បាប់មិនអាចទទួលបាននូវសំណងបែបនេះឡើយ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ពួកគាត់ម្នាក់ៗមានសិទ្ធិស្របច្បាប់ក្នុងការទទួលបាននូវសំណងសម្រាប់លំនៅឋាន និងសំណងផ្សេងៗដែលពួកគាត់បានបាត់បង់។ ពួកគាត់ក៏មានសិទ្ធិស្របច្បាប់ ទទួលបានសំណងសម្រាប់ការប្រើប្រាស់ដីនោះ ដូចជាផលដំណាំដែលពួកគាត់បានដាំ ឬប្រព័ន្ធប្រឡាយទឹកដែលពួកគាត់បានធ្វើនៅលើដីនោះជាដើម។[៤៥]

**ក. សំណងទូទាត់ជាសាច់ប្រាក់**

មុននឹងដំណើរការនីតិវិធីនៃការទូទាត់សំណងអាជ្ញាធរដែលទទួលបន្ទុកត្រូវចុះទៅទីតាំងដកហូត ដើម្បីធ្វើការចរចាជាមួយម្ចាស់សិទ្ធិ និងម្ចាស់សិទ្ធិប្រត្យក្ស ក្នុងគោលបំណងធ្វើការអង្កេត និងវាយតម្លៃទៅលើអចលនវត្ថុនោះជាមុនសិន។ បន្ទាប់ពីធ្វើការអង្កេតចប់ និងទទួលបានសេចក្តីសម្រេចពីរាជរដ្ឋាភិបាល គណៈកម្មាធិការអស្សាមិករណ៍ត្រូវប្រគល់ប្រាក់សំណងដែលត្រូវផ្តល់ឱ្យម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិទៅតាមតម្លៃទីផ្សារ ឬថ្លៃជំនួសនៅកាលបរិច្ឆេទនៃការចេញសេចក្តីប្រកាសស្តីពីគម្រោងដោយថ្លៃទីផ្សារ ឬថ្លៃជំនួសត្រូវកំណត់ដោយគណៈកម្មការ ឬភ្នាក់ងារឯករាជ្យមួយតាមការជ្រើសរើសរបស់គណៈកម្មាធិការអស្សាមិករណ៍។[៤៦] ម្យ៉ាងវិញទៀតចំពោះប្រាក់សំណងត្រូវគិតតាមតម្លៃសំណងសរុប ដកចំនួនទឹកប្រាក់បន្ទុកប្រថាប់ត្រា និង/ឬ ពន្ធលើដីធ្លីមិនប្រើប្រាស់ដែលកន្លងមកមិនទាន់បានបង់ជូនទៅកាន់រដ្ឋ ហើយគណៈកម្មាធិការអស្សាមិករណ៍ត្រូវបង់ប្រាក់ពន្ធកាត់ទុកទាំងនោះចូលថវិកាជាតិ តាមនីតិវិធីជាធរមាន។[៤៧] ក្នុងនោះផងដែរ ចំពោះបែបបទ និងនីតិវិធីនៃការទូទាត់សំណង ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[៤៨] បានសេចក្តីថានៅពេលដែលចាប់ផ្តើមធ្វើគម្រោង គណៈកម្មាធិការអស្សាមិករណ៍ត្រូវធ្វើការស្នើសុំថវិកាទៅកាន់ក្រសួងសេដ្ឋកិច្ចដើម្បីឱ្យក្រសួងចេញអនុក្រឹត្យផ្តល់នូវកញ្ចប់ថវិកាដល់ការធ្វើគម្រោងអស្សាមិករណ៍នេះ។ មូលហេតុដែលត្រូវមានថវិកាបម្រុងទុកជាមុន ពីព្រោះតែការធ្វើគម្រោងអស្សាមិករណ៍នេះ គឺទាមទារឱ្យមានថវិកាគ្រប់គ្រាន់ក្នុងការផ្តល់

[៤៤] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា២៤។

[៤៥] សៀវភៅណែនាំសហគមន៍ស្តីពីនយោបាយការពារការផ្លាស់ប្តូរទីលំនៅដោយបង្ខំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

[៤៦] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា២២។

[៤៧] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា២៥។

[៤៨] នៃច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា២៤ កថាខណ្ឌទី២។

សំណងយ៉ាងសមរម្យ និងយុត្តិធម៌ ដែលជាលក្ខខណ្ឌចាំបាច់បំផុតមុននឹងឈានទៅដល់ការអនុវត្តគម្រោងបានយ៉ាងរលូន។ ផ្ទុយទៅវិញ ប្រសិនបើនៅក្នុងស្ថានភាពថវិកាមិនទាន់គ្រប់គ្រាន់ គម្រោងនៃការធ្វើអស្សាមិករណ៍ដាច់ខាតគឺមិនអាចដំណើរការបាននោះឡើយ។

ជាក់ស្តែងនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២១ លោក ឆឹង ង៉ែ មេឃុំកណ្តាល បានចូលរួមសហការណ៍ជាមួយក្រុមការងារអន្តរក្រសួង ដឹកនាំដោយលោក ទេព វិស្តុល ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងក្រុមការងារថ្នាក់ស្រុក ថ្នាក់ខេត្ត មានការចូលរួមពីក្រុមប្រឹក្សាឃុំ និងមេភូមិ ធ្វើការរៀបចំពិធីបើកប្រាក់ទូទាត់សំណងនៃការធ្វើអស្សាមិករណ៍ជូនប្រជាពលរដ្ឋដែលរងនូវផលប៉ះពាល់ដោយសារ គម្រោងលើកម្រិតគុណភាពផ្លូវជាតិលេខ ៤៨ មានចំនួន ៤ ភូមិ ក្នុងឃុំកណ្តាលមានដូចជា ភូមិតាំកន់ ភូមិកណ្តាល ភូមិផ្ទង់ ភូមិប្រលាននៃខេត្តកោះកុង។[៤៩]

## ខ. សំណងទូទាត់ជាទ្រព្យ ឬសិទ្ធិជំនួស

ចំពោះសំណងនៃការធ្វើអស្សាមិករណ៍ មិនត្រឹមតែអាចទូទាត់ជាសាច់ប្រាក់ដល់ម្ចាស់អចលនវត្ថុប៉ុណ្ណោះទេតែក៏អាចទូទាត់ជាទ្រព្យ ឬសិទ្ធិជំនួសបានផងដែរ។ មានន័យថា ប្រសិនបើប្រពលរដ្ឋរងគ្រោះគាត់ពុំចង់ទទួលបាននូវសំណងជាសាច់ប្រាក់ដែលរដ្ឋបានផ្តល់ឱ្យទេ ដោយគាត់មានបញ្ហាមួយចំនួននៅក្នុងការស្វែងរកទីកន្លែងថ្មីសម្រាប់រស់នៅ។ ប្រជាពលរដ្ឋអាចស្នើសុំទៅកាន់រាជរដ្ឋាភិបាល ផ្តល់នូវសំណង់ជាដីត្រង់ទីតាំងណាមួយដែលសមរម្យមកកាន់ពួកគាត់បាន។ គ្រាន់តែរាជរដ្ឋាភិបាលត្រូវមានភាពប្រាកដថា ប្រជាពលរដ្ឋដែលត្រូវបានផ្លាស់ប្តូរទៅរស់នៅទីតាំងថ្មីមានសុវត្ថិភាពនៃការកាន់កាប់អចនវត្ថុនៅឯតំបន់តាំងទីលំនៅថ្មីនោះ។ ក្នុងន័យនេះបានសេចក្តីថា រាជរដ្ឋាភិបាលត្រូវតែធានាតាមផ្លូវច្បាប់ដោយចេញប័ណ្ណកម្មសិទ្ធិលើអចលវត្ថុ ក្នុងគោលបំណងគាំពារមិនឱ្យតតិយជនណាម្នាក់រំលោភបំពានទៅលើសិទ្ធិរបស់ពួកគាត់ដោយការបណ្តេញចេញពីលំនៅឋានឡើយ។ មិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាលគួតែយកចិត្តទុកដាក់នៅក្នុងការស្វែងរកលំនៅឋានថ្មីជូនប្រជាពលរដ្ឋដោយលំនៅឋានថ្មីនោះគប្បីគួរតែរៀបចំនៅកន្លែងជិតទីប្រជុំជនដែលអាចមានហេដ្ឋារចនាសម្ព័ន្ធ និងសេវានានាជាមូលដ្ឋានមានលក្ខខណ្ឌងាយស្រួលក្នុងការរកការងារធ្វើ និងធានាបាននូវសុវត្ថិភាពលំនៅឋានថែមទៀត។[៥០]

ជាក់ស្តែងនាពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលបានរៀបចំធ្វើគម្រោងអស្សាមិករណ៍នៅក្នុងតំបន់មួយនាភូមិ៣២ ឃុំតាអុង ស្រុកចំការលើ ខេត្តកំពង់ចាម ក្នុងគោលបំណងដើម្បីយកតំបន់នោះមកអភិវឌ្ឍន៍ឱ្យមានភាពរីកចម្រើនសម្រាប់ជួយទៅដល់ផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ។ ដោយគម្រោងដំណើរ

---

[៤៩] គេហទំព័រ https://www.kohkong.gov.kh/archives/135666 ដកស្រង់នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣។

[៥០] សៀវភៅគោលនយោបាយជាតិស្តីពី "លំនៅឋាន"។

អស្សាមិករណ៍នេះរាជរដ្ឋាភិបាលបានគិតគូរទៅដល់ប្រជាពលរដ្ឋហើយបានផ្តល់នូវសំណងដែលទូទាត់ជាទ្រព្យ ឬសិទ្ធិជំនួសស្របច្បាប់ទៅកាន់ប្រជាពលរដ្ឋដែលបានរស់នៅទីកន្លែងនោះ។ ម្យ៉ាងវិញទៀត ចំពោះទីកន្លែងថ្មីដែលរដ្ឋបានផ្តល់ជូនប្រជាពលរដ្ឋគឺស្ថិតនៅភូមិថ្មី ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម ដែលមានចម្ងាយមិនឆ្ងាយពីទីកន្លែងចាស់នោះទេ។ មិនតែប៉ុណ្ណោះ ចំពោះទីកន្លែងថ្មីដែលរដ្ឋបានផ្តល់ជូនប្រជាពលរដ្ឋ គឺវាមានភាពល្អប្រសើរជាងទីកន្លែងមុន ដោយរដ្ឋបានសាងសង់សាលារៀន មន្ទីរពេទ្យ ផ្លូវគមនាគមន៍ ព្រមទាំងមានហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតជូនទៅដល់ប្រជាពលរដ្ឋ។ បន្ថែមពីនេះទៅទៀត ទីកន្លែងដែលរដ្ឋបានប្រគល់ជូនប្រជាពលរដ្ឋនោះ វាបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដូចជាងាយស្រួលនៅក្នុងការប្រកបរបរចិញ្ចឹមជីវិត នៅជិតទីប្រជុំជនដែលមានភាពអ៊ូអរ ក្មេងៗមានសាលារៀននៅក្នុងភូមិដោយមិនចាំបាច់ធ្វើដំណើរទៅរៀននៅភូមិដទៃទៀត ថែមទាំងមានមណ្ឌលសុខភាពសម្រាប់សម្រាកព្យាបាលពិគ្រោះជំងឺនៅក្នុងភូមិជាដើម។[៥១]

ដូច្នេះ នេះគឺជាទិដ្ឋភាពមួយដែលនាងខ្ញុំបានមើលឃើញថារាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ទៅលើប្រជាពលរដ្ឋក្នុងការជួយទៅដល់ប្រជាពលរដ្ឋឱ្យមានលំនៅឋានសមរម្យ ធានាសិទ្ធិកាន់កាប់ដោយស្របច្បាប់ លើកកម្ពស់ជីវភាព សុខមាលភាព និងកាត់បន្ថយនូវភាពក្រីក្រ ព្រមទាំងជួយពង្រឹងទៅដល់ស្ថេរភាពសង្គមជាតិថែមទៀតផង។

**២.២.១.២. ការគណនាសំណង**

ការគណនាសំណងអស្សាមិករណ៍ គឺគេត្រូវគិតទៅលើព្យសនៈកម្មដែលកើតមានឡើងចំពោះអចលនវត្ថុទាំងអស់ ដោយបូកបញ្ចូលទាំងដីធ្លី ផ្ទះសម្បែង និងផលដំណាំជាអាទិ៍។ ចំពោះការគណនានេះ គឺត្រូវធ្វើការទូទាត់សំណងលើអចលនវត្ថុក្នុងទំហំស្មើគ្នាដែលត្រូវបានដកហូតដោយអាជ្ញាធរមានសមត្ថកិច្ច។ ម្យ៉ាងវិញទៀត ដើម្បីបង្កើននូវទំនុកចិត្តជូនប្រជាពលរដ្ឋក្នុងការទទួលបាននូវសំណងមួយយ៉ាងសមរម្យ ព្រមទាំងមានភាពយុត្តិធម៌គណៈកម្មាធិការអស្សាមិករណ៍ និងធ្វើការចុះវាស់វែង កត់ត្រានូវវត្ថុដែលត្រូវបានប៉ះពាល់ដោយគម្រោង ថែមទាំងធ្វើការស៊ើបសួរតម្លៃអចលនវត្ថុនៅតាមតំបន់ដែលទទួលរងនូវគម្រោងអស្សាមិករណ៍នេះ។ ហើយម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ មានសិទ្ធិទទួលបាននូវសំណងលើការខូចខាតអចលនវត្ថុជាក់ស្តែងដែលមានចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ដែលជាកាលបរិច្ឆេទចុងក្រោយសម្រាប់មានសិទ្ធិទទួលបាននូវសំណងសមរម្យ និងយុត្តិធម៌។[៥២]

[៥១] សូមមើលឧបសម្ព័ន្ធរូបភាពទី៥។

[៥២] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/00៣, ២៦ កុម្ភៈ ២០១០, មាត្រា២៣។

ក្នុងនោះផងដែរ ការគណនាសំណងនេះ វាមិនត្រឹមតែជាការគណនាសំណងដោយគិតទៅលើតម្លៃដី ឬតម្លៃផ្ទះតែប៉ុណ្ណោះទេ តែគេក៏គិតទៅលើអាជីវកម្មរបស់ប្រជាពលរដ្ឋដែលត្រូវបានរងគ្រោះដោយសារគម្រោងអស្សាមិករណ៍នេះផងដែរ។ ចំពោះការដកហូតយកទីតាំងដែលកំពុងមានសកម្មភាពអាជីវកម្ម ម្ចាស់អចលនវត្ថុ ឬភតិកៈអចលនវត្ថុដែលកំពុងប្រកបអាជីវកម្ម ត្រូវមានសិទ្ធិទទួលបាននូវសំណងឧបត្ថម្ភបន្ថែមដោយអត្រាសមរម្យ និងយុត្តិធម៌ លើតម្លៃនៃទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ជាក់ស្តែង ដោយគិតត្រឹមថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍។[៥៣] បន្ថែមពីនេះ រាជរដ្ឋាភិបាលក៏ត្រូវគិតគូរនូវសំណងបន្ទាប់បន្សំដែលមានដូចជា ផលដំណាំនៅលើអចលនវត្ថុ ឬតម្លៃនៃការជួលពលកម្មក្នុងការរុះរើផ្ទះសំបែង ព្រមទាំងថ្លៃដឹកជញ្ជូនជាដើមផងដែរ។ **<u>ឧទាហរណ៍</u>** លោក ក បានបាត់បង់ដី និងលំនៅឋានរបស់គាត់ដោយសារតែការធ្វើគម្រោងអស្សាមិករណ៍មួយកន្លែង។ ហើយគាត់ត្រូវចំណាយប្រាក់ ៥០.០០០ (ប្រាំម៉ឺន) ដុល្លារ ដើម្បីទិញដី និងផ្ទះមួយកន្លែងនៅក្បែរនោះដែលមានទំហំ និងគុណភាពដូចគ្នា។ ដូច្នេះ លោក ក ត្រូវទទួលបានសំណងជាប្រាក់ចំនួន ៥០.០០០(ប្រាំម៉ឺន) ដុល្លារ ពីរាជរដ្ឋាភិបាលវិញ។ ប្រសិនបើ លោក ក ត្រូវចំណាយ ៥.០០០ (ប្រាំពាន់) ដុល្លារ សម្រាប់ការរុះរើចេញ និងបង់ថ្លៃសុំប័ណ្ណកម្មសិទ្ធិ ឬចំណាយផ្សេងៗទៀត គាត់ក៏ត្រូវទទួលបានប្រាក់ចំណាយបែបនេះដែរ។ រដ្ឋាភិបាលចាំបាច់ត្រូវប្រាកដថា ប្រាក់ដែលទទួលបានចំនួន ៥៥.០០០ (ប្រាំម៉ឺនប្រាំពាន់) ដុល្លារ អាចឱ្យពួកគាត់ទិញបានដី និងផ្ទះ ព្រមទាំងការចំណាយផ្សេងៗបានទាំងស្រុង ដោយគាត់មិនត្រូវបានចំណាយដោយខ្លួនឯងឡើយ។ កាលដែលធ្វើបែបនេះ វាបានផ្តល់នូវសំណងប្រកបទៅដោយសមភាព គណនេយ្យភាព និងតម្លាភាព ប្រកបទៅដោយភាពយុត្តិធម៌ជូនទៅដល់ប្រជាពលរដ្ឋ។

ម្យ៉ាងវិញទៀត នៅពេលដែលគណៈកម្មាធិការអស្សាមិករណ៍ទទួលបានសេចក្តីសម្រេចពីរាជរដ្ឋាភិបាល គណៈកម្មាធិការអស្សាមិករណ៍ និងធ្វើការផ្តល់សំណងជូនទៅដល់ប្រជាពលរដ្ឋដែលរងគ្រោះ ដោយរបៀបនៃការទូទាត់សំណងនេះអាជ្ញាធរត្រូវមានតារាងរាយនាមជាច្រើនលើព្យសនៈកម្មដែលបានកើតមានឡើង ដើម្បីធ្វើការវាយតម្លៃបន្ទាប់មកអាជ្ញាធរនិងធ្វើការបូកសរុបលទ្ធផលសំណងជូនទៅដល់ម្ចាស់អចលនវត្ថុ។

### ២.២.២. បញ្ហាប្រឈម និងដំណោះស្រាយ

ជាទូទៅ រាល់កិច្ចដំណើរការនៃការធ្វើអស្សាមិករណ៍តែងតែកើតមានឡើងនូវបញ្ហាប្រឈមជាច្រើនដែលតម្រូវឱ្យរាជរដ្ឋាភិបាលធ្វើការដោះស្រាយជូនទៅកាន់ប្រជាពលរដ្ឋរងគ្រោះ។ ហើយបញ្ហាប្រឈមទាំងអស់នោះវាគឺជាផ្នែកមួយដែលធ្វើឱ្យការធ្វើអស្សាមិករណ៍មានភាពរាំងស្ទះ។ ដូច្នេះ ដើម្បីធ្វើការសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់នាងខ្ញុំនឹងធ្វើការបកស្រាយឱ្យកាន់តែពិស្តារអំពីបញ្ហាប្រឈមដែលតែងតែកើតមានឡើង ព្រមទាំងការដោះស្រាយរបស់រាជរដ្ឋាភិបាល។

[៥៣] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា២៩។

**២.២.២.១. បញ្ហាប្រឈម**

ការធ្វើអស្សាមិករណ៍ គឺជាការដកហូតនូវរាល់កម្មសិទ្ធិឯកជនដោយស្របច្បាប់របស់រាជរដ្ឋាភិបាលក្នុងគោលបំណងស្ថាបនា ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ដើម្បីបម្រើឱ្យផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និងការអភិវឌ្ឍសង្គមជាតិទាំងមូល។ ក៏ប៉ុន្តែ ចំពោះការដកហូតសិទ្ធិលើកម្មសិទ្ធិឯកជនដោយស្របច្បាប់នេះ រាជរដ្ឋាភិបាលក៏ត្រូវផ្តល់នូវទំនុកចិត្តជូនទៅដល់ប្រជាពលរដ្ឋ ពោលគឺត្រូវធានាការទូទាត់សំណងជាមុនដោយសមរម្យ និងមានភាពយុត្តិធម៌ជាទីបំផុត។ តែទោះបីជាយ៉ាងណាក៏ដោយ រាល់ការធ្វើគម្រោងអស្សាមិករណ៍នៅតាមតំបន់នីមួយៗតែងតែជួបប្រទះនូវបញ្ហាប្រឈមជាច្រើនរួមមានដូចជា បញ្ហាប្រឈមរបស់រាជរដ្ឋាភិបាល និងបញ្ហាប្រឈមកើតចេញពីប្រជាពលរដ្ឋ។

**ក. បញ្ហាប្រឈមរបស់រាជរដ្ឋាភិបាល**

ជាទូទៅ មុននឹងរៀបចំកិច្ចដំណើរការនៃការធ្វើអស្សាមិករណ៍ រាជរដ្ឋាភិបាលត្រូវត្រៀមថវិកាបម្រុងទុកជាមុនសម្រាប់ផ្តល់ជាសំណងជូនទៅកាន់ប្រជាពលរដ្ឋរងគ្រោះ ដោយត្រូវធ្វើការគណនារាល់ការចំណាយផ្សេងៗទាំងអស់។ ក៏ប៉ុន្តែ ទាក់ទងទៅនឹងថវិកាបម្រុងនេះវាបានធ្វើឱ្យរាជរដ្ឋាភិបាលជួបប្រទះនូវបញ្ហាប្រឈមជាច្រើនដែលតម្រូវឱ្យរាជរដ្ឋាភិបាលធ្វើការសិក្សាស្វែងរកដំណោះស្រាយដោយសន្តិវិធី។ ក្នុងនោះទៀតសោត ចំពោះបញ្ហាប្រឈមនានាដែលរាជរដ្ឋាភិបាលបានជួបប្រទះរួមមានដូចជា រដ្ឋពុំមានថវិកាគ្រប់គ្រាន់ បាត់បង់ទំនុកចិត្តពីប្រជាពលរដ្ឋ និងធ្វើការកម្ចីថវិកាពីរដ្ឋដទៃជាដើម។ ហេតុនេះហើយ ដើម្បីធ្វើការបកស្រាយឱ្យមានភាពប្រត្យក្សនាងខ្ញុំនឹងធ្វើការលើកឡើងនូវបញ្ហាប្រឈមទាំង ០៣ ខាងលើនេះដូចតទៅ៖

- **បញ្ហាប្រឈមទាក់ទងទៅនឹងរដ្ឋពុំមានថវិកាគ្រប់គ្រាន់**

យើងបានដឹងហើយថា ប្រទេសកម្ពុជាគឺប្រទេសកំពុងអភិវឌ្ឍន៍ ដោយពុំទាន់មានភាពរឹងមាំផ្នែកហិរញ្ញវត្ថុនោះឡើយ។ ដូច្នេះហើយ រាល់ការស្ថាបនា ស្តារ គម្រោងហេដ្ឋារចនាសម្ព័ន្ធនានាក្នុងប្រទេសតែងតែជួបប្រទះនូវបញ្ហាប្រឈមផ្សេងៗជាច្រើនឥតឈប់ឈរ។ ថ្វីបើរដ្ឋពុំមានថវិកាគ្រប់គ្រាន់សម្រាប់កសាងជាតិក៏ពិតមែន ប៉ុន្តែរដ្ឋបានព្យាយាមរិះរកគ្រប់ដំណោះស្រាយក្នុងការស្វែងរកជំនួយឧបត្ថម្ភផ្សេងៗពីបរទេស ក្រុមហ៊ុនឯកជន ឬអង្គការក្រៅរដ្ឋាភិបាលជាអាទិ៍ ក្នុងគោលបំណងផ្តល់នូវជំនួយដោយឥតសំណងជាដើម។ តែទោះបីជាយ៉ាងណាក៏ដោយ ចំពោះជំនួយដែលបានមកនោះវាពុំមានលក្ខណៈងាយស្រួលឡើយ។ ពីព្រោះរាល់ការផ្តល់នូវជំនួយទាំងអស់នេះ គឺតម្រូវឱ្យរដ្ឋគោរពប្រតិបត្តិនូវច្បាប់មួយចំនួនដូចជា រដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីអស្សាមិករណ៍ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តដទៃទៀតជាច្រើន។ ក្នុងករណី ម្ចាស់ជំនួយបានសង្កេតឃើញថា រដ្ឋពុំអនុវត្តន៍នូវច្បាប់ទាំងអស់នេះទេ ម្ចាស់ជំនួយនឹងឈប់ឧបត្ថម្ភថវិកាទៅលើគម្រោងដែលរដ្ឋបានគ្រោងទុក។ ដូច្នេះ ប្រសិនបើម្ចាស់ជំនួយឈប់ធ្វើការឧបត្ថម្ភទាំងពាក់កណ្តាលទី វានឹងធ្វើឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅ

លើគម្រោងដូចជា គម្រោងមិនអាចដំណើរការទៅមុខបានដោយរលូន ហើយប្រជាពលរដ្ឋនឹងលែងមានការទុកចិត្តទៅលើរាជរដ្ឋាភិបាលតទៅទៀត។

❖ **បញ្ហាប្រឈមបាត់បង់ទំនុកចិត្តពីប្រជាពលរដ្ឋ**

ការធ្វើអស្សាមិករណ៍ វាបានផ្តល់នូវផលវិបាកជាច្រើនទៅដល់ប្រជាពលរដ្ឋ ពីព្រោះប្រជាពលរដ្ឋបានលះបង់នូវអចលនវត្ថុផ្ទាល់ខ្លួនឱ្យទៅរាជរដ្ឋាភិបាលយកទៅអភិវឌ្ឍន៍ប្រទេសជាតិ។ ដូច្នេះ ប្រសិនបើនៅក្នុងករណីដែលរដ្ឋបានយកគម្រោងនោះទៅអភិវឌ្ឍន៍ខុសពីគោលដៅ ឬទុកគម្រោងនោះចោល ហើយពុំផ្តល់នូវសំណងមួយដែលសមរម្យ និងមិនមានភាពយុត្តិធម៌ទេនោះប្រជាពលរដ្ឋនឹងបាត់បង់ទំនុកចិត្តពីរាជរដ្ឋាភិបាលជាក់ជាពុំខាន។

❖ **បញ្ហាប្រឈមកម្ចីថវិកាពីរដ្ឋដទៃ**

នៅពេលដែលរដ្ឋពុំមានថវិកាគ្រប់គ្រាន់នឹងមិនអាចស្វែងរកជំនួយឧបត្ថម្ភពីបរទេស ក្រុមហ៊ុនឯកជន ឬអង្គការសង្គមស៊ីវិលដទៃទៀតបាន ប្រាកដណាស់រដ្ឋនឹងធ្វើការកម្ចីថវិកាពីបរទេស ដើម្បីយកមកធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងស្រុកជាក់ជាពុំខាន។ ដោយការខ្ចីប្រាក់ពីបរទេសនេះវាគឺជាបន្ទុកដ៏ធំមួយតម្រូវឱ្យរដ្ឋត្រូវធ្វើការដោះស្រាយ។

**ខ. បញ្ហាប្រឈមកើតចេញពីប្រជាពលរដ្ឋ**

ជាការពិតណាស់ ដើម្បីរៀបចំនីតិវិធីនៃការធ្វើអស្សាមិករណ៍មួយប្រព្រឹត្តទៅបានយ៉ាងឆាប់រហ័សរដ្ឋត្រូវតែធ្វើការចូលរួមសហការណ៍ជាមួយប្រជាពលរដ្ឋយ៉ាងសកម្ម ក្នុងការដកហូតអចលនវត្ថុរបស់ប្រជាពលរដ្ឋនៅត្រង់កន្លែងណាមួយយកមកអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ និងបម្រើផលប្រយោជន៍ជាតិ។ ហើយចំពោះការដកហូតនេះក៏ត្រូវប្រគល់ជាសំណង ឬផ្លាស់ប្តូរទីកន្លែងថ្មីជូនទៅប្រជាពលរដ្ឋរងគ្រោះ ជាថ្នូរសម្រាប់ការដកហូតអចលនវត្ថុរបស់ពួកគាត់។ ប៉ុន្តែ ប្រសិនបើយើងក្រឡេកទៅមើលតាមទិដ្ឋភាពពិតជាក់ស្តែងវិញនោះ ការអនុវត្តអស្សាមិករណ៍មិនមានលក្ខណៈងាយស្រួលនោះឡើយ ពីព្រោះនៅក្នុងករណីដែលរដ្ឋធ្វើការដកហូតដោយគ្មានគោលបំណងច្បាស់លាស់ ព្រមទាំងមិនផ្តល់នូវសំណងមួយយ៉ាងសមរម្យ និងប្រកបទៅដោយភាពយុត្តិធម៌ជូនទៅកាន់ប្រជាពលរដ្ឋទេនោះ ច្បាស់ណាស់បញ្ហាប្រឈមមួយចំនួននឹងកើតមានឡើងជាក់ជាពុំខាន។ ដោយបញ្ហាប្រឈមទាំងនេះភាគច្រើនគេសង្កេតឃើញថា ប្រជាពលរដ្ឋមិនពេញចិត្តនឹងសំណងដែលរដ្ឋបានប្រគល់ជូន និងមិនមានការយល់ដឹងអំពីច្បាប់អស្សាមិករណ៍ជាដើម។ ដូច្នេះ ដើម្បីធ្វើការបកស្រាយឱ្យកាន់តែច្បាស់លាស់ នាងខ្ញុំនឹងធ្វើការលើកឡើងអំពីករណីទាំង ០២ ខាងលើនេះ ដែលជាបញ្ហាប្រឈមកើតមានឡើងជារឿយៗនៅពេលធ្វើអស្សាមិករណ៍៖

❖ **ករណីប្រជាពលរដ្ឋមិនពេញចិត្តនឹងសំណងដែលរដ្ឋបានប្រគល់ជូន**

នៅក្នុងករណីនេះយើងបានធ្វើការកំណត់សម្គាល់នូវសំណងជា០២ផ្នែកគឺ សំណងទូទាត់ជាសាច់ប្រាក់ និងសំណងទូទាត់ជាទ្រព្យ ឬសិទ្ធិជំនួស។ ចំពោះសំណងដែលទូទាត់ជាសាច់ប្រាក់ យើងអាចនិយាយបានថា ប្រជាពលរដ្ឋពុំពេញចិត្តទៅ និងសាច់ប្រាក់ដែលរដ្ឋបានប្រគល់ជូន ពីព្រោះដោយសារតែប្រជាពលរដ្ឋគាត់បាន យល់ឃើញថាសាច់ប្រាក់ដែលរដ្ឋបានផ្តល់ទៅឱ្យពួកគាត់មិនសមស្របទៅតាមតម្លៃទីផ្សារ និងមិនមាននូវភាព សមាមាត្រចំពោះតម្លៃដីរបស់ពួកគាត់ ជាហេតុធ្វើឱ្យគាត់មិនពេញចិត្តទៅនិងសំណងដែលរដ្ឋបានប្រគល់ជូន។ មួយវិញទៀត ទាក់ទងទៅនឹងសំណងទូទាត់ជាទ្រព្យ ឬសិទ្ធិជំនួស ក៏ជួបប្រទះនូវបញ្ហាប្រឈមជាច្រើនមួយចំនួន ផងដែរ។ ដោយយើងបានដឹងហើយថា រាល់ការទូទាត់សំណងដែលជាទ្រព្យ ឬសិទ្ធិជំនួស គឺជាការប្រគល់នូវ អចលនវត្ថុដែលជាតម្លៃតបស្នងទៅកាន់ប្រជាពលរដ្ឋ ហើយវាពុំមែនជាសំណងទូទាត់ជាសាច់ប្រាក់នោះទេ។ ក្នុងនោះផងដែរ នៅពេលដែលរដ្ឋបានប្រគល់អចលនវត្ថុជូនទៅដល់ប្រជាពលរដ្ឋរងគ្រោះ គាត់អាចនឹងមិនពេញ ចិត្តទៅលើទីកន្លែងដែលរដ្ឋបានផ្តល់ឱ្យ ក៏ព្រោះតែទីកន្លែងនោះពិបាកប្រកបមុខរបរចិញ្ចឹមជីវិតព្រមទាំងមិនមាន ហេដ្ឋារចនាសម្ព័ន្ធដូចទៅនឹងទីកន្លែងដែលពួកគាត់រស់នៅពីមុន ឬដីគ្មានជីវជាតិមិនអាចដាំដុះបានជាអាទិ៍។

ឧទាហរណ៍ជាក់ស្តែងដូចជា ការសាងសង់គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ គឺជាទំនប់មួយ ដែលនឹងត្រូវធ្វើការសាងសង់នៅក្នុងទន្លេសេសាន ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង ប្រទេសកម្ពុជា ដែលមាន ចម្ងាយ ១,៥គីឡូម៉ែត្រ ផ្នែកខាងក្រោមនៃចំណុចប្រសព្វគ្នារវាងទន្លេសេសាន និងទន្លេស្រែពក ដែលមានចម្ងាយ ប្រមាណជា ២៥គីឡូម៉ែត្រ ពីចំណុចជួបគ្នានឹងទន្លេមេគង្គ។ គម្រោងនេះត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៃ ប្រទេសកម្ពុជា នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១២។ ដោយការធ្វើគម្រោងនេះ វាបានធ្វើឱ្យមានផលប៉ះពាល់ទៅដល់ អចលនវត្ថុរបស់ប្រជាពលរដ្ឋជាច្រើន ជាហេតុធ្វើឱ្យប្រជាពលរដ្ឋខ្លះមិនមានការពេញចិត្តទៅនឹងគម្រោងនៃ ការសាងសង់នេះ ព្រមទាំងមានការតវ៉ាជាហូរហែដោយមិនចង់ចាកចេញពីទីកន្លែងដែលពួកគាត់ធ្លាប់រស់នៅពី មុនថែមទៀតផង ទោះបីជារដ្ឋបានផ្តល់សំណងមួយចំនួនជូនទៅដល់ពួកគាត់ក៏ដោយ។[៥៤]

❖ **ការមិនយល់ដឹងអំពីច្បាប់ស្តីពីអស្សាមិករណ៍**

ចំពោះបញ្ហានេះ គឺជាករណីមួយដែលរាជរដ្ឋាភិបាលតែងតែជួបប្រទះជានិច្ចនៅរាល់ពេលធ្វើគម្រោង អស្សាមិករណ៍ ពីព្រោះដោយសារតែប្រជាពលរដ្ឋមួយចំនួនគាត់ពុំបានយល់ដឹងយ៉ាងស៊ីជម្រៅទាក់ទងទៅនឹង ច្បាប់ស្តីពីអស្សាមិករណ៍។ ដោយពួកគាត់បានយល់ឃើញថា រាល់ការធ្វើអស្សាមិករណ៍នេះមិនបានផ្តល់នូវ សារៈប្រយោជន៍អ្វីទៅដល់ពួកគាត់នោះទេ ព្រមទាំងមានការភ័យខ្លាចបាត់បង់ និងទទួលរងនូវការរំលោភបំពាន

[៥៤] សៀវភៅ គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ នៅភាគឥសាន្តនៃប្រទេសកម្ពុជា។

សិទ្ធិពីសំណាក់ពួកជនខិលខូចមួយចំនួនផងដែរ។ មូលហេតុនេះគឺបណ្តាលមកពីពួកគាត់មិនបានធ្វើការសិក្សាស្វែងយល់ឱ្យបានល្អិតល្អន់នូវផលប្រយោជន៍ដែលទទួលបានមកពីការធ្វើអស្សាមិករណ៍ ឬអាចនិយាយបានថាប្រព័ន្ធផ្សព្វផ្សាយច្បាប់នៅកម្ពុជាយើងមិនមានលក្ខណៈទូលំទូលាយ ដោយពុំអាចបញ្ជ្រៀបនូវចំណេះដឹងនៃការធ្វើអស្សាមិករណ៍នេះជូនទៅកាន់បងប្អូនប្រជាពលរដ្ឋឱ្យបានយល់ដឹងគ្រប់ៗគ្នា។

**២.២.២.២. ការដោះស្រាយវិវាទអស្សាមិករណ៍**

ជាធម្មតា ទំនាស់តែងតែកើតមាននៅពេលដែលរាជរដ្ឋាភិបាលបានធ្វើការដកហូតអចលនវត្ថុរបស់ប្រជាពលរដ្ឋមកធ្វើគម្រោងអស្សាមិករណ៍។ មូលហេតុដែលបណ្តាលឱ្យកើតមានទំនាស់នេះឡើង ពីព្រោះតែប្រជាពលរដ្ឋមួយចំនួនមិនពេញចិត្តទៅនឹងសំណងដែលរដ្ឋបានផ្តល់ឱ្យ ក៏ដូចជាពុំសូវមានការយល់ដឹងទៅលើច្បាប់ស្តីពីអស្សាមិករណ៍នេះជាដើម។ល។ តែទោះបីជាយ៉ាងណាក៏ដោយ រាល់បញ្ហាទាំងឡាយដែលកើតមានឡើងតែងតែមានដំណោះស្រាយជានិច្ច។ តួយ៉ាង ដូចជាការធ្វើគម្រោងអស្សាមិករណ៍រាជរដ្ឋាភិបាលបានបើកសិទ្ធិឱ្យប្រជាពលរដ្ឋនៅក្នុងការធ្វើបណ្តឹងតវ៉ាគ្រប់សកម្មភាពដែលខ្លួនមិនមានការពេញចិត្តទៅលើគម្រោងនេះ។ ហើយការធ្វើបណ្តឹងនេះទៀតសោត ប្រជាពលរដ្ឋអាចធ្វើការដោះស្រាយជាពីរដំណាក់គឺ ទីមួយដំណាក់កាលនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងទីពីរដំណាក់កាលនៃការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ។

**ក. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ឬ Alternative Dispute Resolution គឺជាការដោះស្រាយវិវាទដោយមិនឆ្លងកាត់នូវនីតិវិធីតាមផ្លូវតុលាការ ឬជាជម្រើសដ៏ល្អប្រសើររបស់គូភាគីនៃវិវាទដែលបានឯកភាពគ្នាធ្វើការដោះស្រាយវិវាទដោយមិនចូល ឬមុននឹងចូលតុលាការ។[៥៥] ហើយការដោះស្រាយនេះត្រូវបានអនុវត្តន៍ឡើងដើម្បីឆ្លើយតបទៅនឹងការប្រើនីតិវិធីតុលាការដែលមានភាពស្មុគស្មាញ ចំណាយពេលយូរ ចំណាយថវិកាច្រើន និងមានភាពតានតឹង។ មិនតែប៉ុណ្ណោះ វាក៏ត្រូវបានគេយកទៅប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជា និងជាទូទៅត្រូវបានប្រើនៅក្នុងការដោះស្រាយវិវាទគ្រួសារ ដីធ្លី ធនធានធម្មជាតិ ការងារ និងពាណិជ្ជកម្មស៊ីវិល ព្រមទាំងករណីស៊ីវិលផ្សេងៗទៀតជាដើម។[៥៦] ម្យ៉ាងវិញទៀត បើសិនជាភាគីនៃវិវាទមិនមានការពេញចិត្តជាមួយនឹងដំណោះស្រាយដែលធ្វើឡើងតាមរយៈដំណើរការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះទេ ភាគីនៃវិវាទអាចសម្រេចចិត្តបន្តទៅធ្វើការដោះស្រាយវិវាទនៅក្នុងប្រព័ន្ធតុលាការបាន។ ដូចនេះផងដែរការដោះស្រាយ

[៥៥] សៀវភៅ "ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ" រៀបរៀងដោយ បេក្ខអនុបណ្ឌិតច្បាប់ កៅ សីហា។

[៥៦] សៀវភៅ "ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជា" ឯកសារស្រាវជ្រាវសង្ខេប នៃគណៈកម្មការទី១ ព្រឹទ្ធសភា។

វិវាទក្រៅប្រព័ន្ធតុលាការក៏ត្រូវបានគេយកទៅអនុវត្តន៍នៅក្នុងកិច្ចដំណើរការនៃការដោះស្រាយវិវាទអស្សាមិករណ៍ផងដែរ។

នៅក្នុងនីតិវិធីនៃការដោះស្រាយវិវាទអស្សាមិករណ៍ គណៈកម្មាធិការអស្សាមិករណ៍ និងគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា គឺជាអ្នកមានសមត្ថកិច្ចទទួលពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ានេះ។[៥៧] ប៉ុន្តែ នៅក្នុងករណីដែលម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ដែលមិនយល់ស្របនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការអស្សាមិករណ៍ អាចប្តឹងទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាបាន។[៥៨] ត្រង់ចំណុចនេះយើងអាចបញ្ជាក់ឱ្យឃើញកាន់តែច្បាស់ថាឋានានុក្រមនៃគណៈកម្មាធិការអស្សាមិករណ៍មានសមត្ថកិច្ចទាបជាងគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា។ ដោយឡែកប្រសិនបើប្រជាពលរដ្ឋរងគ្រោះពុំចង់ដាក់ពាក្យបណ្តឹងទៅគណៈកម្មាធិការអស្សាមិករណ៍ទេ ដោយយល់ឃើញថាវាអាចចំណាយពេលយូរមិនចំណេញពេលវេលា ប្រជាពលរដ្ឋរងគ្រោះអាចធ្វើការដាក់ពាក្យបណ្តឹងទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាតែម្តងក៏បាន។ ដោយសមាសភាពនៃគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ានេះ គឺត្រូវបានបង្កើតឡើង និងដឹកនាំដោយតំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងមានតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួម។[៥៩] ហើយការដាក់ពាក្យបណ្តឹងទៀតសោត អាចប្រព្រឹត្តទៅបានចំពោះតែម្ចាស់អចលនវត្ថុដែលបានរងគ្រោះទៅនឹងគម្រោងនៃកិច្ចដំណើរការនៃការធ្វើអស្សាមិករណ៍តែប៉ុណ្ណោះ។ ចំណែកឯនីតិវិធីនៃការដាក់ពាក្យបណ្តឹងអស្សាមិករណ៍ គឺត្រូវធ្វើឡើងបន្ទាប់ពីម្ចាស់សិទ្ធិទទួលបាននូវសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដោយម្ចាស់សិទ្ធិដែលពុំមានការពេញចិត្តទៅនឹងគម្រោងនោះអាចធ្វើបណ្តឹងសុំឱ្យមានការអង្កេតក្នុងគោលបំណងស្នើសុំទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាជួយធ្វើការសម្របសម្រួលទៅលើបញ្ហារបស់ខ្លួនបាន។ បន្ទាប់មកបណ្តឹងនឹងត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរក្នុងអំឡុងរយៈពេល ៣០ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីបានទទួលសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ជូនចំពោះគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាដោយភ្ជាប់មកជាមួយខ្លឹមសារសំខាន់ៗនៃពាក្យបណ្តឹងដូចជា ឈ្មោះម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ អាស័យដ្ឋាននិង លេខទូរស័ព្ទ មូលហេតុនៃការធ្វើបណ្តឹង ការរៀបរាប់អំពីលក្ខណៈស្របច្បាប់នៃដីនោះ បូករួមទាំងផលប្រយោជន៍របស់ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិនៅលើដីដែលត្រូវបានដកហូត។ បន្ទាប់ពីបានធ្វើការអង្កេតចប់ជាស្ថាពរក្នុងរយៈពេល ៣០ថ្ងៃ នៃថ្ងៃធ្វើការ គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវធ្វើរបាយការណ៍ ដែលក្នុងនោះត្រូវលើកឡើងនូវអនុសាសន៍

[៥៧] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា៣២។

[៥៨] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា៣៣។

[៥៩] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា១៤។

នានា និងសុំការសម្រេចពីរាជរដ្ឋាភិបាល។ ក៏ប៉ុន្តែ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិមិនអាចធ្វើពាក្យបណ្តឹងតវ៉ាសុំឱ្យមានធ្វើការអង្កេតនេះបានទេ ចំពោះតម្រូវការសម្រាប់អភិវឌ្ឍន៍ផ្លូវជាតិធំៗ ស្ពាន ផ្លូវរទេះភ្លើង ការតភ្ជាប់ការចែកចាយបណ្តាយទឹកភ្លើង បំពង់បង្ហូរប្រេងកាត បំពង់បង្ហូរទឹកកខ្វក់ ខ្សែបណ្តាញ ឬលូមេបង្ហូរទឹក ព្រមទាំងប្រព័ន្ធធារាសាស្ត្រជាដើម។[៦០] ដូច្នេះសរុបមក នៅក្នុងករណីប្រសិនបើប្រជាពលរដ្ឋរងគ្រោះពុំមានការពេញចិត្តទៅនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាទៀតនោះ ប្រជាពលរដ្ឋរងគ្រោះអាចធ្វើការដាក់ពាក្យបណ្តឹងទៅតុលាការបន្តទៀតបាន។

**ខ. ការដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ**

ជាគោលការណ៍ ក្នុងករណីប្រសិនបើមិនមានការយល់ព្រមទៅលើសេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាទេ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ អាចប្តឹងទៅតុលាការមានសមត្ថកិច្ច ចំពោះនីតិវិធីអស្សាមិករណ៍ដែលធ្វើឡើងមិនបានត្រឹមត្រូវ ចំពោះការដកហូតដែលមិនយកទៅបម្រើផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និងការទូទាត់សំណងដែលធ្វើឡើងមិនបានគ្រប់ចំនួនសមរម្យ និងយុត្តិធម៌។[៦១]

ក្នុងនោះផងដែរ ចំពោះរឿងក្តីនៃការប្តឹងទាមទារនេះគឺស្ថិតនៅក្រោមសមាសភាពតុលាការរដ្ឋប្បវេណីជាអ្នកដោះស្រាយ។ ហើយអ្វីដែលសំខាន់បំផុតនោះ គឺការដាក់ពាក្យបណ្តឹងតម្រូវឱ្យម្ចាស់សិទ្ធិដែលរងគ្រោះត្រូវយល់ដឹងអំពីសមត្ថកិច្ចតុលាការជាមុនសិន ថាតើតុលាការមួយណាដែលមានសមត្ថកិច្ចនៅក្នុងការដោះស្រាយបណ្តឹងទាក់ទងទៅនឹងការទាមទារសំណងនៃការដកហូតអចលនវត្ថុមកធ្វើអស្សាមិករណ៍។ មូលហេតុដែលតម្រូវឱ្យជនរងគ្រោះធ្វើការស្វែងយល់អំពីតុលាការមានសមត្ថកិច្ច ពីព្រោះតែតុលាការដែលមានសមត្ថកិច្ចគឺជាតុលាការតែមួយគត់ដែលអាចទទួលដោយស្របច្បាប់នូវពាក្យបណ្តឹង វិនិច្ឆ័យលើរឿងក្តី ហើយចេញសាលក្រម ឬសាលដីកាបាន។[៦២] ដោយតុលាការដែលមានសមត្ថកិច្ចនេះគឺសំដៅទៅដល់ប្រព័ន្ធតុលាការទាំង០៣ថ្នាក់មានដូចជា តុលាការសាលាដំបូង តុលាការសាលាឧទ្ធរណ៍ និងតុលាការកំពូល។

ជាងនេះទៅទៀត សម្រាប់ដីការសម្រេចរបស់តុលាការ គឺជាការសម្រេចបិទផ្លូវតវ៉ា មានន័យថាបណ្តឹងរបស់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិមិនអាចធ្វើការដោះស្រាយនៅក្រៅប្រព័ន្ធតុលាការ និងនៅក្នុងប្រព័ន្ធតុលាការជាថ្មីម្តងទៀតបានទេ។ ហើយចំពោះដំណើរការនៃនីតិវិធីរឿងក្តីក្នុងប្រព័ន្ធតុលាការនេះ ជនរងគ្រោះដែលជាម្ចាស់អចលនវត្ថុអាចជ្រើសរើសអ្នកតំណាងដោយអាណត្តិ ដើម្បីជួយសម្រួលទៅដល់រឿងក្តីរបស់ខ្លួន។

[៦០] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា១៨។

[៦១] ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា៣៤។

[៦២] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៧។

អ្នកតំណាងដោយអាណត្តិមានសិទ្ធិអំណាចក្នុងការធ្វើរាល់សកម្មភាពបណ្តឹង ព្រមទាំងការដាក់ពាក្យបណ្តឹង ការឆ្លើយដោះសារចំពោះបណ្តឹង ការឆ្លើយតប ការចូលរួមជួយអន្តរាគមន៍បណ្តឹង ការប្តឹងទៅតុលាការជាន់ខ្ពស់ និងការផ្សះផ្សាការលះបង់ការទាមទារ និងការទទួលស្គាល់នូវការទាមទារ ចំពោះរឿងក្តីដែលខ្លួនបានទទួលពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិដែលរងគ្រោះ។[៦៣]

បន្ថែមពីនេះ ការប្តឹងត្រូវធ្វើដោយដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ ទៅតុលាការ។ ព្រមទាំងបញ្ជាក់នូវឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិដែលរងគ្រោះ ហើយ និងឈ្មោះ និងអាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ព្រមទាំងអង្គហេតុនៃការប្តឹងទាមទារ។[៦៤]

[៦៣] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤។

[៦៤] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៧៥។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

អស្សាមិករណ៍ គឺជាច្បាប់ដែលត្រូវបានបង្កើតឡើងក្នុងគោលដៅផ្តល់នូវសិទ្ធិអត្ថិភាពជូនរាជរដ្ឋាភិបាលអាចដកហូតអចលនវត្ថុដោយស្របច្បាប់លើកម្មសិទ្ធិឯកជន ព្រមទាំងផ្តល់នូវការទូទាត់សំណងជាមុនយ៉ាងសមរម្យ និងយុត្តិធម៌ សម្រាប់គម្រោងស្ថាបនា ស្តារ ពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ដើម្បីបម្រើឱ្យផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ។ ក្នុងនោះផងដែរ ច្បាប់ស្តីពីអស្សាមិករណ៍នេះត្រូវបានរដ្ឋសភាអនុម័ត កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើទី៣ នីតិកាលទី៤ និងត្រូវបានព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យនូវធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេច លេខ១០៨/០០១/២០១០ គ.ប.ធ.ច ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១០។ ដោយច្បាប់នេះត្រូវបានប្រកាសឱ្យប្រើទូទាំងប្រទេសជាការប្រញាប់នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ស្របទៅតាមមាត្រា ៩៣ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា។

ឆ្លងទៅតាមការសិក្សាស្រាវជ្រាវខាងលើ នាងខ្ញុំទាំងពីរនាក់បានយល់ឃើញថា ច្បាប់ស្តីពីអស្សាមិករណ៍នេះពិតជាមានសារៈប្រយោជន៍ខ្លាំងណាស់សម្រាប់ជួយបម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិឱ្យឈានទៅរកភាពរីកចម្រើន។ ហើយក៏បានជួយសម្រួលទៅដល់រាជរដ្ឋាភិបាលនៅក្នុងការស្វែងរកនូវដំណោះស្រាយផ្សេងៗជូនទៅកាន់ប្រជាពលរដ្ឋផងដែរ។ បន្ថែមពីនេះ ដើម្បីឲ្យគម្រោងអស្សាមិករណ៍នៅកន្លែងណាមួយមានភាពជោគជ័យ ច្បាប់ស្តីពីអស្សាមិករណ៍នេះក៏បានធ្វើការបែងចែកនីតិវិធីទៅតាមដំណាក់កាលនីមួយៗមានដូចជា នីតិវិធីមុនធ្វើអស្សាមិករណ៍ និងកិច្ចដំណើរការធ្វើអស្សាមិករណ៍ជាអាទិ៍។

សម្រាប់នីតិវិធីមុនធ្វើគម្រោងអស្សាមិករណ៍ គឺត្រូវធ្វើឡើងដោយផ្អែកលើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដែលមានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាល ព្រមទាំងត្រូវមានការចុះអង្កេតយ៉ាងត្រឹមត្រូវក្នុងការស្វែងយល់អំពីទីតាំងដែលត្រូវបានដកហូតដើម្បីធ្វើរបាយការណ៍ជូនទៅកាន់រាជរដ្ឋាភិបាលធ្វើការពិនិត្យ និងចេញសេចក្តីសម្រេចទៅលើគម្រោង។ បន្ទាប់ពីរាជរដ្ឋាភិបាលបានធ្វើការពិនិត្យសម្រេចទៅលើគម្រោងនេះហើយ គណៈកម្មាធិការអស្សាមិករណ៍ដែលទទួលបន្ទុកទៅលើគម្រោងត្រូវធ្វើការផ្តល់នូវព័ត៌មានជូនទៅដល់ប្រជាពលរដ្ឋដែលរងគ្រោះឱ្យបានដឹងអំពីការដកហូតនេះ។ ក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលរងគ្រោះបានធ្វើការត្រៀមខ្លួនទុកជាមុនសម្រាប់ការដកហូតនូវអចលនវត្ថុយកមកធ្វើអស្សាមិករណ៍។ ក្រោយពីបានប្រកាសព័ត៌មានជូនទៅដល់ប្រជាពលរដ្ឋរួចរាល់ គណៈកម្មាធិការណ៍អស្សាមិករណ៍និងចាប់ផ្តើមរៀបចំកិច្ចដំណើរការអស្សាមិករណ៍នេះជាផ្លូវការ។

ក្នុងកិច្ចដំណើរការអស្សាមិករណ៍ គណៈកម្មាធិការអស្សាមិករណ៍ត្រូវធ្វើការដកហូតអចលនវត្ថុរបស់ប្រជាពលរដ្ឋដោយផ្តល់នូវសំណងមួយយ៉ាងសមរម្យ និងយុត្តិធម៌ជូនទៅកាន់ប្រជាពលរដ្ឋរងគ្រោះ ព្រមទាំងធ្វើការដកហូតអចលនវត្ថុនោះប្រកបទៅដោយការទទួលខុសត្រូវជៀសវាងកុំឱ្យមានការអនុវត្តន៍ខុសប្លែកពីគម្រោង។ មុននឹងចាប់ផ្តើមធ្វើអស្សាមិករណ៍ទៅលើអចលនវត្ថុណាមួយនោះ គឺគេបានធ្វើការរៀបចំគម្រោងថាតើអចលនវត្ថុណាត្រូវធ្វើការដកហូតទាំងស្រុង អចលនវត្ថុណាដែលត្រូវធ្វើការដកហូតមួយផ្នែក ហើយអចលនវត្ថុណាដែលត្រូវធ្វើការដកហូតជាបណ្តោះអាសន្ន។ ដោយមិនត្រូវអនុវត្តន៍ឱ្យខុសពីគម្រោង ឬទុកឱ្យអចលនវត្ថុនោះទំនេរចោលឥតប្រយោជន៍ឡើយ។ ប្រសិនបើគណៈកម្មាធិការអស្សាមិករណ៍បានធ្វើខុសពីគម្រោងដែលបានព្រៀងទុកប្រាកដណាស់វានឹងធ្វើឱ្យមានផលប៉ះពាល់ទៅដល់ប្រជាពលរដ្ឋរងគ្រោះជាក់ជាពុំខាន។ ជាងនេះទៅទៀត ចំពោះនីតិវិធីនៃការទូទាត់សំណងជូនប្រជាពលរដ្ឋ រដ្ឋត្រូវធ្វើការបែងចែកទៅតាមរូបមន្តនៃការទូទាត់សំណង និងការគណនាសំណង ដែលការទូទាត់សំណងនេះរដ្ឋត្រូវធ្វើការទូទាត់ប្រកបទៅដោយតម្លាភាព សមភាព និងមានភាពយុត្តិធម៌ជាទីបំផុតជូនទៅកាន់ប្រជាពលរដ្ឋរងគ្រោះ។ ម្យ៉ាងវិញទៀត ចំពោះបញ្ហាប្រឈមនានាដែលកើតមានឡើង គណៈកម្មាធិការអស្សាមិករណ៍ត្រូវតែស្វែងរកវិធីសាស្ត្រគ្រប់បែបយ៉ាងដើម្បីធ្វើការដោះស្រាយបញ្ហាប្រឈមនេះប្រកបទៅដោយសន្តិវិធីជូនទៅកាន់ប្រជាពលរដ្ឋរងគ្រោះ។ ហើយការដោះស្រាយនេះទៀតសោត គឺគេអាចធ្វើការដោះស្រាយក្រៅប្រព័ន្ធតុលាការ និងក្នុងប្រព័ន្ធតុលាការបាន។

ជាទីបញ្ចប់ នាងខ្ញុំទាំងពីរសូមសន្និដ្ឋានថា ច្បាប់ស្តីពីអស្សាមិករណ៍ វាបានឆ្លើយតបទៅនឹងការអនុវត្តគម្រោងនៃកិច្ចដំណើរការអស្សាមិករណ៍បានយ៉ាងមានប្រសិទ្ធិភាព ព្រមទាំងជួយធ្វើការដោះស្រាយរាល់បញ្ហាផ្សេងៗដែលកើតមានឡើងបានយ៉ាងល្អប្រសើរ។ តែការអនុវត្តជាក់ស្តែងមួយចំនួនគឺពុំទាន់មានលក្ខណៈល្អប្រសើរគ្រប់ជ្រុងជ្រោយនោះទេ ដែលជាហេតុតម្រូវឱ្យរាជរដ្ឋាភិបាលត្រូវធ្វើការគិតគូរចំពោះរឿងនេះ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវ ច្បាប់ស្តីអំពីអស្សាមិករណ៍នេះរួចមក នាងខ្ញុំបានយល់ឃើញថាការអនុវត្ត ច្បាប់ស្តីពីអស្សាមិករណ៍នៅកម្ពុជាពិតជាបានផ្តល់នូវគុណប្រយោជន៍ជាច្រើនក្នុងការជួយសម្របសម្រួលទៅដល់ ការស្ថាបនា ស្តារគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ រាល់កិច្ចដំណើរ ការនីតិវិធីនៃការធ្វើអស្សាមិករណ៍ តែងតែជួបប្រទះនូវបញ្ហាប្រឈមជាច្រើនមួយចំនួនដែលតម្រូវឱ្យរាជរដ្ឋាភិបាល ត្រូវធ្វើការដោះស្រាយ។ ហើយ ចំពោះបញ្ហាប្រឈមដែលកើតមានជារឿយៗនោះ គឺទាក់ទងទៅនឹងការកើតទុក មិនសុខចិត្តរបស់ប្រជាពលរដ្ឋចំពោះការផ្តល់នូវសំណង ព្រមទាំងបញ្ហាផ្សេងៗទៀតជាច្រើន។ ដោយបញ្ហាទាំង អស់នោះវាបានបង្កឱ្យការធ្វើអស្សាមិករណ៍មានភាពរាំងស្ទះ ត្រូវចំណាយពេលយូរ និងថវិកាជាច្រើន។

ដូច្នេះ ដើម្បីដោះស្រាយនឹងបញ្ហាប្រឈមនានាដែលកើតមានឡើង នាងខ្ញុំទាំងពីរនាក់សូមការអនុញ្ញាត លើកឡើងនូវមតិសំណូមពរមួយចំនួនដូចជា៖

- សូមឱ្យរាជរដ្ឋាភិបាលជួយផ្សព្វផ្សាយច្បាប់ស្តីពីអស្សាមិករណ៍ ឱ្យកាន់តែទូលំទូលាយជាងមុន ដូចជា ធ្វើការផ្សព្វផ្សាយតាមរយៈវិទ្យុ ទូរទស្សន៍ និងកាសែតជាដើម។ល។ ដើម្បីឱ្យប្រជាពលរដ្ឋដែលរស់ក្នុង ប្រទេសកម្ពុជាទាំងមូលគាត់បានយល់ដឹងកាន់តែច្បាស់អំពីច្បាប់ស្តីពីអស្សាមិករណ៍នេះ។
- សូមឱ្យប្រជាពលរដ្ឋដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងអស់ មេត្តាយកចិត្តទុកដាក់ដោយធ្វើ ការស្វែងយល់បន្ថែមឱ្យបានច្រើន ពាក់ព័ន្ធទៅនឹងច្បាប់ស្តីពីអស្សាមិករណ៍នេះ ជាពិសេសនោះនីតិវិធី នៃការផ្តល់សំណង។
- សូមឱ្យរាជរដ្ឋាភិបាលធ្វើការសិក្សាអំពីគម្រោងអស្សាមិករណ៍ឱ្យបានច្បាស់លាស់រាល់ព្យសនកម្មដែល បានកើតឡើងនៅមុនពេលអនុវត្តន៍គម្រោង និងធ្វើយ៉ាងណាផ្តល់នូវសំណងមួយយ៉ាងសមរម្យប្រកប ទៅដោយភាពយុត្តិធម៌ជូនទៅកាន់ប្រជាពលរដ្ឋដែលរងគ្រោះ។
- សូមឱ្យរាជរដ្ឋាភិបាលជួយដោះស្រាយរាល់បញ្ហាប្រឈមផ្សេងៗដែលតែងតែកើតមានឡើងនៅពេលធ្វើ អស្សាមិករណ៍ប្រកបទៅដោយសន្តិវិធីជៀសវាងនូវការប្រើប្រាស់កម្លាំងហិង្សាទៅលើប្រជាពលរដ្ឋដោយ ប្រការណាមួយ។
- ដាក់ទោសទណ្ឌទៅដល់មន្ត្រីពុករលួយទាំងឡាយណាដែលមានគំនិតទុច្ចរិត ឆ្លៀតឱកាសកេងប្រវ័ញ្ច ប្រជាពលរដ្ឋនៅក្នុងអំឡុងពេលធ្វើអស្សាមិករណ៍នេះ។

# ឯកសារយោង

# ឯកសារយោង

## ១. ឯកសារយោងជាលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
- ច្បាប់ភូមិបាល ឆ្នាំ២០០១។
- ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦។
- ច្បាប់ស្តីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០។
- អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ, លេខ១១៨ អនក្រ បក, ៨ តុលា ២០០៥។

## ២. ឯកសារជាសៀវភៅ ឬរបាយការណ៍

- វចនានុក្រម សម្តេចព្រះមហាសុមេធាធិបតីជោតញ្ញាណោ ជួន ណាត។
- សៀវភៅ "ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ" រៀបរៀងដោយ បេក្ខអនុបណ្ឌិតច្បាប់ កៅ សីហា។
- សៀវភៅ "ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជា" ឯកសារស្រាវជ្រាវសង្ខេប នៃគណៈកម្មការទី១ ព្រឹទ្ធសភា។
- សៀវភៅ គម្រោងទំនប់វារីអគ្គីសនីសេសានក្រោម២ នៅភាគឥសាន្តនៃប្រទេសកម្ពុជា។
- សៀវភៅគោលនយោបាយជាតិស្តីពី លំនៅឋាន។
- សៀវភៅណែនាំសហគមន៍ស្តីពីនយោបាយការពារការផ្លាស់ប្តូរទីលំនៅដោយបង្ខំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

## ៣. ឯកសារយោងជាគេហទំព័រ

- គេហទំព័រ https://opendevelopmentcambodia.
- គេហទំព័រ https://construction-property.com
- គេហទំព័រ https://documents1.worldbank.org/curated/es/
- គេហេទំព័រ https://www.kohkong.gov.kh/archives/

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធគតិយុត្ត

**ឧបសម្ព័ន្ធទី១៖** រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

**ឧបសម្ព័ន្ធទី២៖** ច្បាប់ភូមិបាល ឆ្នាំ២០០១។

**ឧបសម្ព័ន្ធទី៣៖** ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦។

**ឧបសម្ព័ន្ធទី៤៖** ច្បាប់ស្ដីពីអស្សាមិករណ៍, លេខនស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០។

**ឧបសម្ព័ន្ធទី៥៖** អនុក្រឹត្យស្ដីពីការគ្រប់គ្រងដីរដ្ឋ, លេខ១១៨ អនក្រ បក, ៥ តុលា ២០០៥។

## ២. ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធរូបភាពទី១៖** គម្រោងសាងសង់ស្ពានក្បាលថ្នល់។

**ឧបសម្ព័ន្ធរូបភាពទី២៖** បឹងកក់ដែលលុបហើយ និងបឹងកក់មិនទាន់លុប។

**ឧបសម្ព័ន្ធរូបភាពទី៣៖** ការធ្វើអស្សាមិករណ៍ ដោយដកហូតអចលនវត្ថុរបស់ប្រជាពលរដ្ឋទាំងស្រុងក្នុងតំបន់ពយជំទាវម៉ៅ។

**ឧបសម្ព័ន្ធរូបភាពទី៤៖** ការទូទាត់ប្រាក់សំណងជូនប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារ គម្រោងលើកម្រិតគុណភាពផ្លូវជាតិលេខ៤៨ នៅខេត្តកោះកុង។

**ឧបសម្ព័ន្ធរូបភាពទី៥៖** ការទូទាត់សំណងជាទ្រព្យ ឬសិទ្ធិជំនួស ជូនប្រជាពលរដ្ឋនៅភូមិ៣២ ឃុំតាអុង ស្រុកចំការលើ ខេត្តកំពង់ចាម។

# ឧបសម្ព័ន្ធគតិយុត្ត

# រដ្ឋធម្មនុញ្ញ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

# បុព្វកថា

❖❖❖❖

## យើង ប្រជារាស្ត្រខ្មែរ

ដែលធ្លាប់មានអារ្យធម៌ឧត្តុង្គឧត្តម ប្រទេសជាតិស្តុកស្តម្ភ ធំទូលាយ ថ្កុំថ្កើងរុងរឿង កិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺចែងចាំងដូចពេជ្រពណ្ណរាយ

បានធ្លាក់ខ្លួនដ៏សែនរន្ធត់ ក្នុងអំឡុងពីរទសវត្សរ៍ចុងក្រោយនេះ ឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយ ទ្រុឌទ្រោម ឱនថយមហាសោកស្តាយ

បានភ្ញាក់រលឹក ក្រោកឈរឡើង ចងបាច់ឆន្ទៈមោះមុត ប្តូរផ្តាច់ រួបរួមគ្នា ពង្រឹងឯកភាពជាតិ រក្សាការពារទឹកដីកម្ពុជា អធិបតេយ្យ ថ្លៃថ្លា និងអារ្យធម៌អង្គរដ៏បវរ កសាងប្រទេសជាតិឱ្យទៅជា"កោះសន្តិភាព" ឡើងវិញ ផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ ទទួលខុសត្រូវខ្ពស់ ចំពោះវាសនាអនាគតជាតិ ឱ្យបានឈានឡើងរីកចម្រើនលូតលាស់ សម្បូររុងរឿងជានិច្ចនិរន្តរ៍ ។

## ក្នុងឆន្ទៈមោះមុតនេះ

យើងសរសេរចារឹកក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដូចតទៅ :

**មាត្រា ៤៣.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ ។

សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងល័ក្ខខ័ណ្ឌ ដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

**មាត្រា ៤៤.-**

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ស្ថិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុន ដោយសមរម្យ និងយុត្តិធម៌ ។

**មាត្រា ៤៥.-**

ការរើសអើងគ្រប់ប្រភេទ ប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ចោល ។

-កិច្ចប្រជុំជាសមាជរដ្ឋសភា និងព្រឹទ្ធសភា ត្រូវដឹកនាំដោយសហប្រធាន ។

### មាត្រា ១៥៨.._ថ្មី (មាត្រា ១៣៩ ចាស់)

ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និងដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោល លើកលែងតែបទប្បញ្ញត្តិណា ដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ ។

រដ្ឋធម្មនុញ្ញនេះ

ត្រូវបានសភាធម្មនុញ្ញអនុម័ត

នៅភ្នំពេញ ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៩៣ នាសម័យប្រជុំលើកទី ២

ភ្នំពេញ, ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៩៣

**ប្រធាន**

**សឺន សាន**

# ព្រះរាជក្រម

នស/រកម/០៨០១/១៤

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧបភោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ភូមិបាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៦ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទម្រង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

បទបញ្ញានិងនីតិវិធីនៃការគ្រប់គ្រងអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

# មាតិកាទី ១
# អំពីកម្មសិទ្ធិឯកជននិងកម្មសិទ្ធិសាធារណៈ
## ជំពូកទី ១
## អំពីគោលការណ៍នៃកម្មសិទ្ធិ

**មាត្រា ៤.-**

សិទ្ធិនៃកម្មសិទ្ធិដែលចែងក្នុងមាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ អនុវត្តទៅលើអចលនវត្ថុទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា តាមលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់នេះ ។

**មាត្រា ៥.-**

គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ។ ការដកហូតត្រូវធ្វើឡើងតាមទម្រង់និងនីតិវិធីបញ្ញត្តិដោយច្បាប់និងបទបញ្ញាបន្ទាប់ពី បានផ្តល់សំណងជាមុនដោយសមរម្យនិងយុត្តិធម៌ ។

**មាត្រា ៦.-**

មានតែភោគៈត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះដែលអាចនាំឱ្យបានកម្មសិទ្ធិ ។

រដ្ឋក៏អាចផ្តល់កម្មសិទ្ធិនៃទ្រព្យជាអចលនវត្ថុដែលជារបស់រដ្ឋក្នុងព្រំដែនជាក់លាក់ដែលបានកំណត់ដោយច្បាប់នេះដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ ។

រាល់ការផ្ទេរ ឬផ្លាស់ប្តូរសិទ្ធិនៃកម្មសិទ្ធិត្រូវធ្វើឡើងតាមវិធាននៃនីតិរូបនៃការលក់ ការបន្តមរតក ការដូរ ឬប្រទានកម្ម ឬតាមសេចក្តីសំរេចរបស់តុលាការ ។

**មាត្រា ៧.-**

របបកម្មសិទ្ធិលើអចលនវត្ថុមុនឆ្នាំ ១៩៧៩ មិនត្រូវបានទទួលស្គាល់ ។

រដ្ឋអាចធ្វើអំណោយជាអចលនវត្ថុចំពោះតែរូបវន្តបុគ្គល ដោយហេតុផលសង្គមកិច្ច ដើម្បីឱ្យស្នាក់នៅ ឬដាំដំណាំចិញ្ចឹមជីវិត ។ តម្លៃអចលនវត្ថុដែលផ្តល់ឱ្យ ត្រូវបានកំណត់សមស្របទៅនឹងគោលដៅណាមួយដែលចង់បាន និងមិនអនុញ្ញាតឱ្យកេងយកកំរៃ ឬធ្វើមានបានមិនសមស្របទៅនឹងកំរិតជីវភាពសង្គមនៃអ្នកទទួល ។

ប្រទានកម្មដែលរដ្ឋបានធ្វើពីមុនមកហើយ មិនអាចសើរើបានឡើយ ។

**មាត្រា ៨៤.-**

ប្រទានកម្មទ្រព្យជាអចលនវត្ថុ មិនអាចដកហូតមកវិញបានឡើយ នៅពេលដែលមានការព្រមទទួលហើយនោះ ។ ប្រទានកម្មនេះ អាចធ្វើការផ្ទេរសិទ្ធិកម្មសិទ្ធិបានភ្លាម ។ ប៉ុន្តែទាយក អាចរក្សាទុកសំរាប់ខ្លួន នូវសិទ្ធិផលុបភោគនៃទ្រព្យ សិទ្ធិប្រើប្រាស់ និងអាស្រ័យនៅ នៃចលនវត្ថុដែលត្រូវចែងក្នុងកិច្ចសន្យា និងត្រូវចុះបញ្ជីនៅអង្គភាពសុរិយោដី ។

## មាតិកាទី ៣

## អំពីរបបកម្មសិទ្ធិឯកជន

## ជំពូកទី ៧

## អំពីសិទ្ធិនិងភារកិច្ចនៃកម្មសិទ្ធិករ

## ផ្នែកទី ១ : អំពីការអាស្រ័យផលនៃកម្មសិទ្ធិ

**មាត្រា ៨៥.-**

កម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុ មានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទ្រព្យរបស់ខ្លួនផ្តាច់មុខ និងទូលំទូលាយ កុំឱ្យតែយកទ្រព្យនោះ ទៅប្រើប្រាស់ក្នុងបទណាមួយដែលច្បាប់បានហាមឃាត់ ។

**មាត្រា ៨៦.-**

កម្មសិទ្ធិករនៃទ្រព្យ មិនអាចប្រើប្រាស់ទ្រព្យនោះ ក្នុងគោលដៅព្យាបាទ ឬរំខានដល់តតិយជន និងជា ពិសេស ដល់អ្នកជិតខាងរបស់ខ្លួនបានឡើយ ។

ការប្រើប្រាស់ទ្រព្យជាធម្មតា ដែលមានចរិតធម្មានុរូប មិនអាចចាត់ទុកជាការរំខាន ដែលបណ្តាលឱ្យ រាំងស្ទះដល់ការប្រើប្រាស់ទ្រព្យនោះបានឡើយ ។

**មាត្រា ៨៧.-**

កម្មសិទ្ធករនៃដី អាចធ្វើនៅលើដី នូវរាល់ការដាំដុះ ការរៀបចំ និងការសាងសង់តាមបំណងរបស់ខ្លួន លើកលែងតែមានច្បាប់ហាមឃាត់ ។ ការរៀបចំ ឬការសាងសង់ទាំងនោះ ជាកម្មសិទ្ធិរបស់ខ្លួនទាំងអស់ស្រប តាមបញ្ញត្តិនៃផ្នែកទី ៣ នៃជំពូកនេះ ។

**មាត្រា ៨៨.-**

កម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុ អាចរៀបចំ ឬកែប្រែបានដោយសេរី នូវប្រភេទ និងរចនាសម្ព័ន្ធដើម នៃទ្រព្យរបស់ខ្លួន ស្របតាមការប្រើប្រាស់ដែលខ្លួនចង់ធ្វើ តាមការកំណត់នៃច្បាប់ ។

**មាត្រា ៨៩.-**

ចាត់ទុកជាការកែប្រែប្រភេទ ឬរចនាសម្ព័ន្ធដើមនៃទ្រព្យជាអចលនវត្ថុ ក្នុងន័យនៃច្បាប់នេះ មានជា អាទិ៍ ការគាស់រានដី ការកាប់ព្រៃឈើ ការដាំដំណាំលើដីនោះ ការចាក់បំពេញដី ការឈូសពង្រាបភ្នំ ការជីករុករក ការជីកយកដីចេញ ការជីកអណ្តូងរ៉ែ ឬកន្លែងយកថ្ម ការរៀបចំ ឬការធ្វើឱ្យស្ងួតដែនវារីជាតិ ការរៀបចំដីកសិកម្មទៅជាទីប្រជុំជន ការបង្កើតតំបន់ឧស្សាហកម្ម និងការបង្កើតទីតាំងរោងចក្រ ។

**មាត្រា ៩០.-**

កម្មសិទ្ធករនៃផ្ទៃដី គឺជាកម្មសិទ្ធករនៃផ្នែកក្រោមដី និងរាល់អ្វីៗដែលអាចទាញយកផលបាន កុំឱ្យតែផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៨៨ និងមាត្រា ៨៩ នៃច្បាប់នេះ ។ ព្រំប្រទល់នៃផ្នែកខាងក្រោមដី ត្រូវបានកំណត់តាមបន្ទាត់ឈរនៃផ្ទៃរាបខាងលើ ។

ប៉ុន្តែកម្មសិទ្ធិករ មិនអាចទាមទារយកជាកម្មសិទ្ធិនូវបដិមាករ ចម្លាក់ក្រឡោត ឬបុរាណវត្ថុគ្រប់ប្រភេទដែលបានរកឃើញ ។ ស្នាដៃទាំងនេះ ជាចំណែកនៃបេតិកភណ្ឌជាតិ ហើយត្រូវតែប្រគល់ឱ្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**មាត្រា ២៦៥.-**

រាល់ការប៉ះពាល់ធ្វើឡើងដោយប្រឆាំងនឹងសិទ្ធិលើដីរបស់សហគមន៍ជនជាតិដើមភាគតិច ដោយអាជ្ញាធរដែលទទួលខុសត្រូវគ្រប់គ្រងតំបន់ដែលអចលនវត្ថុនោះតាំងនៅ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.៥០០.០០០ (មួយលានប្រាំសែន) រៀល ដល់ ៥.០០០.០០០ (ប្រាំបួនលាន) រៀល ឬ/និង ផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និង ត្រូវទទួលទោសរដ្ឋបាលថែមទៀត ។

**មាត្រា ២៦៦.-**

ការប៉ះពាល់អចលនវត្ថុរបស់វត្ត ដោយបុគ្គលដែលទទួលបន្ទុកគ្រប់គ្រង ត្រូវបង្ខំឱ្យសងទ្រព្យនោះវិញ និង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.៥០០.០០០ (មួយលានប្រាំសែន) រៀល ដល់ ៥.០០០.០០០ (ប្រាំបួនលាន) រៀល ។

## មាតិកាទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ២៦៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៦៨.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

**ហត្ថលេខា**

**អ៊ឹម ឈុនលឹម**

លេខ : ១៩៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ហត្ថលេខា និង ត្រា**

**ណារ៉ុ តាន់**

# ព្រះរាជក្រម

នស / រកម / ០៧០៦ / ០២១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៦នាសម័យប្រជុំពេញអង្គលើកទី១នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ក្រម
# នីតិវិធីរដ្ឋប្បវេណី

ត្រូវរកជំនួស ។

**មាត្រា ៦.-** ការចូលរួមរបស់តំណាងអយ្យការ

១-ក្នុងករណីដែលយល់ឃើញថា ចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការថា ពាក្យបណ្តឹងត្រូវបានទទួល ។

២-ទោះបីជាគ្មានការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះពីតុលាការក៏ដោយ ក៏តំណាងអយ្យការ អាចចូលរួមក្នុងនីតិវិធីនៃបណ្តឹងរដ្ឋប្បវេណី និងបញ្ចេញយោបល់បានដែរ ប្រសិនបើខ្លួនយល់ឃើញថា ចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ ។

## ជំពូកទី ២

## តុលាការ

### ផ្នែកទី ១

### សមត្ថកិច្ចសាលាជម្រះក្តី

**មាត្រា ៧.-** និយមន័យនៃតុលាការដែលមានសមត្ថកិច្ច

តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការដែលអាចទទួលដោយស្របច្បាប់នូវពាក្យបណ្តឹង វិនិច្ឆ័យលើរឿងក្តី ហើយចេញសាលក្រម ឬ សាលដីកាបាន ។

**មាត្រា ៨.-** សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍

បណ្តឹងចំពោះចុងចម្លើយដែលបានកំណត់ក្នុងចំណុចខាងក្រោមនេះ ត្រូវដាក់ពាក្យបណ្តឹងទៅសាលាដំបូង ដែលមានសមត្ថកិច្ចជម្រះក្តីនៅទីកន្លែងដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-រូបវន្តបុគ្គល :

-លំនៅឋានរបស់ចុងចម្លើយ ។

-ទីសំណាក់ បើពុំមានលំនៅឋាន ឬ មានលំនៅឋានមិនពិតប្រាកដនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខណ្ឌទី ១ ខាងលើនេះ នៅពេលណាក៏បាន ។

**មាត្រា ៥៤.–** សិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ

១-អ្នកតំណាងដោយអាណត្តិមានសិទ្ធិអំណាចក្នុងការធ្វើរាល់សកម្មភាពបណ្ដឹង ព្រមទាំងការដាក់ពាក្យបណ្ដឹង ការឆ្លើយដោះសាចំពោះបណ្ដឹង ការប្ដឹងតប ការចូលរួមអន្តរាគមន៍បណ្ដឹង ការប្ដឹងទៅតុលាការជាន់ខ្ពស់ ការផ្សះផ្សា ការលះបង់ការទាមទារ និង ការទទួលស្គាល់នូវការទាមទារ ចំពោះរឿងក្ដីដែលខ្លួនបានទទួលអាណត្តិ ។

២-សិទ្ធិតំណាងដែលត្រូវបានប្រគល់សម្រាប់បណ្ដឹងរាប់បញ្ចូលទាំងសិទ្ធិលើការចាត់ចែងរក្សាការពារ ការអនុវត្តដោយបង្ខំ ការជ្រើសតាំងអនុតំណាង និង ការទទួលនូវការសង ។

៣-ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិជាមេធាវី ភាគីពុំអាចកម្រិតនូវសិទ្ធិតំណាងបានទេ លើកលែងតែករណីទាក់ទងនឹងការដាក់ពាក្យបណ្ដឹងតប ការដកពាក្យបណ្ដឹង ការផ្សះផ្សា ការលះបង់ការទាមទារ ការទទួលស្គាល់នូវការទាមទារ ការដកខ្លួនពីបណ្ដឹង ការដាក់ពាក្យបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ការដកពាក្យបណ្ដឹងឧបាស្រ័យពីតុលាការជាន់ខ្ពស់ និង ការជ្រើសតាំងអនុតំណាង ។

៤-ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិមិនមែនជាមេធាវី ភាគីក៏អាចឱ្យអ្នកតំណាងដោយអាណត្តិនោះ ធ្វើតំណាងចំពោះតែសកម្មភាពបណ្ដឹងមួយចំនួនដែលបានកំណត់ដោយឡែកៗដោយភាគីបានដែរ ។

៥-បញ្ញត្តិនៃកថាខណ្ឌទាំងបួនខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះអ្នកតំណាងដែលត្រូវបានអនុញ្ញាតដោយច្បាប់ក្នុងការធ្វើសកម្មភាពបណ្ដឹងជំនួសភាគី ។

**មាត្រា ៥៥.–** ករណីដែលសិទ្ធិតំណាងដោយអាណត្តិមិនរលត់

សិទ្ធិអំណាចនៃអ្នកតំណាងដោយអាណត្តិមិនត្រូវរលត់ឡើយ ទោះបីជាមានករណីដែលភាគីទទួលមរណភាព ឬ បាត់បង់សមត្ថភាពក្នុងការធ្វើបណ្ដឹង ឬ មានករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវបានប្ដូរ ជាអាទិ៍ ក៏ដោយ ។

**មាត្រា ៥៦.–** ហេតុនៃការរលត់នូវសិទ្ធិតំណាងដោយអាណត្តិ

១-សិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិត្រូវរលត់ ដោយហេតុដូចជាមរណ-

# គន្ថីទី ២
# នីតិវិធីនៃការជម្រះក្តីលើកទី ១

## ជំពូកទី ១
## បណ្តឹង

**មាត្រា ៧៤.–** ផលប្រយោជន៍នៃបណ្តឹង

បណ្តឹងអាចធ្វើឡើងបាន ក្នុងករណីដែលបណ្តឹងនោះមានកម្មវត្ថុជាវិវាទតាមផ្លូវច្បាប់ជាក់ស្តែង និង ដែលវិវាទនោះអាចដោះស្រាយដោយសាលក្រម ។

**មាត្រា ៧៥.–** របៀបដាក់ពាក្យបណ្តឹង និង ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង

១-ការប្តឹង ត្រូវធ្វើដោយដាក់ពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរ ទៅតុលាការ ។

២-នៅក្នុងលិខិតនៃពាក្យបណ្តឹង ត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ។

៣-នៅក្នុងពាក្យបណ្តឹង ក្រៅពីចំណុចដែលបានកំណត់នៅក្នុងចំណុច ខ នៃកថាខណ្ឌទី ២ ខាងលើនេះ ដើមចោទគប្បីសរសេរបញ្ជាក់ឱ្យច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង តាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាង ។

៤-ពាក្យបណ្តឹងដែលមានសរសេរអំពីមធ្យោបាយតទល់ ឬ ការពារខ្លួន ត្រូវចាត់ជាឯកសារត្រៀមផងដែរ ។

**មាត្រា ៧៦.–** បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនៅពេលអនាគត

បណ្តឹងទាមទារការផ្តល់តាវកាលិកនៅពេលអនាគត អាចធ្វើឡើងបាន លុះត្រាតែមាន

# គន្ថីទី ៩

# អវសានប្បញ្ញត្តិ

## ជំពូកទោល

## អវសានប្បញ្ញត្តិ

**មាត្រា ៥៨៧.-** ការអនុវត្តក្រមនេះ

ក្រោយពីចូលជាធរមាន ក្រមនេះត្រូវផ្សព្វផ្សាយរយៈពេល ១ (មួយ) ឆ្នាំ ទើបអនុវត្ត ។

**មាត្រា ៥៨៨.-** ការធ្វើឱ្យនិរាករណ៍នូវច្បាប់ផ្សេង ជាអាទិ៍

១-ច្បាប់ដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវបាត់បង់អានុភាព ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត ៖

ក-ច្បាប់ស្តីអំពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥១ ក្រ ចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ១៩៩២ ។

ខ-ច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលត្រូវបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ ០៧ ក្រ ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

២-បញ្ញត្តិនៃច្បាប់ផ្សេងទៀត ដែលមានអានុភាពនៅពេលក្រមនេះត្រូវបានអនុវត្ត ហើយផ្ទុយនឹងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកជា គ្មានអានុភាព ត្រឹមទំហំដែលផ្ទុយនឹងក្រមនេះ ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០០៦

នស/រកម-០៧០៦-០១៧ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខ : ៧៨៣ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ. ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃួន ជិនកេន**

# ព្រះរាជក្រម

នស/រកម/០៣១០/០០៣

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីអស្សាមិករណ៍ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៦ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ១០៨/០០១/២០១០ ក.ធ.ប ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១០ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE * LE ... ROYAL *

# ច្បាប់

# ស្តីពី

# អស្សាមិករណ៍

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅកំណត់ពីអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយកំណត់ពីគោលការណ៍ យន្តការ នីតិវិធីនៃអស្សាមិករណ៍ និង សំណងឱ្យបានសមរម្យ និង យុត្តិធម៌ សម្រាប់គម្រោងស្ថាបនា ស្តារ និង គម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ បម្រើឱ្យផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និង ការអភិវឌ្ឍរបស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលបំណងជាអាទិ៍ :

- ធានាការដកសិទ្ធិស្របច្បាប់លើកម្មសិទ្ធិឯកជនដោយសមរម្យ និង យុត្តិធម៌
- ធានាការទូទាត់សំណងជាមុនដោយសមរម្យ និង យុត្តិធម៌
- បម្រើផលប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ជាតិ
- ធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះការធ្វើអស្សាមិករណ៍ដែលមានពាក់ព័ន្ធទៅនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់នេះ មិនគ្របដណ្តប់លើកិច្ចព្រមព្រៀង ឬ អនុស្សារណៈ ស្តីពីការគាំពារវិនិយោគរវាងរាជរដ្ឋាភិបាល និង ប្រទេសជាដៃគូដែលមានចែងពីអស្សាមិករណ៍ទេ ។ ក្នុងករណីដែលពុំមានកិច្ចព្រមព្រៀងនេះទេ ឬ ក្នុងករណីដែលកិច្ចព្រមព្រៀង ឬ អនុស្សារណៈពុំមានចែងពីអស្សាមិករណ៍ គឺត្រូវស្ថិតនៅក្រោមអានុភាពនៃច្បាប់នេះ ។

**មាត្រា ៤.-**

ពាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះមានដូចតទៅ :

**អស្សាមិករណ៍** សំដៅដល់ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬ សិទ្ធិប្រត្យក្សលើអចលនវត្ថុរបស់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និង នីតិបុគ្គលសាធារណៈ រួមមាន ដី សំណង់ និង ដំណាំដាំដុះសម្រាប់បម្រើការស្ថាបនា ស្តារ និង ពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដែលបម្រើប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ជាតិ ព្រមទាំងផ្តល់នូវសំណងជាមុនដោយសមរម្យ និង យុត្តិធម៌ ។

**ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ** សំដៅដល់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និង នីតិបុគ្គលសាធារណៈ រួមមាន កម្មសិទ្ធិករ ភោគី និង អ្នកមានសិទ្ធិទាំងឡាយទៅលើទីតាំងដីដែលជាអ្នកទទួលរងនូវផលប៉ះពាល់ដោយសារគម្រោងអស្សាមិករណ៍ ។

**ផលប្រយោជន៍សាធារណៈ ឬ ទូទៅ** សំដៅដល់ការប្រើប្រាស់ដី ឬ ទ្រព្យសម្បត្តិដោយសាធារណជនទូទៅ ឬ ដោយទីភ្នាក់ងារ ឬ ស្ថាប័នរដ្ឋ ឬ សាធារណៈ ។

**តម្រូវការនៃផលប្រយោជន៍ជាតិ** សំដៅដល់សកម្មភាព ឬ គម្រោងមានជាអាទិ៍ :

- ការសាងសង់ ស្តារ ថែទាំ ឬ ពង្រីក សំណង់ចាំបាច់ដល់កិច្ចការពារជាតិ ឬ ការងារសន្តិសុខ

- ការកាន់កាប់ដី ឬ ទ្រព្យសម្បត្តិ ដើម្បីអនុវត្តជាក់ស្តែងនយោបាយការពារបូរណភាពទឹកដី ។

**អ្នកអនុវត្តគម្រោង** សំដៅដល់រដ្ឋ សហគ្រាស និង គ្រឹះស្ថានសាធារណៈ អ្នកម៉ៅការ ឬវិនិយោគិន ។

**ភតិកៈ** សំដៅដល់ រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលទទួលសិទ្ធិកាន់កាប់ និង សិទ្ធិប្រើប្រាស់លើអចលនវត្ថុ ពីម្ចាស់អចលនវត្ថុ ។

**បុគ្គលដែលធ្វើការរារាំង** សំដៅដល់ រូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនទាំងឡាយណាដែលជាមេក្លោង អ្នកសមគំនិត អ្នកញុះញង់ ដែលធ្វើសកម្មភាពដោយផ្ទាល់ ឬ ដោយប្រយោល ដោយគំនិតទុច្ចរិតក្នុងគោលដៅធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការអនុវត្តសេចក្តីសម្រេចអស្សាមិករណ៍ ។

**មាត្រា ៥.-**

គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ មានជាអាទិ៍ :

ក- ការសាងសង់ ឬ ពង្រីកផ្លូវអោយស្វ័យយាន ផ្លូវថ្នល់ ស្ពាន អាកាសយានដ្ឋាន កំពង់ផែ ដោយរួមទាំងរចនាសម្ព័ន្ធ និង ឧបករណ៍ ។

ខ- ការសាងសង់ ឬ ពង្រីកស្ថានីយថាមពល រចនាសម្ព័ន្ធ ឧបករណ៍ និង ខ្សែ សម្រាប់ការបញ្ជូន និង ចែកចាយថាមពលអគ្គិសនី ។

គ- ការសាងសង់ ឬ ពង្រីកអគារ និង ឧបករណ៍សម្រាប់ប្រៃសណីយ៍ និង ទូរគមនាគមន៍ និង ប្រព័ន្ធព័ត៌មានវិទ្យា ។

ឃ- ការសាងសង់ ឬ ពង្រីកផ្លូវ ធ្លាក្រុង ចំណតយានយន្ត ទីផ្សារ សួនច្បារ និង ទីលានសាធារណៈ ។

ង- ការសាងសង់ ឬ ពង្រីកប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធលូទឹកកខ្វក់ និង កន្លែងបម្រើសេវាសាធារណៈផ្សេងទៀត ។

ច- ការសាងសង់ ឬ ពង្រីកអគារ សម្រាប់អប់រំបណ្តុះបណ្តាលវិទ្យាសាស្ត្រ វប្បធម៌ ថែរក្សាសុខភាព សន្តិសុខសង្គម និង កីឡាដ្ឋានសម្រាប់សម្តែងជូនជាសាធារណៈ ។

ឆ- ការសាងសង់ ឬ ពង្រីកកន្លែងចម្រាញ់ និង កន្លែងប្រព្រឹត្តកម្ម សំណង់ ឧបករណ៍ សម្រាប់ការការពារធម្មជាតិ និង បរិស្ថាន ។

ជ- ការសាងសង់ ឬ ពង្រីកអគារ និង ឧបករណ៍សម្រាប់ស្រាវជ្រាវ និង សម្រាប់ការធ្វើអាជីវកម្មរ៉ែ និង ធនធានធម្មជាតិផ្សេងទៀត ។

ឈ- ការសាងសង់ ឬ ពង្រីកបណ្តាញឧស្ម័ន បណ្តាញបំពង់ប្រេងឥន្ធនៈ រោងចក្រចម្រាញ់ប្រេង រោងចក្របូមប្រេង និង បណ្តាញដទៃទៀត ។

ញ- ការសាងសង់ ឬ ពង្រីកអគារតាំងទីលំនៅដែលបណ្តាលមកពីការបំផ្លាញយ៉ាងធ្ងន់ធ្ងរពីធម្មជាតិមាន រញ្ជួយផែនដី ទឹកជំនន់ អគ្គិភ័យ និង គ្រោះចាក់ដីជាដើម និង ការរៀបចំសម្រាប់ការតាំងទីលំនៅឡើងវិញ ។

ដ- ការសាងសង់ ឬ ពង្រីកអគារសម្រាប់ការការពារ និង ការគាំពារប្រជាជន ។

ឋ- ការសាងសង់ ឬ ពង្រីកទីកន្លែងឆ្លងកាត់ព្រំដែន ។

ឌ- ការកសាង ពង្រីក ឬ ការរៀបចំសំណង់ចាំបាច់ដល់កិច្ចការពារជាតិ ឬ ការធានាសន្តិសុខ ។

ឈ- ការបង្កើតឡើងថ្មីនូវតំបន់ការពារធនធានធម្មជាតិ ព្រៃឈើ បេតិកភ័ណ្ឌវប្បធម៌បុរាណវិទ្យា ឬ ការពារបរិស្ថាន ។

ញ- ការអនុវត្តតាមតម្រូវការរបស់ជាតិ តាមការកំណត់របស់រាជរដ្ឋាភិបាល។

## ជំពូកទី ២

## គោលការណ៍ទូទៅ

**មាត្រា ៦.-**

អស្សាមិករណ៍ អាចធ្វើលើអចលនវត្ថុមួយផ្នែកឬទាំងស្រុង ឬ លើសិទ្ធិប្រត្យក្សនៃអចលនវត្ថុ ។

**មាត្រា ៧.-**

មានតែរដ្ឋទេដែលជាអ្នកធ្វើអស្សាមិករណ៍ ដើម្បីប្រើប្រាស់ក្នុងគោលដៅជាផលប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ជាតិ ។

អស្សាមិករណ៍អាចអនុវត្តទៅបាន លុះត្រាតែយកទៅអនុវត្តគម្រោង ដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់នេះ ។

**មាត្រា ៨.-**

រដ្ឋត្រូវតែទទួលទិញយកនូវចំណែកនៃអចលនវត្ថុ ដែលនៅសេសសល់ពីអស្សាមិករណ៍ ដោយថ្លៃសមរម្យ និង យុត្តិធម៌ តាមសំណើរបស់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិដែលពុំអាចរស់នៅក្បែរគម្រោងបាន ឬ ពុំអាចសាងសង់លំនៅឋានបាន ឬ ពុំអាចប្រកបអាជីវកម្មអ្វីផ្សេងទៀតបាន ។

**មាត្រា ៩.-**

អចលនវត្ថុដែលត្រូវបានដកហូតនេះ ត្រូវប្រើប្រាស់សម្រាប់តែក្នុងគោលដៅដែលបានគ្រោងទុកនៅក្នុងប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដើម្បីប្រយោជន៍សាធារណៈ ឬតម្រូវការនៃផលប្រយោជន៍ជាតិប៉ុណ្ណោះ និង មិនអាចឱ្យទុកនៅចោលទំនេរដោយគ្មានហេតុផលសមស្រប ឬ ផ្ទេរឱ្យតតិយជនណាម្នាក់ក្នុងគោលដៅបម្រើផលប្រយោជន៍ឯកជន

អចលនវត្ថុដែលនៅសល់ពីតម្រូវការប្រើប្រាស់ ត្រូវផ្តល់អាទិភាពលក់ជូនម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ តាមអត្រាតម្លៃនៃការទូទាត់សំណង ។ ក្នុងករណីដែលម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិមិនព្រមទទួលយកអចលនវត្ថុដែលសល់ពីតម្រូវការប្រើប្រាស់វិញទេ ត្រូវរក្សាទុកអចលនវត្ថុនោះជាទ្រព្យសម្បត្តិរបស់រដ្ឋ ។

**មាត្រា ១០.-**

ក្នុងករណីពិសេស និង បន្ទាន់ ដែលសុវត្ថិភាពសាធារណៈតម្រូវ ដូចជា ប្រយុទ្ធប្រឆាំងគ្រោះអគ្គិភ័យ ទឹកជំនន់ ភ្លើងឆេះព្រៃ រញ្ជួយដី សង្គ្រាមដែលប្រុងនឹងកើតឡើង ឬ ការវាយប្រហារដោយភេរវកម្ម និង ស្ថានភាពផ្សេងៗទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល រាជរដ្ឋាភិបាលអាចធ្វើការដកហូតអចលនវត្ថុ ឬ សិទ្ធិប្រត្យក្សលើអចលនវត្ថុជាបណ្តោះអាសន្ន ដោយមិនចាំបាច់ធ្វើការពិគ្រោះយោបល់ឡើយ ហើយត្រូវប្រគល់ជូនម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិវិញនៅពេលចប់ការដកហូតនេះ ។

ក្នុងករណីបន្ទាន់ និង ចាំបាច់ដែលផលប្រយោជន៍ជាតិតម្រូវ រាជរដ្ឋាភិបាលមានអំណាចឆន្ទានុសិទ្ធិក្នុងការធ្វើអស្សាមិករណ៍ ដោយមិនចាំបាច់រៀបចំធ្វើការពិគ្រោះយោបល់តាមនីតិវិធី ដូចមានចែងក្នុងជំពូកទី ៤ នៃច្បាប់នេះទេ ។

**មាត្រា ១១.-**

មុននឹងដំណើរការការងារអស្សាមិករណ៍ រាជរដ្ឋាភិបាលត្រូវគ្រោងថវិកាប្រចាំឆ្នាំឱ្យបានគ្រប់គ្រាន់ ហើយត្រូវផ្តល់ឥណទានឱ្យគ្រប់ចំនួន និង ទាន់ពេលវេលាជូនគណៈកម្មាធិការអស្សាមិករណ៍ តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់យកទៅទូទាត់សំណងជូនម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ដែលរងនូវផលប៉ះពាល់ដោយសារអស្សាមិករណ៍ ។

## ជំពូកទី ៣

## យន្តការអស្សាមិករណ៍

**មាត្រា ១២.-**

គណៈកម្មាធិការអស្សាមិករណ៍មួយត្រូវបានបង្កើតឡើង និង ដឹកនាំដោយតំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង មានតំណាងក្រសួងស្ថាប័នពាក់ព័ន្ធចូលរួម ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអស្សាមិករណ៍ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៣.-**

អនុគណៈកម្មាធិការអស្សាមិករណ៍ ជាសេនាធិការនៃគណៈកម្មាធិការអស្សាមិករណ៍ ត្រូវបានបង្កើតឡើង និង ដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និង មានតំណាងមន្ទីរជំនាញ អាជ្ញាធរពាក់ព័ន្ធចូលរួម ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អនុគណៈកម្មាធិការអស្សាមិករណ៍ត្រូវកំណត់ដោយអនុក្រឹត្យ ដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ ។

**មាត្រា ១៤.-**

គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវបានបង្កើតឡើង និង ដឹកនាំដោយតំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ និង មានតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួម ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

## ជំពូកទី ៤
## នីតិវិធីនៃអស្សាមិករណ៍
### ផ្នែកទី ១
### នីតិវិធីមុនអស្សាមិករណ៍

**មាត្រា ១៥.-**

អស្សាមិករណ៍ ត្រូវធ្វើឡើងដោយផ្អែកលើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ និង មានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួង ស្ថាប័នសាមី ។

គណៈកម្មាធិការអស្សាមិករណ៍ ត្រូវរៀបចំសំណើស្តីពីគម្រោងអស្សាមិករណ៍ដាក់ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និង សម្រេច ។

**មាត្រា ១៦.-**

មុននឹងធ្វើសំណើស្តីពីគម្រោងអស្សាមិកករណ៍ គណៈកម្មាធិការអស្សាមិកករណ៍ត្រូវធ្វើការអង្កេតជាសាធារណៈ ដោយត្រូវកត់ត្រាភិនភាគឱ្យបានលម្អិតចំពោះរាល់សិទ្ធិរបស់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ លើអចលនវត្ថុ និង ទ្រព្យសម្បត្តិផ្សេងៗទៀតដែលមានជាប់ពាក់ព័ន្ធនឹងការផ្តល់សំណង ព្រមទាំងត្រូវកត់ត្រានូវរាល់បញ្ហាពាក់ព័ន្ធ ។

ក្នុងការធ្វើការអង្កេតនេះ គណៈកម្មាធិការអស្សាមិកករណ៍ត្រូវរៀបចំចាត់ចែងធ្វើការពិគ្រោះយោបល់ជាសាធារណៈ នៅក្នុងកម្រិតអាជ្ញាធរ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និង តំណាងភូមិ ឬ សហគមន៍ដែលរងនូវអស្សាមិកករណ៍ ដើម្បីផ្តល់ពត៌មាន ជាក់លាក់ ច្បាស់លាស់ និង ទទួលបាននូវមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធអំពីសំណើនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។

ដើម្បីកំណត់ពេលវេលាដកហូត ឬ ទីកន្លែងដែលផ្តល់ថ្មី ឬ សំណង គណៈកម្មាធិការអស្សាមិកករណ៍ ត្រូវសាកសួរគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យបានគ្រប់ជ្រុងជ្រោយ អំពីបញ្ហាអចលនវត្ថុ ដែលពាក់ព័ន្ធនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។

បន្ទាប់ពីបានធ្វើការអង្កេតចប់ជាស្ថាពរក្នុងរយៈពេល ៣០ ( សាមសិប ) ថ្ងៃ នៃថ្ងៃធ្វើការ គណៈកម្មាធិការអស្សាមិកករណ៍ត្រូវធ្វើរបាយការណ៍ ដែលក្នុងនោះត្រូវលើកឡើងនូវអនុសាសន៍នានាជាក់ជូន និង សុំការសម្រេចពីរាជរដ្ឋាភិបាល ។

**មាត្រា ១៧.-**

ផ្អែកលើការសម្រេចរបស់រាជរដ្ឋាភិបាល គណៈកម្មាធិការអស្សាមិកករណ៍ត្រូវចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិកករណ៍ ដែលក្នុងនោះត្រូវជម្រាបដល់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិឱ្យបានដឹងអំពីអចលនវត្ថុដែលជាកម្មវត្ថុនៃការដកហូតនោះ និង ត្រូវចែងអំពីគោលបំណង នៃការដកហូតកម្មសិទ្ធិ និង/ ឬ សិទ្ធិលើអចលនវត្ថុឱ្យបានច្បាស់លាស់ ដោយអនុវត្តតាមនីតិវិធី ដូចខាងក្រោម :

ក- កំណត់អំពីកម្មវត្ថុនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ទីតាំងតម្រោង និង រយៈពេលសម្រាប់អនុវត្តគម្រោង និង អាជ្ញាធរមានសមត្ថកិច្ច ដែលមានសិទ្ធិដើម្បីធ្វើការដកហូតកម្មសិទ្ធិ និង/ ឬ សិទ្ធិ ឬ ទ្រព្យសម្បត្តិឯកជន

ខ- កំណត់អំពីសំណងសមរម្យ និង យុត្តិធម៌

គ- កំណត់រយៈពេលនៃបណ្តឹងតវ៉ា

ឃ- ផ្ញើសេចក្តីប្រកាសទៅដល់គ្រប់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិដោយភ្ជាប់នូវលិខិតចតបម្លងនៃច្បាប់នេះ

ង- ដាក់ស្លាកសម្គាល់ថា អចលនវត្ថុនេះជាកម្មវត្ថុត្រូវដកហូតសម្រាប់បម្រើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ

ច- ផ្សព្វផ្សាយសេចក្តីប្រកាសតាមប្រព័ន្ធផ្សព្វផ្សាយ

ឆ- បិទផ្សាយសេចក្តីប្រកាសនៅសាលាឃុំ សង្កាត់ ពាក់ព័ន្ធនឹងទីតាំងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ហើយសេចក្តីប្រកាសនេះត្រូវផ្សព្វផ្សាយជូនដល់ប្រជាជនដែលមានអចលនវត្ថុពាក់ព័ន្ធដោយមេភូមិ ។

**មាត្រា ១៨.-**

បន្ទាប់ពីទទួលបាននូវសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិអាចធ្វើបណ្តឹងសុំឱ្យមានការអង្កេត ដើម្បីឱ្យដឹងថាជាតម្រូវការមួយចាំបាច់ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ឬ ផលប្រយោជន៍ជាតិពិតប្រាកដមែន ឬ ក៏អាចបង្វែរទីតាំងគម្រោងទៅកន្លែងណាផ្សេងវិញបាន ។ បណ្តឹងនេះអាចធ្វើឡើងតាមរយៈមេធាវី ឬ តំណាងរបស់ខ្លួន ។

បណ្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៣០ ( សាមសិប ) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីបានទទួលសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ជូនចំពោះគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ។ ខ្លឹមសារសំខាន់ៗនៃបណ្តឹងមាន ជាអាទិ៍ :

- ឈ្មោះម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ អាសយដ្ឋាន និង លេខទូរស័ព្ទ
- មូលហេតុនៃការធ្វើបណ្តឹង
- ការរៀបរាប់អំពីលក្ខណៈស្របច្បាប់នៃដីនោះ
- ផលប្រយោជន៍របស់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិនៅលើដីដែលត្រូវ

ដកចម្លងពីច្បាប់ដើម

ប៉ុន្តែម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិមិនអាចធ្វើពាក្យបណ្តឹងតវ៉ាសុំឱ្យមានធ្វើការអង្កេតបានទេ ចំពោះតម្រូវការសម្រាប់កិច្ចអភិវឌ្ឍផ្លូវជាតិធំៗ ស្ពាន ផ្លូវរទេះភ្លើង ការតភ្ជាប់ ការចែកចាយបណ្តាញទឹក ភ្លើង បំពង់បង្ហូរប្រេងកាត បំពង់បង្ហូរទឹកកខ្វក់ ខ្សែបណ្តាញ ឬ លូមេបង្ហូរទឹក ប្រព័ន្ធធារាសាស្ត្រ ។

បន្ទាប់ពីបានធ្វើការអង្កេតចប់ជាស្ថាពរក្នុងរយៈពេល ៣០ ( សាមសិប ) ថ្ងៃ នៃថ្ងៃធ្វើការ គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវធ្វើរបាយការណ៍ ដែលក្នុងនោះត្រូវលើកឡើងនូវអនុសាសន៍នានា និង សុំការសម្រេចពីរាជរដ្ឋាភិបាល ។

## ផ្នែកទី ២
## កិច្ចដំណើរការអស្សាមិករណ៍

**មាត្រា ១៩.-**

ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុ អាចធ្វើទៅបានលុះត្រាតែគណៈកម្មាធិការអស្សាមិករណ៍បានផ្តល់សំណងឱ្យម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិជាមុន ដោយសមរម្យ និង យុត្តិធម៌ តាមគោលការណ៍ និង នីតិវិធីនៃការទូទាត់សំណងដូចមានចែងក្នុងផ្នែកទី ៣ ជំពូកទី ៤ នៃច្បាប់នេះ ។

ការដកហូតនៅតែអាចប្រព្រឹត្តទៅបាន ទោះបីទំនាស់នៅមិនទាន់បានដោះស្រាយរួចរាល់ហើយក្តី ។ ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ដែលបានទទួលប្រាក់សំណងតាមការកំណត់របស់គណៈកម្មាធិការអស្សាមិករណ៍ នៅតែមានសិទ្ធិបន្តការប្តឹងរបស់ខ្លួនទៅតាមនីតិវិធីនៃការជំទាស់ និង ការដោះស្រាយទំនាស់ដូចបានកំណត់ក្នុងមាត្រា ៣៤ ជំពូកទី ៦ នៃច្បាប់នេះ ។

**មាត្រា ២០.-**

ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុដទៃទៀត ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការអស្សាមិករណ៍ ។ សេចក្តីសម្រេចអស្សាមិករណ៍ ត្រូវកំណត់ជាអាទិ៍ :

- កម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុដែលត្រូវដកហូត
- សំណងដែលត្រូវទូទាត់
- កាលបរិច្ឆេទដែលតម្រូវឱ្យម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិធ្វើការរុះរើ ចាកចេញពីទីតាំង និង ធ្វើការប្រគល់អចលនវត្ថុ ជូនគណៈកម្មាធិការអស្សាមិករណ៍ ។

**មាត្រា ២១.–**

គណៈកម្មាធិការអស្សាមិករណ៍ ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចអស្សាមិករណ៍ និង ត្រូវផ្តល់សំណងគ្រប់ចំនួនដល់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ មុននឹងធ្វើអស្សាមិករណ៍ ។

## ផ្នែកទី ៣
## ការទូទាត់សំណងនៃអស្សាមិករណ៍

**មាត្រា ២២.–**

ប្រាក់សំណងដែលត្រូវផ្តល់ឱ្យទៅម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ត្រូវគិតតាមថ្លៃទីផ្សារ ឬ ថ្លៃជំនួសនៅកាលបរិច្ឆេទនៃការចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ។

ថ្លៃទីផ្សារ ឬ ថ្លៃជំនួសត្រូវកំណត់ដោយគណៈកម្មការ ឬ ភ្នាក់ងារឯករាជ្យមួយ តាមការជ្រើសរើសរបស់គណៈកម្មាធិការអស្សាមិករណ៍ ។

**មាត្រា ២៣.–**

ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ មានសិទ្ធិទទួលបាននូវសំណងលើការខូចខាតអចលនវត្ថុជាក់ស្តែង ដែលមានចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដែលជាកាលបរិច្ឆេទចុងក្រោយសម្រាប់មានសិទ្ធិទទួលបាននូវសំណងសមរម្យ និង យុត្តិធម៌ ។

**មាត្រា ២៤.–**

សំណងត្រូវទូទាត់ជាសាច់ប្រាក់ ជាទ្រព្យ ឬ ជាសិទ្ធិជំនួសទៅតាមភាពជាក់ស្តែង ដោយមានការយល់ព្រមពីម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ និង ពីគណៈកម្មាធិការអស្សាមិករណ៍ ។

បែបបទ និង នីតិវិធីនៃការទូទាត់សំណង ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ២៥.-**

ប្រាក់សំណងត្រូវគិតតាមតម្លៃសំណងសរុប ដកចំនួនទឹកប្រាក់បន្ទុកពន្ធប្រថាប់ត្រា និង/ ឬ ពន្ធលើដីធ្លីមិនប្រើប្រាស់ដែលកន្លងមកមិនទាន់បានបង់ជូនរដ្ឋ ហើយគណៈកម្មាធិការអស្សាមិករណ៍ ត្រូវបង់ប្រាក់ពន្ធកាត់ទុកទាំងនោះចូលថវិកាជាតិ តាមនីតិវិធីជាធរមាន ។

**មាត្រា ២៦.-**

ប្រាក់សំណងចំពោះកម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុ មិនត្រូវបានគិតដល់ការប្រែប្រួលនៃតម្លៃដែលកើតមានឡើង ចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍នោះឡើយ ដោយការប្រែប្រួលទាំងនោះអាចពាក់ព័ន្ធដល់ការផ្លាស់ប្តូរវិធានការបម្រុងផ្ទៃដីទុកដែលមានក្នុងផែនការនគរូបនីយកម្ម ដែលកំណត់តំបន់ប្រើប្រាស់ដីធ្លី ឬ ផែនការប្រើប្រាស់ដីធ្លីដែលបានអនុម័តត្រឹមត្រូវ ឬ ដោយការប្រែប្រួលនោះបណ្តាលមកពីសេចក្តីប្រកាស ស្តីពីគម្រោងអស្សាមិករណ៍ ។

**មាត្រា ២៧.-**

បន្ទាប់ពីទទួលបានប្រាក់សំណងគ្រប់ចំនួនរួចហើយ ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ត្រូវទទួលខុសត្រូវក្នុងការថែរក្សា ស្នាក់អាស្រ័យ កាន់កាប់ និង ទទួលផលដែលលើសិទ្ធិ និង អចលនវត្ថុ រហូតដល់មានការទទួលយកអចលនវត្ថុទាំងនោះ ដោយគណៈកម្មាធិការអស្សាមិករណ៍ ។

**មាត្រា ២៨.-**

គណៈកម្មាធិការអស្សាមិករណ៍អាចទទួលយកអចលនវត្ថុ ឬ សិទ្ធិលើអចលនវត្ថុនោះក្រោយពី :

- បានអនុវត្តតាមនីតិវិធី និង លក្ខខណ្ឌដូចមានចែងក្នុងផ្នែកទី ១ និង ផ្នែកទី ២ ជំពូកទី ៤ នៃច្បាប់នេះ

- ការផ្តល់ប្រាក់សំណងត្រូវបានអនុវត្តតាមគោលការណ៍ និង នីតិវិធីដូចមានចែងក្នុងផ្នែកទី៣ ជំពូកទី ៤ នៃច្បាប់នេះ ។

**មាត្រា ២៩.-**

ភតិកៈអចលនវត្ថុដែលមានកិច្ចសន្យាត្រឹមត្រូវ ត្រូវទទួលបាននូវសំណងសម្រាប់ការវិនាសនានា ពាក់ព័ន្ធនឹងការដកហូតជាអាទិ៍ ការរុះរើសំណង់ សម្ភារៈ ការដឹកជញ្ជូនទៅកាន់ទីតាំងថ្មី ។

ចំពោះភតិកៈអចលនវត្ថុដែលកំពុងប្រកបអាជីវកម្ម ត្រូវមានសិទ្ធិទទួលបាននូវសំណងលើផលប៉ះពាល់ដល់អាជីវកម្មនិងការឧបត្ថម្ភបន្ថែមដោយអត្រាសមរម្យ និង យុត្តិធម៌ លើតម្លៃដើមទុនដែលបានចំណាយជាក់ស្តែង សម្រាប់សកម្មភាពនៃការប្រកបរបរអាជីវកម្មនោះ ដោយគិតត្រឹមថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ។

ចំពោះការដកហូតយកទីតាំងដែលកំពុងមានសកម្មភាពអាជីវកម្ម ម្ចាស់អចលនវត្ថុត្រូវមានសិទ្ធិទទួលបានសំណងឧបត្ថម្ភបន្ថែមដោយអត្រាសមរម្យ និង យុត្តិធម៌ លើតម្លៃនៃទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ជាក់ស្តែង ដោយគិតត្រឹមថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ។

## ជំពូកទី ៥

## អន្តរកាលនៃការកាន់កាប់ និង គ្រប់គ្រងអចលនវត្ថុ

**មាត្រា ៣០.-**

ចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិពុំអាចលក់ ឬ ផ្ទេរអចលនវត្ថុនោះឱ្យអ្នកដទៃបានឡើយ ។ លិខិតឯកសារនានា និង នីតិវិធីទាំងអស់ដែលផ្ទុយនឹងបទប្បញ្ញត្តិនេះ ត្រូវចាត់ទុកជាមោឃៈ ។

ចំពោះការប្រើប្រាស់ដី ឬ អចលនវត្ថុពាក់ព័ន្ធ ត្រូវរក្សាលក្ខណៈ និង ទំហំប្រើប្រាស់ដូចមាននៅពេលចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ហើយមិនត្រូវសាងសង់សំណង់នៅលើដីនោះថែមទៀតឡើយ ។ សកម្មភាពណាដែលផ្ទុយនឹងបញ្ញត្តិខាងលើនេះ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ មិនត្រូវមានសិទ្ធិទទួលបានសំណងលើការសាងសង់សំណង់ថ្មីបន្ថែមនោះឡើយ ។

**មាត្រា ៣១.-**

ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ អាចកាន់កាប់អចលនវត្ថុទាំងនោះបានត្រឹមរយៈពេល ១ ( មួយ ) ខែ បន្ទាប់ពីគណៈកម្មាធិការអស្សាមិករណ៍បានទូទាត់សំណងគ្រប់ចំនួនស្របតាមនីតិវិធី ដូចមានចែងនៅក្នុងជំពូកទី ៤ នៃច្បាប់នេះ លើកលែងតែមានការព្រមព្រៀង ឬ មានការអនុញ្ញាតផ្សេងពីនេះ ។

ក្នុងករណីម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិពុំព្រមចាកចេញពីទីកន្លែងនោះ គណៈ-កម្មាធិការអស្សាមិករណ៍អាចស្នើសុំទៅស្ថាប័នមានសមត្ថកិច្ច ឬ អាជ្ញាធរសាធារណៈ ដើម្បីចាត់វិធានការ តម្រូវឱ្យជននោះចាកចេញពីទីកន្លែងដែលបានធ្វើអស្សាមិករណ៍រួចហើយ ។

## ជំពូកទី ៦
## ការដោះស្រាយវិវាទ

**មាត្រា ៣២.-**

គណៈកម្មាធិការអស្សាមិករណ៍ និង គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា មានសមត្ថកិច្ចទទួលពិនិត្យ និង ដោះស្រាយបណ្តឹងតវ៉ា ។

**មាត្រា ៣៣.-**

ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ដែលមិនយល់ស្របនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការអស្សាមិករណ៍ អាចប្តឹងទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ។

**មាត្រា ៣៤.-**

ក្នុងករណីដែលមិនមានការយល់ព្រមចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ អាចប្តឹងទៅតុលាការមានសមត្ថកិច្ច ចំពោះនីតិវិធីអស្សាមិករណ៍ដែលធ្វើឡើងមិនបានត្រឹមត្រូវ ការដកហូតដែលមិនយកទៅបម្រើផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និង ការទូទាត់សំណងដែលធ្វើឡើងមិនបានគ្រប់ចំនួនសមរម្យ និង យុត្តិធម៌ ។

និយាមបទ និង នីតិវិធីប្តឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ៣៥.–**

មន្ត្រីមានសមត្ថកិច្ចដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងរដ្ឋបាល ដោយមិនទាន់គិតពីទណ្ឌកម្មផ្សេងទៀតស្របតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៣៦.–**

បុគ្គលណាដែលធ្វើការរារាំងដល់ការអនុវត្តសេចក្តីសម្រេចអស្សាមិករណ៍ដោយគំនិតទុច្ចរិត ធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការអនុវត្តគម្រោងដែលបម្រើឱ្យផលប្រយោជន៍សាធារណៈ ឬ ផលប្រយោជន៍ជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ( មួយ ) ខែ ដល់ ១ ( មួយ ) ឆ្នាំ និង ពិន័យជាប្រាក់ពី ១០០.០០០ ( មួយសែន ) រៀល ដល់ ២.០០០.០០០ ( ពីរលាន ) រៀល ។

**មាត្រា ៣៧.–**

បុគ្គលណាដែលបានកាន់កាប់ ប្រើប្រាស់ដោយរំលោភបំពានលើទីកន្លែងដែលបានធ្វើអស្សាមិករណ៍រួចហើយ ត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៨.–**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣៩.–**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០១០

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ពរល.១០០២.១០៥

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

**លេខៈ ១៨៥ ច.ល**

**ថតចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ជិនកេន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១១៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងដីរដ្ឋ

*****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/០៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្តក្រុង

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/០៥ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យ លេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីដែលមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីនីតិវិធី ការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៥

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់គោលការណ៍ នីតិវិធី យន្តការ និងការរៀបចំផ្នែកស្ថាប័នសម្រាប់ការគ្រប់គ្រងដីរដ្ឋ លើ ÷

- ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ
- ការចុះបញ្ជី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ
- ការបង្កើត និងការថែរក្សាប្រព័ន្ធទិន្នន័យដីរដ្ឋ
- ការបែងចែក និងការគ្រប់គ្រងដីរដ្ឋ និង
- ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ។

**មាត្រា ២**

ពាក្យបច្ចេកទេសទាំងឡាយខាងក្រោមនេះមានន័យដូចតទៅ ÷

- ដីរដ្ឋ "សំដៅដល់ ដីទាំងអស់ដែលជារបស់រដ្ឋ ហើយដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ឬស្ថាប័នថ្នាក់ជាតិ និងដីដែលត្រូវបានប្រគល់ឱ្យនីតិបុគ្គលសាធារណៈ ឬគ្រឹះស្ថានសាធារណៈដែលបានទទួលស្គាល់ដោយច្បាប់ថា ជានីតិបុគ្គលដើម្បីកាន់កាប់ ។
- អាជ្ញាធរដែនដី " សំដៅដល់ រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ។
- អាជ្ញាធរកាន់កាប់ដីរដ្ឋ " សំដៅដល់ ក្រសួង ឬ ស្ថាប័ន ឬ អាជ្ញាធរដែនដីដែលរដ្ឋបានប្រគល់ដីរដ្ឋណាមួយជាក់លាក់សម្រាប់គ្រប់គ្រង ថែរក្សាការពារ និងប្រើប្រាស់បំរើឱ្យស្ថាប័ន ។
- ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ " សំដៅដល់ក្រុមការងារធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ តាមស្រុក ខណ្ឌ ។

**មាត្រា ៣ ..**

គោលការណ៍ទូទៅសម្រាប់អនុវត្តក្នុងការគ្រប់គ្រងដីរដ្ឋមានដូចខាងក្រោម ÷

ក. ជាទូទៅ រដ្ឋគឺជាម្ចាស់នៃដីទាំងអស់ដែលមិនឋិតនៅក្រោមការកាន់កាប់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬដោយសមូហភាព ស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១ ។

ខ. ដីរដ្ឋរួមមាន ដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ ។

គ. ក្បាលដីរដ្ឋនីមួយៗត្រូវចុះបញ្ជី ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ នៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ។

ឃ. ដីរដ្ឋអាចផ្តល់ឱ្យជាសម្បទានដីសង្គមកិច្ច ជាសម្បទានដីសេដ្ឋកិច្ច ឬជាសម្បទានផ្សេងៗទៀតបានលុះត្រាតែដីនោះត្រូវបានចុះបញ្ជីថា ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ និងត្រូវអនុវត្តតាមនីតិវិធីច្បាប់ ។

**មាត្រា ៤ ..**

ដីសាធារណៈរបស់រដ្ឋជាដីដែលមានជាប់ផលប្រយោជន៍សាធារណៈ និងឋិតនៅក្នុងប្រភេទជាក់លាក់នៃទ្រព្យដែលមានផលប្រយោជន៍សាធារណៈដូចខាងក្រោម ÷

ក. ទ្រព្យទាំងឡាយដែលបង្ហាញការកើតឡើងពីធម្មជាតិ ដូចជា ÷

១. ព្រៃឈើ ។

២. ផ្លូវទឹកដែលនាវា ឬក្បូនអាចចេញចូលបាន បណ្តែតបាន ។

៣. បឹងធម្មជាតិ ។

៤. ច្រាំងទន្លេដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន ។

៥. ត្រើយសមុទ្រ។

ខ. ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសម្រាប់ប្រយោជន៍សាធារណៈទូទៅ ដូចជា ÷

១. តំបន់ផែ។

២. កំពង់ផែ។

៣. ផ្លូវដែក។

៤. ស្ថានីយរថភ្លើង។

៥. ព្រលានយន្តហោះ។

គ. ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈ តាមស្ថានភាពពីកំណើត ឬក្រោយពីបានរៀបចំ ដូចជា ÷

១. ផ្លូវថ្នល់។

២. ផ្លូវលំ។

៣. ផ្លូវរទេះ។

៤. ផ្លូវដើរ។

៥. សួនច្បារ ឧទ្យានសាធារណៈ។

៦. ដីចំណី។

ឃ. ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យដំណើរការសម្រាប់សេវាសាធារណៈ ដូចជា ÷

១. សាលារៀន ឬ អគារសិក្សាសាធារណៈ។

២. អគាររដ្ឋបាល។

៣. មន្ទីរពេទ្យសាធារណៈ។

ង. ដែនបម្រុងធម្មជាតិការពារដោយច្បាប់។

ច. បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ។

ឆ. អចលនវត្ថុជាព្រះរាជទ្រព្យ ដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស។

ជ. ដីផ្សេងៗទៀតដែលមានចរិតបំរើផលប្រយោជន៍សាធារណៈ និងដីដែលមានមូលដ្ឋានគតិយុត្តកំណត់រួចហើយ។

**មាត្រា ៥ .-**

ដីឯកជនរបស់រដ្ឋ រួមមាន ដីទាំងអស់ដែលមិនមែនជាដីសាធារណៈរបស់រដ្ឋ និងមិនមែនជាដីដែលកាន់កាប់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬដោយសមូហភាព ស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១។ ដីឯកជនរបស់រដ្ឋ មានរួមបញ្ចូលដូចជា ទ្រព្យនិទាយាទភាពទាំងអស់ ឬទ្រព្យដែលម្ចាស់ប្រគល់ឱ្យរដ្ឋដោយស្ម័គ្រចិត្ត ឬទ្រព្យដែលមិនអាចកំណត់បាននូវអត្តសញ្ញាណភោគី ឬកម្មសិទ្ធិករស្របច្បាប់។

មាត្រា ៣៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការពាក់ព័ន្ធ អភិបាលគ្រប់ខេត្ត ក្រុង គ្រប់ប្រធានស្ថាប័ន អង្គភាពដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា ២៤ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-គ្រប់ក្រសួង ស្ថាប័នកណ្តាល
-គ្រប់សាលាខេត្តក្រុង
-ដូចមាត្រា ៣៣
-ឯកសារ -កាលប្បវត្តិ

# ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធរូបភាពទី១**

គម្រោងសាងសង់ស្ពានក្បាលថ្នល់






# ឧបសម្ព័ន្ធរូបភាពទី២

បឹងកក់ដែលលុបហើយ និងបឹងកក់មិនទាន់លុប




បឹងកក់នៅពេលមិនទាន់លុប




បឹងកក់ដែលលុបហើយ

# ឧបសម្ព័ន្ធរូបភាពទី៣

ការធ្វើអស្សាមិករណ៍ ដោយដកហូតអចលនវត្ថុរបស់ប្រជាពលរដ្ឋទាំងស្រុងក្នុងតំបន់ពយជំទាវម៉ៅ






## ឧបសម្ព័ន្ធរូបភាពទី៤

ការទូទាត់ប្រាក់សំណងជូនប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារ គម្រោងលើ
កម្រិតគុណភាពផ្លូវជាតិលេខ៤៨ នៅខេត្តកោះកុង






## ឧបសម្ព័ន្ធរូបភាពទី៥

ការទូទាត់សំណងជាទ្រព្យ ឬសិទ្ធិជំនួស ជូនប្រជាពលរដ្ឋនៅ
ភូមិ៣២ ឃុំតាអុងស្រុកចំការលើ ខេត្តកំពង់ចាម



អចលនវត្ថុមុនអនុវត្តន៍គម្រោងអស្សាមិករណ៍



ហេដ្ឋារចនាសម្ព័ន្ធដែលរដ្ឋបានសាងសង់ជូនប្រជាពលរដ្ឋ